00922592

E1/207.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jun-2013, 10:35
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង
# សាធារណៈ
# កិច្ចប្រជុំរៀបចំសវនាការ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៦នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោក ស៊ីម៉ុន មេសិនប៊ឺជ

*(Mr. Simon MEISENBERG)*

លោកស្រី ស៊ូហ្សាន ឡេម *(Ms. Susan Lamp)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក វ៉េង ហ៊ត់

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

នៅព្រឹកនេះ អង្គជំនុំជម្រះធ្វើកិច្ចប្រជុំចុងក្រោយចំពោះសំណុំរឿង០០២/០១។ ក្នុងឋានៈខ្ញុំជាប្រធាន និងជំនួសមុខឲ្យចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមស្វាគមន៍ចំពោះសហព្រះរាជអាជ្ញា សហមេធាវីការពារជនជាប់ចោទ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅព្រឹកនេះ។ ហើយគោលបំណងនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយនៅក្នុងសំណុំរឿង០០២/០១នេះ គឺដើម្បីអនុញ្ញាតឲ្យភាគីមានឱកាសជាលើកចុងក្រោយ ដើម្បីលើកឡើងនូវបញ្ហានានាដែលពុំទាន់បានដោះស្រាយនៅក្នុងពេលសវនាការកន្លងមក។

[០៩:០៧:៤៣]

ហើយបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការនេះត្រូវបញ្ចប់ទៅ អង្គជំនុំជម្រះកំណត់កាលបរិច្ឆេទសវនាការដែលសេសសល់ចុងក្រោយ ហើយនៅពេលដែលសវនាការទាំងនេះបញ្ចប់ទៅនោះ អង្គជំនុំជម្រះនឹងប្រកាសកំណត់អំពីការបិទកិច្ចដំណើរការនីតិវិធីលើការដេញដោលភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១។

ដើម្បីជាការសម្រួលដល់កិច្ចរៀបចំកិច្ចប្រជុំរៀបចំសវនាការនៅពេលកន្លងទៅនេះ អង្គជំនុំជម្រះនូវឧបសម្ព័ន្ធចំនួនបួនទៅភាគីនានា ឧបសម្ព័ន្ធចំនួនបីដំបូង នៃឧបសម្ព័ន្ធទាំងនេះផ្ដល់ទៅភាគីនូវសេចក្ដីសម្រេចបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះលើសំណើទាំងអស់ ដែលភាគីស្នើសុំស្ដាប់សក្ខីកម្មផ្ទាល់មាត់របស់សាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសវនាការ។

ភាគីទាំងអស់នេះបានស្នើសុំស្ដាប់សក្ខីកម្មសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីសរុបទាំងអស់ចំនួន១.០៥៤រូប នៅក្នុងសំណុំរឿង០០២ទាំងមូល។

ឧបសម្ព័ន្ធទី១ នៃឧបសម្ព័ន្ធទាំងនេះ បង្ហាញអំពីបុគ្គលទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះមានបំណងស្ដាប់សក្ខីកម្មនៅក្នុងសវនាការ។

ឧបសម្ព័ន្ធទី២ បង្ហាញពីបុគ្គលទាំងឡាយដែលភាគីបានស្នើសុំឲ្យស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះបានសម្រេចមិនស្តាប់សក្ខីកម្មនៅពេលសវនាការ។

ឧបសម្ព័ន្ធទី៣ បង្ហាញពីបុគ្គលទាំងអស់ដែលមាននៅក្នុងបញ្ជីដើមរបស់ភាគី ដោយអនុលោមតាមវិធាន៨០ សម្រាប់សំណុំរឿង០០២ទាំងមូល ប៉ុន្តែពុំត្រូវបានភាគីនានាចាត់ទុកជាបុគ្គលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១។

សេចក្តីសម្រេចនានា ទាក់ទងទៅនឹងឧសម្ព័ន្ធទី៣នេះ ត្រូវបានលើកឡើង លើកនៅពេលក្រោយបន្ទាប់ពីសវនាការដែលនឹងអាចមាននៅថ្ងៃអនាគត។ ភាគីទាំងអស់បានទទួលឱកាសជាច្រើននៅក្នុងអំឡុងពេលសវនាការដើម្បីកំណត់អត្តសញ្ញាណរបស់បុគ្គលពាក់ព័ន្ធ ដែលនឹងត្រូវកោះហៅ ហើយគោលបំណងនៃកិច្ចប្រជុំរៀបចំសវនាការ គឺពុំមែនឲ្យភាគីលើកឡើងអំពីសំណើមុនៗរបស់ខ្លួនសាជាថ្មីនោះឡើយ។ ផ្ទុយទៅវិញកិច្ចប្រជុំនេះផ្តល់ឱកាសឲ្យភាគីមានឱកាសចុងក្រោយដើម្បីលើកយកនូវបញ្ហាថ្មីៗពាក់ព័ន្ធនឹងឧបសម្ព័ន្ធទាំងនេះ និងបុគ្គលទាំងឡាយដែលភាគីកំណត់អត្តសញ្ញា។ នៅមុនកិច្ចប្រជុំនេះភាគីបានកំណត់អត្តសញ្ញាណសាក្សីបន្ថែមមួយចំនួនទៀតដែលភាគីស្នើសុំឲ្យស្តាប់សក្ខីកម្មនៅក្នុងសវនាការ ហើយអង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យភាគីនៅថ្ងៃនេះដើម្បីពិភាក្សាអំពីសំណើសុំទាំងនេះ។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើទាំងនេះនាពេលដ៏ខ្លីខាងមុខក្រោយកិច្ចប្រជុំរៀបចំសវនាការនេះទៅ។

[០៩:១១:២០]

នៅមុនកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះសាលាដំបូងបានចេញឧបសម្ព័ន្ធទី៤ ដោយលើកឡើងអំពីសំណើទាំងអស់ដែលមានចំនួន២៨៥ ដែលភាគីបានដាក់នៅក្នុងអំឡុងពេលនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ដើម្បីជួយដល់ភាគីក្នុងការកំណត់បញ្ហានានាដែលនៅសេសសល់ចុងក្រោយ អង្គជំនុំជម្រះបានភ្ជាប់សារណា និងសំណើទាំងអស់ រួមជាមួយសេចក្តីសម្រេចឆ្លើយតបទៅនឹងសំណើទាំងនោះ ដែលត្រូវបានធ្វើនៅសវនាការ។ សំណើមួយចំនួនតូចស្ថិតនៅក្រោមការពិចារណារបស់អង្គ-ជំនុំជម្រះនៅឡើយ។

ដើម្បីជាជំនួយដល់កិច្ចពិភាក្សានៅឯកិច្ចប្រជុំរៀបចំសវនាការនោះ អង្គជំនុំជម្រះបានជូនដំណឹងក្រៅផ្លូវការជាមុនទៅភាគីអំពីសេចក្តីសម្រេចទាំងអស់នេះ។ ភាគីត្រូវបានស្នើសុំឲ្យផ្តល់ការជូនដំណឹងជាមុនទៅអង្គជំនុំជម្រះអំពីបញ្ហានានាដែលពួកគាត់មានបំណងលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការ។ ភាគីទាំងអស់បានអនុវត្តតាមសំណើនេះហើយ ចំណុចនេះបានជួយយ៉ាងច្រើនដល់

អង្គជំនុំជម្រះក្នុងការរៀបចំធ្វើផែនការការងាររបស់ខ្លួន។

[០៩:១២:៤៩]

នៅមុនពេលពិភាក្សាអំពីសាក្សីបន្ថែមចំនួន១៧រូប ដែលភាគីបានស្នើសុំឲ្យស្តាប់សក្ខីកម្មនៅមុនពេលបញ្ចប់សវនាការនៃសំណុំរឿង០០២/០១ អង្គជំនុំជម្រះនឹងដោះស្រាយបញ្ហាផ្សេងៗទាំងអស់ដែលភាគីបានលើកឡើងក្នុងកិច្ចប្រជុំរៀបចំសវនាការនេះ។

អំពីសវនាការដេញដោលលើឯកសារជាលើកចុងក្រោយ។ បន្ទាប់ពីបញ្ចប់សក្ខីកម្មសាក្សីដែលរហស្សនាម TCW-801 អង្គជំនុំជម្រះនឹងធ្វើសវនាការជាលើកចុងក្រោយមួយដើម្បីអនុញ្ញាតឲ្យភាគីបង្ហាញឯកសារសំខាន់ៗដែលទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម ទៅនឹងតួនាទីរបស់ជនជាប់ចោទដែលអាចធ្វើនៅក្នុងអំឡុងសប្តាហ៍ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ខាងមុខនេះ។

សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាចំនួន៣ថ្ងៃដើម្បីបង្ហាញឯកសារសំខាន់ៗក្នុងសវនាការនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏ស្នើសុំពេលវេលាដូចគ្នានឹងសហព្រះរាជអាជ្ញាផងដែរ។ អង្គជំនុំជម្រះក៏ចង់ដឹងថា តើនៅក្នុងការស្នើសុំពេលវេលាទាំងនេះ សហមេធាវីនាំមុខ និងសហព្រះរាជអាជ្ញាបានសហការគ្នាដើម្បីធានាថា ភាគីទាំងពីរនឹងមិនបង្ហាញឯកសារដូចគ្នានៅក្នុងសវនាការនេះ ឬអាចផ្តល់បង្ហាញដែលត្រួតជាន់គ្នាដែរឬទេ។

បាទ សូមផ្តល់ឱកាសនេះជូនទៅតំណាងសហព្រះរាជអាជ្ញា រួចក្រុមសហមេធាវីនាំមុខឆ្លើយបញ្ជាក់បញ្ហានេះ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:១៤:៥២]

**លោក វីណ្សៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ទាក់ទងទៅនឹងឯកសារ។ ដូចដែលលោកប្រធានបានបញ្ជាក់អម្បាញ់មិញនេះ យើងបានស្នើសុំ៣ថ្ងៃដើម្បីបង្ហាញ។ ហើយរយៈពេល៣ថ្ងៃនេះគឺទាក់ទងទៅនឹងគោលនយោបាយនៃការជម្លៀសដោយបង្ខំហើយនិងសហករណ៍ អាពាហ៍ពិពាហ៍ដោយបង្ខំ ហើយនិងក្រុមគេកំណត់ជាខ្មាំង ហើយនិងនយោបាយទាក់ទងនឹងខ្មាំង។ យើងមិនទាន់បានពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណីទេ ប៉ុន្តែយើងនឹងធ្វើដូចនោះដើម្បីព្យាយាមធានាថាឯកសារទាំងអស់នោះគឺថា ដើម្បីចៀសវាងការបង្ហាញវាជាន់គ្នាឬក៏ច្រំដែលនោះ យើងខ្ញុំនឹងបញ្ជាក់ជូននៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវសេចក្តីបញ្ជាក់នេះ។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ប្រាកដណាស់យើងនឹងពិភាក្សាអំពីឯកសារទាំងអស់នេះ។ ក៏ប៉ុន្តែខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះថា យើងខ្ញុំបានកាត់បន្ថយពេលវេលាចាំបាច់ដូច្នេះយើងខ្ញុំគិតថា យើងត្រូវការតែមួយថ្ងៃកន្លះទេ សម្រាប់ការបង្ហាញឯកសារនេះគឺមិនត្រូវការ៣ថ្ងៃទៀតទេ។ ដូច្នេះយើងនឹងពិភាក្សាគ្នាដើម្បីកុំឲ្យមានឯកសារជាន់គ្នាដែលនឹងត្រូវបង្ហាញ។ ដូច្នេះពេលវេលាសរុបដែលយើងត្រូវការគឺ ១ថ្ងៃកន្លះ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការផ្តល់ព័ត៌មាននេះ។

សូមអញ្ជើញលោកចៅក្រមហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាអាចបញ្ជាក់បានទេថា តើខ្លួនបានរៀបចំបញ្ជីឯកសាររបស់ខ្លួនដែលចង់ដាក់នៅពេលសវនាការបង្ហាញហើយឬនៅ? ហើយតើភាគីទាំងពីរបានផ្លាស់ប្តូរបញ្ជីឲ្យគ្នាមើលទៅវិញទៅមកហើយឬនៅ? ដូច្នេះយើងខ្ញុំចង់ដឹងថា តើអស់លោក លោកស្រីទៅដល់ដំណាក់កាលរៀបចំនោះយ៉ាងម៉េចទៅហើយ?

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកចៅក្រមឡាវែន៍។ ដើម្បីជម្រាបឲ្យច្បាស់ជាងហ្នឹងបន្តិចការប៉ាន់ប្រមាណលើឯកសារគឺថាយើងត្រូវប្រើពេល៣ថ្ងៃ ប៉ុន្តែហ្នឹងដាក់បញ្ចូលតួនាទីរបស់ នួន ជា នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះសវនាការលើឯកសារហ្នឹងគឺទាក់ទងទៅលើសហឧក្រិដ្ឋកម្មសុទ្ធសាធ និងទាក់ទងទៅគឺថាយើងនឹងប្រើពេល២ថ្ងៃ។ រីឯស្ថានភាពនៃការត្រៀមរៀបចំវិញគឺថា យើងបានរៀបចំមួយចំនួនច្រើនហើយ។ រីឯបញ្ជីត្រឹមត្រូវនៃឯកសារនោះ ខ្ញុំសូមជម្រាបថាអាចនឹងមានជាងឯកសារបន្ថែមទៀតរហូតទៅដល់ថ្ងៃចន្ទ។ បន្ទាប់មក ឬក៏ល្ងាចនេះ នេះគឺជាការជំហានលឿននៃការរៀបចំរបស់យើង។ ហើយនៅពេលដែលយើងឈានដល់ណាយើងនឹងជម្រាបជូនដល់ភាគី។ ហើយខ្ញុំសូមជម្រាបថាអាច

ហ្នឹងជូនព័ត៌មានបានមួយចំនួនច្រើនទៀតបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ចំពោះពួកយើងខ្ញុំនោះ យើងខ្ញុំបានបញ្ជាក់ថា យើងខ្ញុំរក្សាសិទ្ធិបង្ហាញឯកសារចំពោះជនជាប់ចោទទាំងពីរ។ ដូច្នេះ រយៈពេលមួយថ្ងៃកន្លះហ្នឹង គឺសម្រាប់តួនាទីរបស់ជនជាប់ចោទ នយោបាយ ហើយនិងសហឧក្រិដ្ឋកម្មរួមក៏ប៉ុន្តែគោលនយោបាយទាំងប្រាំនោះ យើងមិនទាន់បានរៀបចំបញ្ចប់នៅឡើយទេ យើងខ្ញុំកំពុងតែស្ថិតនៅក្នុងដំណាក់កាលរៀបចំ។ យើងខ្ញុំគិតថាប្រហែលជាថ្ងៃចន្ទមិនទាន់ចប់ទេ។ ដូច្នេះយើងខ្ញុំព្យាយាមធ្វើយ៉ាងណាឲ្យចប់ក្នុងសប្ដាហ៍ក្រោយ ប៉ុន្តែត្រឹមថ្ងៃចន្ទនេះគឺមិនអាចចប់បានទេលោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណចំពោះព័ត៌មានទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកចៅក្រម។ បន្តមេធាវីការពារក្ដី នួន ជា បានគូសបញ្ជាក់ថាពួកគាត់ពុំមានបំណងបង្ហាញឯកសារសំខាន់ៗនៅក្នុងសវនាការនេះទេ។ ប៉ុន្តែបានស្នើសុំពេលវេលាអតិបរមាចំនួន១ថ្ងៃដើម្បីឆ្លើយតបទៅនឹងការបង្ហាញឯកសាររបស់ភាគីផ្សេងៗ។ នៅក្នុងសំណើរបស់ខ្លួនឯកសារ E263 មេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា សវនាការដេញដោលលើឯកសារសំខាន់ៗ រំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌នៅពេលដែលសវនាការទាំងនោះពុំមានចេតនាអនុញ្ញាតឲ្យមានការលើកឡើងទឡ្ហីករណ៍តទល់ទាក់ទងទៅនឹងឯកសារនានាដែលភាគីបានលើកបង្ហាញ និងដោយសារតែការប្រព្រឹត្តទៅតាមរបៀបខុសៗគ្នា ដែលត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងការធ្វើសវនាការទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្ដីលើកឡើងថាខ្លួនត្រូវតែទទួលបានឱកាសពិតប្រាកដមួយ ដើម្បីពិភាក្សាអំពីការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងជនជាប់ចោទ ហើយសវនាការបន្ថែមទៀត ស្ដីពីភាពអាចទទួលយកបាននៃឯកសារគួរតែត្រូវបានកំណត់កាលបរិច្ឆេទធ្វើផងដែរ។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានលើកឡើងផងដែរថា ឯកសារសំខាន់ៗដែលត្រូវបានបង្ហាញមកទាល់នឹងពេលនេះ គួរត្រូវបានពិនិត្យបន្ថែមទៀតទៅលើតម្លៃជាភស្តុតាង

ដើម្បីអនុញ្ញាតឲ្យមានការពិភាក្សាតទល់គ្នា ហើយគួរផ្តល់ឱកាសនៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីសវនាការ សម្រាប់ការវាយតម្លៃលម្អិតមួយអំពីភស្តុតាងនានាប្រឆាំងនឹងជនជាប់ចោទ។

[០៩:២១:០០]

អង្គជំនុំជម្រះធ្លាប់បានជម្រាបជូនភាគីតាំងពីដំបូងមកហើយថា អង្គជំនុំជម្រះនឹងធ្វើសវនាការនៃការបង្ហាញឯកសារសំខាន់ៗនៅពេលចុងបញ្ចប់នៃសវនាការនៅក្នុងវគ្គនីមួយៗ ពីព្រោះថាក្របខ័ណ្ឌគតិយុត្តិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានតម្រូវថា ឯកសារអាចដាក់បាននៅចំពោះមុខអង្គជំនុំជម្រះតែនៅពេលពិភាក្សាដេញដោលទៅលើសាក្សី ឬអ្នកជំនាញពាក់ព័ន្ធនោះឡើយ។ សវនាការទាំងនេះត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឲ្យភាគីគូសបញ្ជាក់នូវឯកសារទាំងឡាយណាដែលត្រូវបានភាគីយល់ថា ពាក់ព័ន្ធទៅនឹងវគ្គនៃការជំនុំជម្រះនីមួយៗ ដើម្បីជាប្រយោជន៍ដល់អង្គជំនុំជម្រះ។

អង្គជំនុំជម្រះធ្លាប់បានគូសបញ្ជាក់ថា គោលបំណងនៃសវនាការទាំងនេះ គឺដើម្បីធានាបានថា ទាំងភស្តុតាងដោះបន្ទុក ទាំងភស្តុតាងដាក់បន្ទុក ត្រូវបានលើកឡើងយ៉ាងសមស្របនៅចំពោះមុខអង្គជំនុំជម្រះ។

សវនាការទាំងនេះក៏អនុញ្ញាតឲ្យសាធារណជនអាចពិនិត្យមើលបានកាន់តែទូលំទូលាយនូវទិដ្ឋភាពទាំងឡាយនៃឯកសារនៃការជំនុំជម្រះនេះ ពីព្រោះសំណុំឯកសារនៃសំណុំរឿង០០២ មានច្រើនសន្លឹកសន្ធាប់ ហើយសាធារណជនទូទៅអាចពុំដឹងអំពីខ្លឹមសារនៃឯកសារសំខាន់ៗទាំងនេះ។ ដោយហេតុថា សវនាការដាច់ដោយឡែកពីគ្នាត្រូវបានធ្វើជាពិសេស ដើម្បីទុកលទ្ធភាពឲ្យមានការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារទាំងអស់ ដែលត្រូវបានដាក់នៅពេលសវនាការរួចហើយនោះ ការលើកទឡ្ហីករណ៍នានាពាក់ព័ន្ធនឹងភាពអាចទទួលយកបាន ពុំត្រូវបានអនុញ្ញាតឡើយក្នុងអំឡុងពេលសវនាការនៃការបង្ហាញឯកសារសំខាន់ៗទាំងនេះ។

[០៩:២៣:០២]

យ៉ាងណាមិញជនជាប់ចោទ ឬមេធាវីរបស់ពួកគាត់ពុំដែលត្រូវបានហាមឃាត់មិនឲ្យពិភាក្សាអំពីភាពពាក់ព័ន្ធ ឬតម្លៃជាភស្តុតាងនៃឯកសារសំខាន់ៗដែលត្រូវបានបង្ហាញនៅក្នុងអំឡុងពេលសវនាការនោះឡើយ។ យោងតាមការចោទប្រកាន់របស់មេធាវីការពារក្តី ខៀវ សំផន ដែលថាពួកគាត់ខ្វះឱកាសគ្រប់គ្រាន់សម្រាប់ការលើកទឡ្ហីករណ៍តទល់ទៅនឹងឯកសារទាំងនេះ អង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យមេធាវីការពារក្តី ខៀវ សំផន គូសបញ្ជាក់ក្នុងកិច្ចប្រជុំរៀបចំសវនាការនេះថា តើនៅពេលនេះពួក

លោកត្រូវការពេលវេលាប៉ុន្មានសម្រាប់គោលបំណងនេះ និងបញ្ជាក់អំពីឯកសារដែលពួកលោកមានបំណងជំទាស់ ឬធ្វើសេចក្ដីអត្ថាធិប្បាយបន្ថែម។ តើនាពេលនេះ មេធាវីការពារក្ដី ខៀវ សំផន អាចផ្ដល់នូវសេចក្ដីបញ្ជាក់ទាំងនេះបានដែរឬទេ?

សូមអញ្ជើញលោកមេធាវី អាកទួរ វែកគែន!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ គោលជំហររបស់មេធាវីការពារក្ដីលោក ខៀវ សំផន គឺថានៅតែដដែលពុំមានការប្រែប្រួលទេ។ ចំពោះយើង សវនាការនៃការបង្ហាញឯកសារគន្លឹះគឺថាវាមិនមានភាពពាក់ព័ន្ធទៅនឹងការជំនុំជម្រះក្ដីព្រហ្មទណ្ឌនោះទេ។ ខ្ញុំសូមផ្ដល់នូវសុភាសិតបារាំងមួយដែលថា “យើងដាក់រនង្គ័លនៅក្រោយគោ” គឺថាយើងត្រឡប់ប្រព័ន្ធធម្មតានៃការជំនុំជម្រះក្ដីដែលត្រូវតែពិនិត្យឯកសារមួយចំនួន ហើយនិងសក្ខីកម្មនៅក្នុងអំឡុងពេលសវនាការជាសាធារណៈ ដែលក្រោយពីសវនាការនោះ គឺគេផ្ដល់ឱកាសទៅឲ្យភាគីផ្សេងៗទៀតក្នុងការផ្លាស់ប្ដូរសារណាជាលាយលក្ខណ៍អក្សរគ្នាទៅវិញទៅមក ដែលក្នុងនោះគឺថាមានការវិភាគទៅលើឯកសារដែលពិនិត្យនៅក្នុងសវនាការ។ នេះជាទម្លាប់ដែលធ្វើនៅព្រហ្មទណ្ឌដទៃទៀត។ ហើយបន្ទាប់មកផ្ដល់ឱកាសក្នុងការឆ្លើយតបជាលាយលក្ខណ៍អក្សរ ហើយប្រសិនជាមិនអាចធ្វើជាលាយលក្ខណ៍អក្សរបានទេ គឺថាធ្វើដោយផ្ទាល់មាត់។ ចំពោះយើងដំណើរការធម្មតានៃការសវនាការ គឺរបៀបហ្នឹងឯង។ ក៏ប៉ុន្តែការបង្ហាញឯកសារគន្លឹះនោះ គឺថាបានប្រព្រឹត្តទៅបីដងហើយ គឺថាមានការប្រែប្រួលរហូតក្នុងការរៀបចំនោះ។

[០៩:២៥:៥៥]

ជាដំបូង អង្គជំនុំជម្រះបានប្រកាសថា គឺក្នុងសវនាការហ្នឹង គ្រាន់តែបង្ហាញឯកសារជូនទៅដល់សាធារណជន ជូនទៅដល់សារព័ត៌មាន។ យើងបានជំទាស់តវ៉ាថាយើងខ្ញុំមិនមែនជាអ្នកកាសែតទេ យើងមិនធ្វើការផ្សាយពាណិជ្ជកម្មអីទេ។ យើងដឹងហើយថាសាធារណជនត្រូវដឹងអំពីអ្វីដែលយើងនិយាយនៅក្នុងសវនាការជាទូទៅ គឺអ៊ីចឹង។ ហើយនៅពេលដែលយើងរក្សារបៀបដូចដែលយើងធ្វើដូចរាល់ថ្ងៃនេះ គោលជំហររបស់មេធាវីការពារក្ដីរបស់លោក ខៀវ សំផន នោះ កត់សម្គាល់ឃើញថា នៅពេលដែលមានសវនាការបង្ហាញឯកសារគន្លឹះបែបនោះ នៅពេលចុងក្រោយនៃសវនាការនោះ យើងស្ថិតនៅក្នុងស្ថានភាពមួយដែលថា គេផ្ដល់ឱកាសឲ្យយើងគ្រាន់តែធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ត្រឹមតែ១០០ទំព័រ ដែល

មានធ្វើការសវនាការអស់ពេលប្រហែលជាជិត២ឆ្នាំមកហើយ ហើយរហូតមកថ្ងៃនេះ គឺថា៣៦សាក្សីមកហើយ ដែលយើងបានស្តាប់ ហើយនិងមានឯកសាររាប់ពាន់រាប់ម៉ឺនដែលត្រូវពិភាក្សា ហើយយើងត្រូវធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលរបស់យើងត្រឹមតែ១០០ទំព័រ។ ដូច្នេះប៉ុនណេះវាមិនគ្រប់គ្រាន់នោះទេ គឺថាវាតិចតួចណាស់ប៉ុននេះនោះ ១០០ទំព័រ យើងមិនអាចធ្វើបានទេ។

[០៩:២៧:២៧]

បន្ទាប់មកគេ យើងឃើញថា យើងមានការវិវត្តទៅមុខ ហើយនៅក្នុងការកំណត់ដែលមានបញ្ជាក់នៅក្នុងអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នោះ ខ្ញុំគិតថាគឺនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះ គឺថាការធ្វើការពិភាក្សាដេញដោលផ្ទាល់មាត់នោះ ត្រូវធ្វើឲ្យខ្លី គឺថាសង្ខេបចេញពីសេចក្តីសន្និដ្ឋានបញ្ចប់១០០ទំព័ររបស់យើង។ ដូច្នេះជំហររបស់យើង គឺនៅតែដដែល មិនមានការផ្លាស់ប្តូរទេ យើងកត់សម្គាល់ឃើញថា សវនាការនេះពីដំបូងឡើង គឺប្រកាស គឺថាដូចជារបៀបជាការអប់រំមួយអ៊ីចឹង ហើយបន្ទាប់មកមានការប្រែប្រួល មានការបំប្លែងមួយដើម្បីឲ្យអង្គជំនុំជម្រះកាត់បន្ថយ រឹតត្បិតលទ្ធភាពក្នុងការការពារខ្លួនរបស់លោក ខៀវ សំផន។ គឺថាត្រឹមកំណត់មកត្រឹមតែឲ្យ១០០ទំព័រ ហើយឲ្យឡើងមកជជែកតវ៉ាត្រឹមតែប៉ុន្មានម៉ោងតែប៉ុនណោះ។ ដូច្នេះ ជាការរំលោភសិទ្ធិធ្ងន់ធ្ងរទៅលើសិទ្ធិរបស់យើងខ្ញុំក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងចំពោះមុខ។ ហេតុហ្នឹងហើយបានជាយើងបដិសេធមិនចង់រួម នៅក្នុងសវនាការបង្ហាញឯកសារបែបនេះ ដែលដូចជាអន្ទាក់អ៊ីចឹង ដូចជាអន្ទាក់ដាក់មេធាវីការពារក្តីយើងអ៊ីចឹង។ ដូច្នេះហើយនេះជាជំហររបស់ពួកយើង។

[០៩:២៩:២១]

ចំពោះយើង យើងស្នើសុំឲ្យនៅពេលដែលចប់សវនាការ ចប់ការជំនុំជម្រះក្តីនោះ គឺថាធ្វើឲ្យដូចជាសវនាការធម្មតា ដូចថាឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ឲ្យយើងរៀបចំសារណា រៀបចំកិច្ចប្រជុំពិភាក្សាដេញដោលបញ្ចប់នោះ។ ឲ្យយើងមាន -- ទុកពេលឲ្យយើងវិភាគទៅលើឯកសារទាំងអស់វិភាគទៅលើសក្ខីកម្មរបស់សាក្សី ហើយនិងក៏ទុកពេលឲ្យយើងឆ្លើយតបទៅនឹងភាគីបដិបក្ខ យើងមិនចង់ប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះទេ។ អ្វីដែលយើងចង់បាននោះគឺថា គឺដំណើរការនីតិវិធីយុត្តិធម៌ធម្មតា ដូចនៅតុលាការព្រហ្មទណ្ឌដទៃទៀត។

ដូច្នេះយើងភ្ជាប់កិច្ចពិភាក្សាយើងនេះទៅនឹងភាពមិនច្បាស់លាស់ គឺថាមិនមានភាពច្បាស់លាស់ទេពាក់ព័ន្ធទៅនឹងភស្តុតាង។ យើងបានដាក់សំណើ ដាក់ពាក្យសុំជាច្រើនពាក់ព័ន្ធទៅនឹងឯកសារដែល

មានលេខកូដ E3 ពីព្រោះថាប្រព័ន្ធនៃការដាក់លេខកូដ E3 ទៅលើឯកសារដែលបង្ហាញនៅក្នុងសវនាការនេះ គឺថាវាមានបញ្ហាជាច្រើន ហើយបន្ទាប់មកមានការវិវត្តទៅទៀត។ ដូច្នេះខ្ញុំមិនចង់និយាយដដែលៗដូចដែលខ្ញុំសរសេរនៅក្នុងសំណើរបស់យើងទេ។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះមេធាវី ដូចជាឆ្ងាយពីអ្វីដែលអង្គជំនុំជម្រះចង់បាន។ បញ្ហាដែលលោកលើកឡើងអម្បាញ់មិញនេះនឹងមានការពិភាក្សានៅលំដាប់ក្រោយទៀត អំពីអ្វីដែលលោកមេធាវីបានលើកឡើង អំពីឯកសារ E3 អំពីពេលម៉ោងសម្រាប់រៀបចំនៅសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល មិនទាន់ពេលទេ។ អំមិញគឺអង្គជំនុំជម្រះបានជម្រាបអំពីបញ្ហាដែលលោកបានស្នើសុំ ហើយអង្គជំនុំជម្រះបានសួរលោកថាសុំឱ្យលោកគូសបញ្ជាក់នៅក្នុងកិច្ចប្រជុំនេះ ថាតើក្រុមលោកនោះត្រូវការពេលវេលាប៉ុន្មានសម្រាប់គោលបំណងនេះ ហើយនិងការបញ្ជាក់អំពីឯកសារដែលលោកមានបំណងជំទាស់ ឬក៏ធ្វើអត្ថាធិប្បាយបន្ថែម។ នេះជាបញ្ហាដែលអង្គជំនុំជម្រះសូមឱ្យលោកផ្តល់ឱកាសឱ្យលោកលើកឡើងបញ្ហានេះនាពេលនេះ។ ចំណែកឯបញ្ហាដែលលើកឡើងទូលំទូលាយនេះ គឺវាមាន វាអាចពាក់ព័ន្ធទៅនឹងអង្គជំនុំជម្រះដែលបានកំណត់បញ្ហានេះតាមលំដាប់ក្រោយទៀតនៅក្នុងកិច្ចប្រជុំនេះ។

[០៩:៣១:៤៦]

ប្រសិនបើយើងលើកទូលំទូលាយហ្នឹងអាចលើកដដែល ឬក៏លើកពីរដង ឬក៏មានន័យថាយើងលើកក្តាប់នូវបញ្ហាប្រធានបទដែលដាក់ជជែកពិភាក្សានានាពេលនេះអត់បានទេ។ សូមលោកតម្រង់ និងបញ្ហានេះ ហើយឆ្លើយតបទៅនឹងសំណួរដែលអង្គជំនុំជម្រះចង់ដឹងអំពីការគិតគូរ អំពីតម្រូវការរបស់ក្រុមរបស់លោកលើបញ្ហានេះ។

**លោក អាកទ្បូ វែកគែន៖**

ក៏ប៉ុន្តែអ្វីដែលខ្ញុំនិយាយនេះមានពាក់ព័ន្ធលោកប្រធាន។ ដូច្នេះហើយ យើងពិបាកណាស់ក្នុងការបែងចែកឱ្យដាច់ពីគ្នានោះ។ អ្វីៗមានភាពពាក់ព័ន្ធគ្នា ហើយមិនអាចកាត់ផ្តាច់ចំណុចនេះមួយ ចំណុចនេះមួយថាវាមិនពាក់ព័ន្ធទេ គឺថាវាពាក់ព័ន្ធទាំងស្រុង។ ដូចថាម៉ាស៊ីនមួយអ៊ីចឹង បើសិនជាលោកប្រធានដកកាប៊ុយរ៉ាទ័រចេញ ម៉ាស៊ីនហ្នឹងវាអត់ដើរទេ--

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែយ៉ាងតិចបំផុត ក៏លោកមិនទាន់បានឆ្លើយតបនឹងអ្វីដែលលោកបានធ្វើការ ធ្វើសំណើសុំ

ហើយអង្គជំនុំជម្រះបានលើកឡើងនូវបញ្ហារបស់លោកដោយឡែកនេះ ដើម្បីរកដំណោះស្រាយ ដើម្បីស្តាប់នូវមតិយោបល់របស់លោក និងគោលបំណងរបស់លោកដែលលោកដាក់សំណើសុំនោះ មានលក្ខណៈដាច់ដោយឡែក។

[០៩:៣៣:០៣]

**លោក អាកខួរ វ៉េកកែន៖**

ចំពោះយើងខ្ញុំ យើងចង់រិះគន់ទៅលើភស្តុតាងទាំងអស់ដែលបានបង្ហាញនៅក្នុងសវនាការនេះ នៅក្នុងពេលដែលយើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល ហើយនិងការសន្និដ្ឋានដោយផ្ទាល់មាត់នោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាលោកប្រធាននិយាយត្រូវហើយ យើងកុំធ្វើឲ្យមានបញ្ហាច្របូកច្របល់គ្នា។ វាមានបញ្ហាផ្សេងដាច់ដោយឡែកពីគ្នា កុំយកបញ្ហាទាំងអស់មកច្របល់ចូលគ្នា។ មានការរិះគន់ពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារគន្លឹះដោយភាគីនៅក្នុងសវនាការយើង។ ហើយនិងមានការជំទាស់តវ៉ាដែលលើកឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន ដែលគាត់បានរអ៊ូរទាំថាមិនមានឱកាសគ្រប់គ្រាន់ក្នុងការពិភាក្សាដេញដោលតទល់ទៅលើឯកសារដែលបង្ហាញជូន។ សំណួរដែលយើងអាចចោទសួរទៅខាងមេធាវីការពារក្តីលោក ខៀវ សំផន នោះគឺថា តើលោកអាចបង្ហាញឲ្យបានច្បាស់ទេថា ឯកសារណាខ្លះដែលលោកចង់ជំទាស់? ហើយតើខាងលោកអាចបញ្ជាក់បានទេថាលោកត្រូវការពេលវេលាចាំបាច់ប៉ុន្មានដើម្បីជំទាស់តវ៉ាទៅលើឯកសារដែលបានបង្ហាញនោះ? អង្គជំនុំជម្រះមិនចង់សួរថា លោករក្សាសិទ្ធិក្នុងការធ្វើបែបនេះនៅក្នុងពេលសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលអីនោះទេ។ យើងដឹងហើយថា យើងមានការកម្រិតអាចចំនួនទំព័រនោះ សម្រាប់ភាគីទាំងអស់ មិនមែនតែសម្រាប់តែភាគីលោកទេ ហើយក៏មានពេលវេលាកម្រិតទាំងអស់សម្រាប់ភាគី សម្រាប់ការបង្ហាញការពិភាក្សាដេញដោលចុងក្រោយនោះ។ ដូច្នេះសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ ថាលោកដល់ណាហើយ។ សំណួរហ្នឹងមិនស្មុគស្មាញទេ គឺថាចំពោះលោកខ្លួនឯងផ្ទាល់ហ្នឹងលោកមានឯកសារគន្លឹះក្នុងការបង្ហាញដែរឬទេ?

**លោក អាកទ្វូរ វែកកែន៖**

ខ្ញុំនៅតែរក្សាជំហររបស់ខ្ញុំដដែល ខ្ញុំមិនចង់ត្រឡប់មកក្រោយពាក់ព័ន្ធទៅនឹងគោលបំណងរបស់តុលាការដែលកំណត់ចំពោះយើងនោះទេ។ យើងមើលជាលក្ខណៈទូទៅថាសវនាការបង្ហាញឯកសារនោះគឺដំបូងសម្រាប់តែបង្ហាញជូនសាធារណជនសម្រាប់បង្ហាញជាលក្ខណៈអប់រំ។ ឥឡូវហ្នឹងវាប្រែក្លាយទៅជាសវនាការលើអង្គសេចក្តីទៅហើយ។ ដូច្នេះហើយវាមិនមែនជារឿងធម្មតាទេ។ ដូច្នេះយើងគិតថា ពេលដែលយើងនឹងឆ្លើយតបទៅនឹងទឡ្ហីករណ៍ហើយនិងភស្តុតាង ហើយនិងសក្ខីកម្មទាំងអស់ដែលនៅចំពោះមុខអង្គជំនុំជម្រះនោះគឺថា នៅពេលដែលយើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ចុងក្រោយជាលាយលក្ខណ៍អក្សរនិងដោយផ្ទាល់មាត់។ ដូច្នេះសវនាការបែបនេះមិនគួរមានទេ។ ហើយការដែលធ្វើលើកឡើងដោយការធ្វើបែបនេះ ការកម្រិតពេលវេលា ការកម្រិតចំនួនទំព័រ នេះជាការរំលោភទៅលើសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថាសិទ្ធិរបស់គាត់នោះ គាត់មានសិទ្ធិក្នុងការពិនិត្យទៅមើលភស្តុតាងដែលបង្ហាញនៅក្នុងសវនាការ។ យើងផ្តល់ឱកាសឲ្យលោកហើយ។ លោកមិនមែនជាអ្នកដឹកនាំនីតិវិធី។ លោកមិនមែនជាកំណត់វិធានទេ គឺអង្គជំនុំជម្រះ។ អ៊ីចឹងយើងផ្តល់ឱកាសឲ្យលោកក្នុងការពិភាក្សាទៅលើឯកសារក្នុងការជំទាស់ទៅលើឯកសារដែលគេបង្ហាញ។ ប៉ុន្តែយើងកត់ -- អង្គជំនុំជម្រះកំណត់ថាលោកមិនចង់ប្រើសិទ្ធិនេះទេអ៊ីចឹងនោះ។

**លោក អាកទ្វូរ វែកកែន៖**

ខ្ញុំគិតថាការ -- យើងអត់មានទស្សនៈយល់ឃើញដូចគ្នាទេលោកចៅក្រម។ ខ្ញុំគឺមានទស្សនៈជាលក្ខណៈទូទៅ ហើយលោកចៅក្រមនោះលោកនៅតែចចេសចង់នាំឲ្យខ្ញុំគិតថាឯកសារសវនាការទៅលើសវនាការគន្លឹះហ្នឹងគឺជាពេលសំខាន់។ ចំពោះខ្ញុំ ខ្ញុំគិតថាមិនមែនជាការជំនុំជម្រះនៅសាលសវនាការបង្ហាញឯកសារបែបនេះនោះ។ នៅពេលដែលយើងជិតមកដល់ពេលចប់ទៅហើយនោះ គឺថាកាន់តែមានបញ្ហា។ យើងមានសវនាការបីដងមកហើយនៅលើឯកសារគន្លឹះនោះ។ ហើយនៅពេលសវនាការយើងអត់មានការជជែកដេញដោលពិភាក្សាគ្នាទេ គឺថាគេបញ្ជាក់ថាភាគីអត់អាចឆ្លើយតបទេ។ ហើយឥឡូវយើងគិតថា ដូចថា ធ្វើដូចដឹងថាមិនមានអីកើតឡើងអ៊ីចឹង។ ហើយចំពោះសវនាការចុងក្រោយនោះគឺថាយើងត្រូវតែចូលរួម ហើយយើងត្រូវតែឆ្លើយតបឯកសារដែលបង្ហាញ។ ខ្ញុំគិតថាភាពសម

ហេតុផលនៃតុលាការនោះគឺថា គឺជាសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ និងជាផ្ទាល់មាត់ឯណោះទេដែលសំខាន់នោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមានការកត់សម្គាល់ធម្មតាមួយ។ លោកមិនមែនមានតែជាក្រុមការពារក្តីតែមួយទេ យើងមានក្រុមការពារក្តីមួយទៀត។ លោកត្រូវតែកត់សម្គាល់ផងដែរថា ខាងភាគីការពារក្តីផ្សេងនោះបានចូលរួមហើយក៏បានបង្ហាញការជំទាស់ទៅលើឯកសារផងដែរ មិនមែនមានតែក្រុមលោកទេ។ ខ្ញុំសូមអាននូវប្រសាសន៍របស់លោកប្រធាននៅឆ្នាំ២០១២ នៅក្នុងសវនាការនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ពាក់ព័ន្ធទៅនឹងសវនាការនៃឯកសារគន្លឹះ។ នេះគឺជាសម្តីរបស់លោកប្រធាន "យើងមិនអាចពិនិត្យទៅលើតម្លៃនិងភស្តុតាងនៃឯការនោះទេ។ ភាគីមិនមានសិទ្ធិវាស់ទៅលើទម្ងន់និងតម្លៃជាភស្តុតាងទេ ព្រោះយើងមិនទាន់ដែលពេលបញ្ចប់សវនាការនៅឡើយនោះទេ។ ភាគីត្រូវតែកម្រិត ត្រឹមតែនិយាយភាពពាក់ព័ន្ធជាក់លាក់នៃឯកសារទាំងអស់នោះ ពីព្រោះថាការវាយតម្លៃភាពជាភស្តុតាងនោះ គឺថានៅពេលក្រោយឯណោះទេ"។ នេះគឺជាការប្រកាសរបស់លោកប្រធាន។ គឺថាដំបូងឡើយ គឺថាសវនាការលើឯកសារគន្លឹះនេះគ្រាន់តែជាសវនាការមានគោលបំណងអប់រំណែនាំឲ្យយើងដឹងតែប៉ុណ្ណោះ។ ហើយនៅពេលសវនាការដំបូងគឺថា មេធាវីការពារក្តីអត់ឲ្យនិយាយទេ កាលពីដំបូងកំណត់មកអ៊ីចឹងថាឲ្យតែជនជាប់ចោទទេ ឆ្លើយតបទៅនឹងឯកសារនោះ។ ហើយពេលនោះគឺថា នួន ជា ចង់នៅក្នុងបន្ទប់ឃុំឃាំង តែអង្គជំនុំជម្រះបង្ខំគាត់ឲ្យមកទីហ្នឹងទៀត ឲ្យគាត់នឹងមានឱកាសក្នុងការឆ្លើយតបទៅនឹងឯកសារ នៅពេលនោះថាអត់ឲ្យមេធាវីឆ្លើយតបទេ ឲ្យតែជនជាប់ចោទ។ ដូច្នេះខ្ញុំចាំច្បាស់ណាស់ពេលនុ៎ងនោះ។ ដូច្នេះចំពោះអស់លោក លោកស្រីនោះគឺថា វាមិនមែនទេ ក៏ប៉ុន្តែចំពោះយើងខ្ញុំនឹងគឺថាការធ្វើបែបហ្នឹងគឺវាមិនត្រឹមត្រូវទេ *(គ្មានការបកប្រែ)*--

**ប្រធានអង្គជំនុំ៖**

បានហើយ។ សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ។ ខ្ញុំសូមលើកឡើងថា យើងមានការច្របូកច្របល់កម្រិតខ្លះដែរទាក់ទងទៅនឹងសវនាការលើឯកសារគន្លឹះ។ ដូច្នេះថាតើអង្គជំនុំជម្រះអាចបញ្ជាក់បានដែរឬទេ ថាតើយើងត្រូវធ្វើការជំទាស់ទៅលើឯកសារជាគន្លឹះតែទៅលើភាពអាចទទួលយកបាន ឬ

ក៏អាចជំទាស់ផងដែរទៅលើតម្លៃនៃភស្តុតាងនៃឯកសារទាំងអស់នោះ។

[០៩:៤១:០៧]

គឺបានន័យថា យើងមិនត្រឹមតែគិតទៅលើតម្លៃភស្តុតាងនោះទេ។ ចំពោះចំណុចទី១ គឺអត់មានបញ្ហាទេយើងយល់អំពីការបង្ហាញឯកសារជាគន្លឹះ ដើម្បីជួយដល់ភាគីនានា គឺបានន័យថាទាំងភាគី ទាំងអស់ជំនុំជម្រះ ទាំងសាធារណជនឲ្យដឹង។ ប៉ុន្តែឥឡូវនេះ យើងក៏អាច -- ហាក់ដូចជាអាចបញ្ចេញមតិយោបល់ទៅលើតម្លៃនៃភស្តុតាងរបស់ឯកសារគន្លឹះផងដែរ។ ដូច្នេះហើយខ្ញុំមើលទៅឃើញថាវាហាក់ដូចជាមានការច្របូកច្របល់ ឬក៏មានការរញ៉េរញ៉ៃ។ ដូច្នេះប្រសិនបើអង្គជំនុំជម្រះអាចផ្តល់នូវការបញ្ជាក់បំភ្លឺអំពីស្ថានភាពនៃការជំទាស់ទៅលើឯកសារគន្លឹះដែលដាក់ដោយព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីឬក៏អត់? តើវាមានលក្ខណៈយ៉ាងដូចម្តេចដែរ?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៤:០១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌ ដើម្បីឆ្លើយបំភ្លឺចំពោះការលើកឡើងពីសំណាក់មេធាវីការពារក្តីនូវបញ្ហាចុងក្រោយអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

ពាក្យថា "ឯកសារគន្លឹះ" គឺត្រូវបានប្រើប្រាស់តាំងពីមុនរហូតមកដល់ឥឡូវ ដែលអង្គជំនុំជម្រះដោយយោងទៅលើឯកសារដែលភាគីនីមួយៗពិចារណាយល់ឃើញថា វាមានលក្ខណៈសំខាន់ចំពោះរឿងក្តីរបស់ខ្លួន។ ដូច្នេះហើយខាងព្រះរាជអាជ្ញា ដើម្បីធ្វើការវាយតម្លៃ និងដើម្បីបង្ហាញភស្តុតាង ក៏ដូចគ្នានឹងខាងមេធាវីការពារក្តីផងដែរ គឺត្រូវធ្វើនូវដូចគ្នា។ ហេតុដូច្នេះហើយ គឺយើងផ្តល់នូវឱកាសដល់ភាគីនីមួយៗដើម្បីបង្ហាញនូវឯកសារដែលភាគីទាំងអស់យល់ឃើញថាសំខាន់ចំពោះរឿងក្តីរបស់ខ្លួន ហើយយើងក៏ផ្តល់ឱកាសដល់ភាគីនានា ភាគីដទៃទៀត ដើម្បីបញ្ចេញមតិយោបល់ទៅលើឯកសារទាំងអស់នោះ។ ហើយភាគីអាចបញ្ចេញមតិយោបល់ទៅលើឯកសារ លើកលែងតែភាពអាចទទួលយកបានដែលភាពអាចទទួលយកបានហ្នឹងត្រូវបានសម្រេចនៅពេលក្រោយ។ ហេតុដូច្នេះហើយ វាជាឆន្ទានុសិទ្ធិរបស់ភាគីនានានៅក្នុងការបញ្ចេញមតិយោបល់។ ឧទាហរណ៍ថា បញ្ចេញមតិយោបល់ទៅលើតម្លៃនៃ

ភស្តុតាង ឬក៏និយាយយោងទៅលើឯកសារដទៃទៀត ដែលអាចដាក់នូវភាពអាចជឿទុកចិត្តបានទៅលើឯកសារដែលខ្លួនកំពុងតែលើកយកមកពិភាក្សាក្នុងពេលសវនាការ។ នៅពេលដែលមានការនិយាយយោងទៅលើឯកសារណាមួយ ភាគីនានាមានមតិយោបល់អាចលើកឡើងមានសិទ្ធិបញ្ចេញមតិយោបល់ទៅលើឯកសារទាំងអស់នោះ។

[០៩:៤៦:០២]

ដូច្នេះបញ្ហាដែលមិនត្រូវបានពិភាក្សានៅក្នុងសវនាការលើកឯកសារគន្លឹះ គឺមានតែបញ្ហាភាពអាចទទួលយកបានតែប៉ុណ្ណោះដែលមិនបានពិភាក្សា។ ដូច្នេះខ្ញុំសូមសង្ឃឹមថាភាគីទាំងអស់គ្នានឹងយល់ច្បាស់អំពីបញ្ហានេះ។ ហើយប្រហែលជាខ្ញុំអាចសួរមួយសាទៀត ថាតើមេធាវីការពារក្តី ខៀវ សំផន ចង់បង្ហាញឯកសារគន្លឹះណាទៀត ឬមួយក៏គាត់ចង់ទទួលបានឱកាសក្នុងការបញ្ចេញមតិយោបល់ទៅលើឯកសារគន្លឹះដែលបង្ហាញដោយភាគីដទៃទៀត? តើយ៉ាងដូចម្តេចដែរ?

**លោក អាកទួរ វែកគែន៖**

គោលជំហររបស់មេធាវីការពារក្តីលោក ខៀវ សំផន នោះគឺថាអ្វីដែលលោកស្រីទើបតែមានប្រសាសន៍អម្បាញ់មិញនេះ គឺថាវាផ្ទុយគ្នាទៅនឹងអ្វីដែលបានប្រកាសតាំងពីដំបូងពាក់ព័ន្ធទៅនឹងប្រធានបទនៃសវនាការលើកឯកសារគន្លឹះ ហើយយើងក៏បានដាក់សំណើសុំមួយដែរ ដែលមានលេខ -- លោកស្រីចៅក្រម! សូមចាំសិន ឲ្យខ្ញុំបញ្ចប់សិនកុំអាលកាត់ខ្ញុំ លោកស្រីចៅក្រមៗ--

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោក វែកគែន ខ្ញុំគ្រាន់តែចង់ដឹងថា តើលោកចង់ធ្វើបែបហ្នឹង ឬក៏អត់?

**លោក អាកទួរ វែកគែន៖**

បាទយើងសូមបដិសេធមិនចូលរួមនៅក្នុងសវនាការណាដែលរំលោភសិទ្ធិជាសារវន្តរបស់យើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅទៀត សហព្រះរាជអាជ្ញាបានបង្ហាញចេតនាឆ្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន ឯកសារ E263។ ឥឡូវនេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាឆ្លើយតប ដោយសង្ខេបផ្ទាល់មាត់ទៅនឹងសំណើនេះ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ចៅក្រម ឡាវែន៍ ហើយនិងចៅក្រម ខាតវ៉ាយថ៍ ប្រហែល

ជាលើកឡើងនៅចំណុចមួយចំនួនដែលព្រះរាជអាជ្ញាចង់លើកឡើងរួចមកហើយទាក់ទងទៅនឹងឯកសារ E263 នេះ។ ពាក់ព័ន្ធទៅនឹងអ្វីដែលសហភាគាខ្ញុំបានបញ្ជាក់កាលពីព្រឹកនេះ គឺពាក់ព័ន្ធទៅនឹងសវនាការលើឯកសារដែលថា បានរំលោភទៅលើសិទ្ធិជាសារវន្តរបស់ជនជាប់ចោទនោះ ដូចដែលលោក លោកស្រីចៅក្រមដឹងហើយ គឺថាលក្ខន្តិកៈ៣៥ថ្មី នៅក្នុងមាត្រា៣៥(ថ្មី) បាននិយាយជាពិសេស ហើយប្រហែលជាមេធាវីការពារក្តី គាត់ចង់និយាយលើកអំពីការពិនិត្យទៅលើឯកសារ ក៏ដូចជាការបង្ហាញអំពីការត្រួតពិនិត្យឯកសារទៅលើ -- ត្រួតពិនិត្យទៅលើឯកសារ ដោយផ្អែកទៅលើលក្ខខណ្ឌតែមួយ គឺថាឯកសារដែលមានស្រាប់។

[០៩:៤៩:០៦]

លោក លោកស្រីចៅក្រម នៅក្នុងករណីនេះ គឺជាការឆ្លើយតបជាទូទៅមួយ ការស្តាប់ឯកសាររបស់សាក្សី គឺថាមេធាវីការពារក្តីមានសិទ្ធិសួរដេញដោល ហើយអង្គជំនុំជម្រះតាមដែលខ្ញុំយល់ គឺថាមានសវនាការលើកឯកសារដែលមានរយៈពេលយ៉ាងសមស្របមួយ ហើយដូចដែលចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់អំពីចឹងភាពអាចទទួលយកបានហ្នឹង គឺលក្ខណៈពិសេសមួយផ្សេងខុសពីសវនាការដេញដោលលើឯកសារ។ ចំពោះភាពដែលអាចទទួលយកបាននៃឯកសារ គឺថាភាគីទាំងអស់អាចដាក់ឯកសារជូនទៅអង្គជំនុំជម្រះដែលខ្លួនចង់ដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ហើយគ្រប់ភាគីទាំងអស់រួមបញ្ចូលទាំងមេធាវីការពារក្តី ខៀវ សំផន អាចមានឱកាសឆ្លើយតបទៅនឹងភាពអាចទទួលយកបាននៃឯកសារទាំងអស់នោះ ដែលយើងធ្វើក្នុងរយៈពេលយ៉ាងយូរដោយភាគីនានា។ ទាំងអស់នេះគឺពាក់ព័ន្ធទៅនឹងឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ នៅពេលដែលមេធាវី ខៀវ សំផន បានបញ្ជាក់ថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានរំលោភដោយសារតែមិនមានលទ្ធភាពក្នុងការជំទាស់ទៅលើឯកសារ គឺថាយើងសូមបញ្ជាក់ថា គ្រប់ភាគីទាំងអស់មានសិទ្ធិទទួលបាននៅក្នុងសវនាការលើភាពដែលអាចទទួលយកបាននៃឯកសារ ហើយមានសិទ្ធិជំទាស់ទៅលើភាពអាចទទួលយកនៃឯកសារ ហើយនៅពេលនុ៎ង ក៏មាននិយាយអំពីតម្លៃនៃភស្តុតាង ហើយក៏មានការលើកឡើងផងដែរនៅក្នុងសវនាការលើភាពអាចទទួលយកបាន។ ចំពោះមេធាវីការពារក្តី ខៀវ សំផន គឺបាននិយាយខុសដែលថាខ្លួនមិនមានឱកាសនៅក្នុងការជំទាស់ទៅលើឯកសារទាំងអស់នេះ។

[០៩:៥០:៥២]

ទាក់ទងទៅនឹងសវនាការលើឯកសារជាគន្លឹះ គឺថាចៅក្រម ខាតវ៉ាយថ៍ បាននិយាយរួចមក

ហើយថាសវនាការនេះគឺមានគោលដៅផ្សេង។ សវនាការទាំងអស់នោះ គឺធ្វើការលើកឡើងនូវឯកសារដដែល ដែលយើងបានធ្វើនៅក្នុងសវនាការលើភាពអាចទទួលយកបាននៃឯកសារនោះ។ ប៉ុន្តែគឺថាមានគោលការណ៍ ឬក៏មានគោលចំណុចសំខាន់ពីរដូចដែលចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់អំពីចឹង គឺថាសវនាការលើឯកសារជាគន្លឹះគឺដើម្បីបង្ហាញថាសវនាការហ្នឹងវាមានតម្លាភាព ហើយវាក៏សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទផងដែរ។

សវនាការលើឯកសារជាគន្លឹះដើម្បីឲ្យសាធារណជនបានដឹង ថាតើអង្គជំនុំជម្រះពិនិត្យទៅលើឯកសារអ្វីខ្លះ? ហើយវាមិនមែនជាការរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទនោះឡើយ។ វាពិបាកក្នុងការយល់ណាស់ ដែលគេនិយាយដូច្នេះ។ បើសិនជាសវនាការធ្វើជាអសាធារណៈ ហើយមិនបានបង្ហាញចំពោះសាធារណជន ពេលហ្នឹង គឺមេធាវី ខៀវ សំផន អាចនឹងលើកតវ៉ាថា នេះមិនមែនជាសវនាការរបស់សាធារណៈនោះទេ។

[០៩:៥១:៥៥]

ចំណុចមួយទៀតនៃសវនាការលើឯកសារ។ ដូចដែលលោកចៅក្រមបានបញ្ជាក់រួចមកហើយ គឺថាដើម្បីឲ្យភាគីនានាបានបញ្ជាក់នូវឯកសារជាគន្លឹះជូនដល់អង្គជំនុំជម្រះ ដើម្បីឲ្យអង្គជំនុំជម្រះអាចធ្វើការពិចារណា។ គ្រប់ភាគីទាំងអស់ រួមទាំងមេធាវីការពារក្ដី ខៀវ សំផន គឺទទួលបានឱកាសដូចគ្នានឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី, មេធាវី អៀង សារី, មេធាវី ខៀវ សំផន, មេធាវី នួន ជា និងព្រះរាជអាជ្ញាផង គឺថាខ្លួនអាចលើកយកមកបង្ហាញនូវឯកសារដែលខ្លួនមាន។ ប៉ុន្តែប្រសិនជាមេធាវី ខៀវ សំផន មិនចង់ប្រើប្រាស់សិទ្ធិហ្នឹងទេ អាហ្នឹងជាបញ្ហារបស់ពួកគេ។ ដូច្នេះ គេមិនអាចនិយាយថាខ្លួនមិនប្រើប្រាស់សិទ្ធិហើយ វាជាការរំលោភទៅលើសិទ្ធិរបស់ខ្លួននោះទេ។

នៅក្នុងសវនាការលើឯកសារ ជាពិសេសគឺសវនាការដំបូងៗ គឺអ្វីដែលយើងបានធ្វើកន្លងមក គឺលោក -- គឺអង្គជំនុំជម្រះបានបញ្ជាក់ថា មេធាវីអាចបញ្ជាក់ទៅលើឯកសារទាំងអស់នោះបាន។ ប៉ុន្តែវាអាចមានភាពមិនច្បាស់លាស់មួយដែលថាមេធាវីការពារក្ដីអាចបញ្ចេញមតិយោបល់អំពីតម្លៃនៃភស្តុតាង ឬក៏អត់នៅពេលនោះ។ ប៉ុន្តែផ្ទុយទៅនឹងអ្វីដែលសហភាតារបស់ខ្ញុំបានលើកឡើង គឺផ្ទុយពីអ្វីដែលលោក វែកគែន បាននិយាយ ដែលថានៅក្នុងសវនាការលើឯកសារទាំងអស់ មិនមានឱកាសផ្ដល់ជូនដល់មេធាវីការពារក្ដីដើម្បីលើកមតិយោបល់ទាក់ទងទៅនឹងតម្លៃនៃភស្តុតាង ដូចជាឯកសារ -- ដូចជានៅក្នុងកថាខណ្ឌ១១ នៃឯកសារ E263 ដែលគេនិយាយថា នៅក្នុងសវនាការថ្ងៃ២៦ ខែមករា ២០១៣ គឺសវនាការ

លើកទី៣ ដែលនិយាយថាមេធាវីការពារក្តីមិនមានឱកាសដើម្បីបញ្ចេញមតិយោបល់ ឬក៏ដើម្បីជំទាស់ទៅលើឯកសារដែលបង្ហាញទៅភាគីនានានោះ។

ខ្ញុំសូមដកស្រង់ ចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់ថា “ភាគីអាចបញ្ចេញមតិយោបល់ទៅលើតម្លៃនៃភស្តុតាង ប៉ុន្តែមិនអាចបញ្ចេញមតិយោបល់ទៅលើភាពអាចទទួលយកនៃឯកសារនោះ”។ ដូច្នេះហើយ ទើបយើងចាំបាច់ត្រូវមានសវនាការលើភាពអាចទទួលយកបាននៃភស្តុតាង។ ដូច្នេះហើយអ្វីដែលលោក វែកគែន បាននិយាយគឺវាហាក់ដូចជាមាន -- មិន -- មានបញ្ហា។ ខ្ញុំគិតថាប្រហែលជាវិធីសាស្ត្រ ឬក៏យុទ្ធសាស្ត្ររបស់មេធាវី ខៀវ សំផន នោះទេ។

[០៩:៥៤:២១]

ចំពោះឯកសារ E263 នេះ គឺថាវាហាក់ដូចជាមានការតវ៉ាប្រញាប់ប្រញាល់ពេកទៅលើដំណើរការនីតិវិធី ហើយការតវ៉ាហាក់ដូចជាមិនត្រឹមត្រូវ។ ព្រោះក្នុងពេលជាមួយគ្នាហ្នឹង ក្នុងសវនាការចំនួនបីលោកចៅក្រម និល ណុន, ចៅក្រម ឡាវែន៍ ហើយនិងចៅក្រម ខាតវ៉ាយថ៍ នៅពេលព្រឹកនេះ គឺបានផ្តល់ដល់មេធាវីនេះ នូវឱកាស គឺផ្តល់ដោយផ្ទាល់នូវឱកាសដល់មេធាវីដើម្បីលើកបង្ហាញនូវសារណារបស់ខ្លួន ទាក់ទងទៅនឹងតម្លៃនៃភស្តុតាងរបស់ឯកសារមួយចំនួន អាចថាជាឯកសារលើកយកមកនិយាយនៅក្នុងសវនាការ។ ឯកសារទី១, ទី២ ដែលថាមេធាវីមិនទាន់មានឱកាស។ ប៉ុន្តែមិនមែននៅក្នុងសវនាការលើកទី៣នោះទេ ប្រសិនបើខ្ញុំសង្កេតឃើញនៅក្នុងញត្តិរបស់មេធាវីការពារក្តី។ នៅក្នុងឱកាសទាំងបីនេះ គឺថាមេធាវីការពារក្តី ខៀវ សំផន សម្រេចចិត្តថាមិនប្រើប្រាស់ឱកាសនេះ។ នេះជាបញ្ហារបស់ពួកគាត់។

លោក លោកស្រីចៅក្រម យើងសូមលើកឡើងថា យើងត្រូវចងចាំថាមេធាវីការពារក្តី ខៀវ សំផន មិនទទួលយកនូវការអញ្ជើញរបស់អង្គជំនុំជម្រះដើម្បីផ្តល់ឱកាសនោះឡើយ គឺពួកគេមិនបានបញ្ជាក់ថាគេត្រូវការប៉ុន្មានម៉ោង ឬក៏ប៉ុន្មានថ្ងៃដើម្បីបញ្ចេញមតិយោបល់ទៅលើតម្លៃនៃភស្តុតាងរបស់ឯកសារដែលបានលើកឡើងនៅក្នុងសវនាការលើឯកសារគន្លឹះ មួយ ពីរ។ មិនមែននៅលើឯកសារសវនាការទី៣នោះទេ។

[០៩:៥៥:៥២]

គឺថាឱកាសត្រូវបានប្រគល់ជូនមេធាវីការពារក្តី ខៀវ សំផន រួចទៅហើយ ប៉ុន្តែមេធាវីការពារក្តី ខៀវ សំផន មិនទទួលយក។ ដូច្នេះអានេះជាសិទ្ធិរបស់ពួកគាត់។ ដូច្នេះគឺថាសវនាការចាប់ពីថ្ងៃ២៤

បន្ថែមទៀត ប្រសិនបើពួកគេទទួលយក អាហ្នឹងជាបញ្ហាមួយ។ អាចថាប្រសិនបើពួកគាត់ស្នើសុំទទួលយក២ម៉ោង អាហ្នឹងគឺជាបញ្ហាមួយ។ នេះគឺជាអ្វីដែលពួកគាត់អាចធ្វើដើម្បីបញ្ចេញមតិយោបល់ទៅលើតម្លៃនៃភស្តុតាងនៅក្នុងសវនាការទី១ និងទី២។

លោក លោកស្រីចៅក្រម យើងខ្ញុំចង់ធ្វើការឆ្លើយតបផងដែរទៅលើបញ្ហាមួយចំនួននៅក្នុងឯកសារ E263 ថាតើយើងអាចបញ្ចេញមតិយោបល់ទៅលើបញ្ហាទាំងអស់នេះទៅលើសំណួរដែលបានលើកឡើង។ មុននឹងខ្ញុំចាប់ផ្តើម ខ្ញុំស្នើសុំថា តើអាចមានការបញ្ជាក់ពីអង្គជំនុំជម្រះថា តើយើងអាចធ្វើការឆ្លើយតបទៅនឹងឯកសារលេខ E263 ឬមួយក៏យើងអាចធ្វើការលើកឡើងបន្ថែមទៀត ទាក់ទងទៅនឹងបញ្ហាដែលមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងនៅពេលដែលខ្លួនបានដាក់នៅពេលក្រោយ។ ថាតើយើងអាចដាក់នៅពេលក្រោយ ឬមួយក៏យ៉ាងដូចម្តេច? យើងអាចពិភាក្សាបញ្ហានៅពេលនេះ ឬមួយក៏ថា យើងអាចផ្តោតទៅលើបញ្ហាផ្សេងតទៅទៀត។ សូមលោកចៅក្រម អង្គជំនុំជម្រះធ្វើការសម្រេច។

[០៩:៥៧:៣៤]

**ប្រធានអង្គជំនុំ៖**

បាទនៅតែពាក់ព័ន្ធនឹងការឆ្លើយតបនឹងឯកសារ E263 ទៅបានហើយ។ បញ្ហាផ្សេងទៀតនោះគឺនៅរបៀបវារៈដែលបានកំណត់ពិភាក្សានៅក្រោយៗទៀត។

**លោក វីញ៉្លៀម ស្មីត៖**

ប្រសិនបើយើងមើលទៅលើឯកសារ E263 គឺសារណាដែលមេធាវីការពារក្តី ខៀវ សំផន ស្នើសុំចង់ឲ្យមានដំណោះស្រាយទៅលើលើកសវនាការឯកសារ ដែលថាវាជាការរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទមិនទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសាធារណៈ។ ព្រោះថាឯកសារហ្នឹងមិនត្រូវបានប្រគល់ជូនជាសាធារណៈ។ ដូច្នេះគឺស្នើសុំឲ្យមានផ្សព្វផ្សាយដោយអង្គជំនុំជម្រះ ហើយនិងកាត់បន្ថយនូវលទ្ធភាពរបស់មេធាវីការពារក្តី ខៀវ សំផន ក៏ដូចជាខាងការពារក្តី និងព្រះរាជអាជ្ញាមិនឲ្យលើកយកឯកសារមកឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ហើយចំពោះមូលដ្ឋានបន្ទាប់ ខ្ញុំស្នើសុំឲ្យមេធាវីការពារក្តី ខៀវ សំផន ស្នើសុំបង្ហាញនូវតម្លៃនៃភស្តុតាងនៅពេលបញ្ចប់សវនាការនីមួយៗ ហើយខ្ញុំសូមជំទាស់។ ប្រសិនបើពួកគេចង់ធ្វើ គឺថាពួកគេអាចត្រូវការពេលវេលាពីបីម៉ោង ដើម្បីធ្វើ អាចធ្វើនៅសប្តាហ៍ក្រោយនៅក្នុងសវនាការលើកឯកសារគន្លឹះ ហើយចំពោះពាក់ព័ន្ធទៅនឹងសវនាការលើ

ឯកសារទី៣ គឺថាមេធាវីគាត់មានឱកាសធ្វើការបញ្ចេញមតិយោបល់ទៅលើតម្លៃនៃភស្តុតាង ប៉ុន្តែពួកគេបានបដិសេធ។

សំណើទី៣ ដែលមេធាវីការពារក្តី ខៀវ សំផន ស្នើសុំ គឺថាអង្គជំនុំជម្រះមិនត្រូវកម្រិតកំណត់ត្រឹមតែ១០០ទំព័រ ចំពោះសារណាបញ្ចប់ការពិភាក្សាដេញដោលនោះទេ។ ខ្ញុំសូមឆ្លើយថាទេ ព្រោះវាពាក់ព័ន្ធទៅនឹងបញ្ហាមួយផ្សេងទៀតដែលអង្គជំនុំជម្រះត្រូវធ្វើការសម្រេច។

មូលដ្ឋានទី៤ នៃការស្នើសុំ គឺសុំឲ្យផ្តល់ពេលវេលាបន្ថែមដល់ភាគីក្នុងការថ្លែងទៅលើសារណាបញ្ចប់ការពិភាក្សាដេញដោលនេះ។ នេះគឺជាបញ្ហាមួយផ្សេងទៀត។ សូមអរគុណលោកប្រធានលោកលោកស្រីចៅក្រម។

[១០:០០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តទៀតបន្ទាប់ពីបានទទួលសំណើរបស់ភាគីទាំងអស់ដែលបានស្នើសុំពេលវេលាសម្រាប់សវនាការលើការបង្ហាញឯកសារជាលើកចុងក្រោយនេះ អង្គជំនុំជម្រះនឹងផ្តល់ការបញ្ជាក់លម្អិតពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃសវនាការនេះនាពេលខ្លីខាងមុខក្រោយកិច្ចប្រជុំរៀបចំសវនាការនេះទៅ។ បន្ថែមពីលើនេះសហព្រះរាជអាជ្ញាបានស្នើសុំបច្ចុប្បន្នភាព ពាក់ព័ន្ធទៅនឹងការចេញលេខសម្គាល់ឯកសារ E3 នៅពេលសវនាការ និងកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីភាព អាចទទួលយកបាននៃចម្លើយរបស់សាក្សីជាលាយលក្ខណ៍អក្សរ។ កាលបរិច្ឆេទនៃសេចក្តីសម្រេចខាង លើនេះនឹងចេញនៅក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន។ ហើយអង្គជំនុំជម្រះសូមរំឭកថា -- អង្គជំនុំជម្រះរំពឹងថានឹងអាចចេញនៅក្នុងរយៈពេលសប្តាហ៍ទី២ ឬទី៣ខាងមុខនេះ ទោះនៅក្នុងករណីណាក៏ដោយ សេចក្តីសម្រេចនេះនឹងចេញនៅមុនពេលនៃការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១។

ចម្លើយទាំងអស់ដែលត្រូវបានទទួលយកនឹងទទួលបានលេខសម្គាល់ E3 នាពេលសមស្របខាងមុខនេះដែរ។ អង្គជំនុំជម្រះប៉ាន់ប្រមាណថា ចម្លើយជាលាយលក្ខណ៍អក្សរចំនួនប្រមាណ ១.៥០០ នឹងទទួលចំណាត់ថ្នាក់ E3 នាពេលខ្លីខាងមុខនេះ នៅពេលដែលសេចក្តីសម្រេចនេះនឹងឧបសម្ព័ន្ធរបស់អង្គជំនុំជម្រះដែលភ្ជាប់ទៅនឹងសេចក្តីសម្រេចនេះនឹងរៀបចំរួចរាល់នៅក្នុងអំឡុងពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ។ មកទល់នឹងពេលបច្ចុប្បន្ននេះ ឯកសារចំនួនប្រមាណ៤.០០០ ត្រូវបានដាក់នៅចំពោះមុខអង្គ

ជំនុំជម្រះ នឹងបានទទួលលេខសម្គាល់ E3។ ឯកសារទាំងនេះភាគច្រើនសន្ធឹកសន្ធាប់ គឺជាឯកសារដែលភាគីស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកនៅពេលសវនាការ។ ឯកសារដែលនៅសេសសល់ប្រមាណ ៨០០ ឯកសារនឹងទទួលបានចំណាត់ E3 នៅពេលដ៏ខ្លីខាងមុខនេះ នៅពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចស្តាពររបស់ខ្លួនស្តីពីភាពអាចទទួលយកបាននៃឯកសារ ដែលត្រូវបានដាក់នៅសវនាការនៅក្នុងសំណុំរឿង០០២/០១។ សេចក្តីសម្រេចនេះក៏នឹងមាននាពេលខាងមុខផងដែរ។

អំពីការសួរសំណួរទៅកាន់ជនជាប់ចោទ: បន្ទាប់ពីមានការគូសបញ្ជាក់ថាជនជាប់ចោទមានបំណងឆ្លើយតបទៅនឹងសំណួរនៅចំពោះមុខអង្គជំនុំជម្រះសហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់ពេលវេលាឲ្យពួកគាត់ចំនួន៦ថ្ងៃពេញសម្រាប់សួរសំណួរទៅកាន់ជនជាប់ចោទម្នាក់ៗ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នាពេលបច្ចុប្បន្នពុំមានភាពប្រាកដប្រជាថា ជនជាប់ចោទនឹងមានលទ្ធភាព ឬឆន្ទៈដើម្បីឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះនិងភាគីបានយូរប៉ុនណាឡើយ។ ហេតុដូច្នេះហើយអង្គជំនុំជម្រះនឹងពុំគូសបញ្ជាក់អំពីពេលវេលាកំណត់សម្រាប់ការសួរសំណួរនេះឡើយ។ ពោលគឺនឹងអនុញ្ញាតឲ្យសួរដរាបណាជនជាប់ចោទ មានឆន្ទៈឆ្លើយនឹងសំណួរ និងល្អិតណាសំណួររបស់ភាគីពាក់ព័ន្ធទៅនឹងអង្គហេតុនៅក្នុងវិសាលភាពសំណុំរឿង០០២/០១។ ភាគីនឹងទទួលដំណឹងឆាប់ៗតាមដែលអាចធ្វើទៅបានអំពីកាលបរិច្ឆេទនៃសវនាការសម្រាប់ការសួរសំណួរទៅកាន់ជនជាប់ចោទ។ ដោយនៅក្នុងនោះអាស្រ័យទៅលើវត្តមានរបស់សាក្សីដែលនៅសេសសល់ប្រសិនបើមាន។

មេធាវីការពារក្តី ខៀវ សំផន ក៏បានស្នើសុំឲ្យផ្តល់ជាមុននៅឯកសារទាំងឡាយដែលនឹងត្រូវយកមកប្រើប្រាស់នៅក្នុងអំឡុងពេលសួរសំណួរទៅកាន់ចុងជាប់ចោទ។ អង្គជំនុំជម្រះឯកភាពជាមួយនឹងសំណើនេះ ហើយក៏ស្នើសុំភាគីទាំងអស់ផ្តល់ជូនដំណឹងឲ្យបានទាន់ពេលវេលាទៅភាគីផ្សេងៗ និងអង្គជំនុំជម្រះ នូវឯកសារនានាដែលពួកគាត់អាចដេញដោលជនជាប់ចោទនាពេលសវនាការ។ អង្គជំនុំជម្រះក៏នឹងជូនដំណឹងទៅភាគីអំពីឯកសារនានាដែលខ្លួនត្រូវយកមកប្រើប្រាស់សម្រាប់គោលបំណងនេះផងដែរ។

អំពីសារណា និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល:

ភាគីជាច្រើនបានធ្វើសំណើជាថ្មី ស្នើសុំការពន្យារពេលផុតកំណត់នៃការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញចំពោះការសម្រេចរបស់អង្គជំនុំជម្រះក្នុងឯកសារ E228 ក្នុងការរក្សាពេលវេលាកំណត់នេះត្រឹម១ខែក្រោយពេលចប់កិច្ច

ដំណើរការនីតិវិធីដេញដោលលើភស្តុតាង។

នាពេលបច្ចុប្បន្ននេះជនជាប់ចោទ ខៀវ សំផន បានស្នើសុំពេលវេលាចំនួនប្រមាណ ៣ខែ ដើម្បីដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន។ បើទោះបីជាបញ្ហានេះធ្លាប់ត្រូវបានសម្រេចរួចម្តងហើយក៏ដោយ ក៏អង្គជំនុំជម្រះនឹងឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំពន្យារពេលដល់៦សប្តាហ៍ គិតពីពេលបញ្ចប់ការ -- កិច្ចពិភាក្សាដេញដោលលើភស្តុតាងសម្រាប់ការដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល។ យ៉ាងណាមិញ អង្គជំនុំជម្រះពុំអាចអនុញ្ញាតចំពោះការពន្យារពេលបន្ថែមទៀតឡើយ។ អង្គជំនុំជម្រះពុំឯកភាពតាមសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ដែលស្នើសុំដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលចំនួន ៣០០ទំព័របានឡើយ។ ដូចដែលអង្គជំនុំជម្រះ បានគូសបញ្ជាក់កាលពីសប្តាហ៍មុនសេចក្តីសម្រេចរបស់ខ្លួន ឯកសារ E228 -- E288 បាទ កែតម្រូវវិញគឺឯកសារ 288។ អង្គជំនុំជម្រះនៅរក្សាចំនួនទំព័រកំណត់កាលពីពេលមុនដូចដែលបានគូសបញ្ជាក់សម្រាប់សារណាបញ្ចប់ការពិភាក្សាដេញដោល។

[១០:០៦:០៦]

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រមព្រហ្មទណ្ឌកម្ពុជាគ្រប់ផ្នែកទាំងអស់បានចូលជាធរមាននាពេលបច្ចុប្បន្ន ហើយថ្វីបើភាគីបានដាក់សារណាស្តីពីច្បាប់ជាធរមានរួចទៅហើយក៏ដោយ ក៏ភាគីនៅតែអាចលើកអំពីបញ្ហានេះនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគី ប្រសិនបើភាគីមានបំណងធ្វើដូច្នេះ។

សហព្រះរាជអាជ្ញាបានស្នើសុំបញ្ជាក់បំភ្លឺនៅមុនកិច្ចប្រជុំនេះ ពាក់ព័ន្ធទៅនឹងទម្រង់នៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល លក្ខណៈនៃសំណើនេះពុំមានភាពច្បាស់លាស់ អង្គជំនុំជម្រះធ្លាប់បានគូសបញ្ជាក់ថា សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់ និងត្រូវកំណត់កាលបរិច្ឆេទនៅប្រមាណ ៣០ថ្ងៃក្រោយដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល។ តើពេលនេះសហព្រះរាជអាជ្ញាអាចបញ្ជាក់អំពីអ្វីដែលនៅសេសសល់ដែលត្រូវការបញ្ជាក់បំភ្លឺដែរឬទេ?

[១០:០៧:១៧]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ តាមពិតនិយាយអំពីបញ្ហានេះគឺថា សុំឲ្យភាគីបញ្ជាក់នោះ ខ្ញុំនឹងនិយាយអំពីបញ្ហាចំពោះមុខមួយចំនួន ហើយខ្ញុំនឹងសូមឲ្យមានការបំភ្លឺពីបញ្ហានេះ។ សូមជម្រាបថា

និយាយអំពីសេចក្តីសម្រេចថា សហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់នូវបញ្ជីឯកសារជាមុននោះ ទាក់ទងទៅនឹងការសួរសំណួរទៅជនជាប់ ខ្ញុំគិតថានឹងមានបញ្ហាមួយ។ តាមសេចក្តីសម្រេចរបស់តុលាការដែលមានសំណើរបស់មេធាវី ខៀវ សំផន គឺថាត្រូវផ្តល់ប្រធានបទជាមុន។ ហើយខ្ញុំយល់ឃើញថា មិនទាន់មានការសម្រេចផ្តល់នោះទេ ជាពិសេសវិធាន៩០ នៃវិធានផ្ទៃក្នុងគឺមិនមានលក្ខខណ្ឌតម្រូវថាប្រធានបទនេះនឹងត្រូវផ្តល់ទៅឲ្យសាក្សី ឬក៏ជនជាប់ចោទទេ ហើយក៏មិនត្រូវឲ្យទៅសាក្សីនោះដែរនៅពេលដែលភាគីសួរដេញដោលនោះ។ យើងខ្ញុំសូមជម្រាបថា នេះជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថា យើងនឹងគោរពតាមយល់ស្រប ហើយចំណុចសំខាន់នោះគឺថា ជនជាប់ចោទ និងភាគីទាំងអស់មានលទ្ធភាពនឹងផ្តល់បង្ហាញភស្តុតាងក្នុងវិធីដូចគ្នា របៀបដូចគ្នា ដូចដែលតម្រូវដោយវិធាននៅក្នុងមាត្រា៣៥ថ្មី គឺត្រូវតែការពារនូវឯកសារ បង្ហាញឯកសារក្នុងនាមភាគី ក្នុងលក្ខខណ្ឌដែលភស្តុតាងនោះប្រឆាំងនឹងជនជាប់ចោទក្តី។ ការផ្តល់ប្រធានបទទៅ ខៀវ សំផន អាចនឹងគឺជាគុណប្រយោជន៍មិនសមស្របទៅដល់ភាគីទេ មិនយុត្តិធម៌ដល់ភាគីទេ ពីព្រោះថាមិនតម្រូវឲ្យផ្តល់ប្រធានបទទៅភាគីផ្សេងៗទៀតទេជាមុននោះបាទ។

និយាយអំពីប្រធានបទ ដែលត្រូវផ្តល់ជូននេះ គឺសហព្រះរាជអាជ្ញាបានជម្រាបអង្គជំនុំជម្រះថាប្រធានបទដែលនឹងពិភាក្សានោះជាមួយលោក ខៀវ សំផន នោះ ហើយនិងលោក នួន ជា ផងដែរនោះគឺជាប្រធានបទដែលបានកំណត់អត្តសញ្ញាណរួចហើយនៅក្នុងរឿងក្តីនេះ។ ជាពិសេសប្រធានបទដែលបានលើកឡើងនៅក្នុងកថាខណ្ឌមួយចំនួនដែលទាក់ទងនឹងដីកាដំណោះស្រាយនៅក្នុងការបំបែកសំណុំរឿងនោះផងដែរ ហើយយើងនឹងពិភាក្សាអំពីជនជាប់ចោទនៅក្នុងកម្រិតមួយដែលអាចធ្វើទៅបាន ដែលយើងបានទទួលសេចក្តីអនុញ្ញាតនោះ។

ទាក់ទងទៅនឹងទម្រង់បែបបទនៃសេចក្តីសន្និដ្ឋានបិទសវនាការនោះ អ្វីដែលយើងខ្ញុំនឹងយោងទៅរកនោះ គឺថាតើត្រូវបែងចែកពេលវេលាដូចម្តេច ជាពិសេសតុលាការបានបញ្ជាក់នៅក្នុងអនុស្សរណៈនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ នេះគឺនិយាយថា ៣ថ្ងៃសម្រាប់សហព្រះរាជអាជ្ញា។ ១ថ្ងៃសម្រាប់ដើម គឺ២ថ្ងៃសម្រាប់មេធាវី នួន ជា ហើយមេធាវីលោក ខៀវ សំផន ២ថ្ងៃ។

[១០:១១:១០]

នេះជាទម្លាប់អនុវត្តន៍ធម្មតា ដូចដែលអនុវត្តនៅក្នុងរឿងក្តី ឌុច ដែរ ដូចជារឿងក្តី០០១ នោះព្រោះទាំងនៅក្នុងតុលាការអន្តរជាតិផ្សេងៗដែរ។ ភាគីទាំងអស់បានធ្វើសេចក្តីសន្និដ្ឋាន ហើយភាគីទាំង

អស់ធ្វើសេចក្តីសន្និដ្ឋាន បន្ទាប់មកសហព្រះរាជអាជ្ញាឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ជនជាប់ចោទ ហើយនៅចុងក្រោយជនជាប់ចោទគាត់មានសម្តីចុងក្រោយជាសេចក្តីសន្និដ្ឋាន។ សំណួររបស់ខ្ញុំថា តើថ្ងៃទាំងអស់នោះដែលអង្គជំនុំជម្រះបញ្ចូលហ្នឹង តើរាប់បញ្ចូលទាំងការឆ្លើយតប និងការបដិសេធនោះដែរឬទេសម្រាប់ភាគីទាំងអស់ ដែលខ្ញុំជឿថា ដែលអង្គជំនុំជម្រះនឹងស្នើផ្តល់ពេលវេលាឲ្យរវាងពីសេចក្តីសន្និដ្ឋានដំបូង ហើយនិងមានការបដិសេធ ហើយនិងការឆ្លើយតប? បើយើងបានចម្លើយបែបនេះដើម្បីឲ្យភាគីទាំងអស់រួមទាំងយើងខ្ញុំអាចនឹងធ្វើផែនការពេលវេលានោះបាន។ ដូចដែលខ្ញុំជម្រាប់លោក លោកស្រីចៅក្រម និងភាគីហ្នឹង គឺថាបញ្ហាមួយចំនួនបានបញ្ជាក់ជូនហើយ ប៉ុន្តែទាក់ទងទៅនឹងរយៈ -- ប្រវែងនៃសេចក្តីសន្និដ្ឋានបញ្ចប់ គឺតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះ ថាចំនួនទំព័រនោះ គឺត្រូវរក្សាទុកដដែល។

[១០:១២:៤២]

អ្វីដែលយើងមានការលំបាក ខ្ញុំយល់ហើយពីការលំបាកនោះ គឺរបស់មេធាវីការពារក្តីរបស់លោក ខៀវ សំផន គឺវាអាចថា សហព្រះរាជអាជ្ញាក៏នឹងអាចមានការលំបាកប្រហាក់ប្រហែលខ្លះដែរ គឺក្នុងការអាចនឹងណែនាំឲ្យអង្គជំនុំជម្រះបង្ហាញនូវឯកសារ ដើម្បីគាំទ្រនូវការចោទ -- និងការបែងចែកដែលថាមានការបញ្ជាក់ច្បាស់លាស់ ឬក៏មិនមាន ជាឧទាហរណ៍ ២០០ទំព័រ របស់សហព្រះរាជអាជ្ញា គឺភាគច្រើនឯកសារយោងទៅនឹងភស្តុតាងនោះ គឺដែលត្រូវតែអាចធ្វើទៅក្នុង ២០០ទំព័រ ឬក៏អាចនឹងបញ្ជាក់ក្នុងលេខយោងចុងក្រោយចុងទំព័រនោះ។ ហើយជាពិសេសដូចជារៀបចំនៅក្នុងដីកាចោទប្រកាន់ -- បញ្ជូនរឿងមកជំនុំជម្រះដែលថា គឺមានសេចក្តីយោងនៅខាងចុងបំផុត គំនិតនេះ គឺមិនចង់ពង្រីកនៅចំនួនទំព័រទេ ប៉ុន្តែអ្វីដែលយើងចង់ធ្វើនោះ គឺដើម្បីអនុញ្ញាតឲ្យភាគីទាំងអស់ ដើម្បីចង្អុលបង្ហាញពីឯកសារយោងទាំងអស់ គឺថាជាពិស្តារនោះចំពោះនឹងការអះអាងរបស់ខ្លួននៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់នោះ។

[១០:១៤:០៨]

ដូចជាលោកស្រីចៅក្រមបញ្ជាក់ថា គឺឯកសារ ៤.០០០ឯណោះ ដែលត្រូវបានទទួលស្គាល់ គឺថា ៨០០ គឺនឹងទទួលបានលេខជា E3 ហើយ ១.០៥០ នឹងអាចទទួលបានឯកសារ E3។ អ៊ីចឹងហើយភាគីគឺនឹងត្រូវធ្វើការភស្តុតាងជាង ៦.០០០ឯណោះ ដែលនឹងត្រូវធ្វើការ ដើម្បីយោង។ អ្វីដែលសហព្រះរាជអាជ្ញានឹងត្រូវអនុវត្តនោះ គឺថា -- ខ្ញុំមិននិយាយជំនួសមេធាវី ខៀវ សំផន ទេ ប៉ុន្តែនៅអ្វីដែលគាត់លើក

ឡើង គាត់មិនចង់ស្ថិតនៅក្នុងស្ថានភាពមួយដែលថា យើងមិនអាចប្រើជាឯកសារយោងណាមួយ ឬក៏ភស្តុតាងសំខាន់ៗទាំងអស់នោះ នោះទេ ដោយហេតុថាមិនបានដាក់បញ្ចូលនៅក្នុងសេចក្តីសន្និដ្ឋាននោះ។ អយ្យការហ្នឹង គឺថា តែងតែដាក់នៅក្នុងកន្ទុះទំព័រ នៅក្នុងសេចក្តីយោងជាលេខយោង ហើយនិងកន្ទុះទំព័រជាសេចក្តីអះអាងរបស់ខ្លួន។ ហើយមានភស្តុតាងច្រើនណាស់រហូតទៅដល់៦.០០០។ យើងមិនអាចយោងទៅភស្តុតាងពាក់ព័ន្ធមួយៗបានទេ ប្រសិនបើយើងមិនអាចបាន មិនអាចប្រើជាលេខឯកសារយោងជា *អ៊ិនណូត* -- ដែលហៅថា លេខយោងចុងទំព័រក្រោយនោះ។ បើយើងធ្វើបែបនេះបាន គឺថាអាចនឹងជួសជុលនូវបញ្ហាចំនួនធំដែលជាសំណើរបស់ ខៀវ សំផន។ អ៊ីចឹងយើងខ្ញុំសូមជម្រាបថា ភាគីមានឱកាសដ៏ល្អក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន ក្នុងការចង្អុលបង្ហាញជូនចៅក្រម គឺថាភស្តុតាងសំខាន់ណាខ្លះដែលខ្លួនពឹងផ្អែកនោះ។

[១០:១៥:៥២]

តែមេធាវីការពារក្តីមានកាសទាំងស្រុងដើម្បីធ្វើដូច្នេះដែរ។ សហព្រះរាជអាជ្ញាក៏អាចនឹងធ្វើបានដើមបណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបាន។ រីឯសហព្រះរាជអាជ្ញាគឺថាមានកាតព្វកិច្ចក្នុងការបង្ហាញរឿងក្តីភស្តុតាងឲ្យហួសពីវិមតិសង្ស័យ។ យើងត្រូវតែមានភស្តុតាងសំខាន់ៗជាបង្អែកនោះឯង។

សំណើរបស់ខ្ញុំជូនអង្គជំនុំជម្រះនោះ គឺថាយើងស្នើថាឲ្យមានសេចក្តីសម្រេចធំមួយដើម្បីបញ្ចេញពីសេចក្តីពីមុន ថាឲ្យភាគីទាំងអស់គឺអាចមើលសេចក្តីសន្និដ្ឋានបញ្ចប់ហ្នឹង គឺថាដូចអ្វីដែលសហចៅក្រមស៊ើបអង្កេតបានធ្វើនៅក្នុងដីកាបញ្ជូនរឿងទៅជម្រះនោះ យើងគិតថាផលប្រយោជន៍សម្រាប់អង្គជំនុំជម្រះនោះគឺវាទូលំទូលាយខ្លាំងជាងមុន គឺសន្សំពេលការបកប្រែ។ ជាពិសេសឲ្យតុលាការហ្នឹងអាចនឹងពន្លឿននីតិវិធីផងដែរ។ ជម្រើសមួយទៀតនោះ ខ្ញុំគិតថាជាជម្រើសល្អនោះ គឺដូចដែលការអនុវត្តទាក់ទងទៅនឹងតុលាការអន្តរជាតិនៅពេលដែលគេភ្ជាប់ឧបសម្ព័ន្ធទៅនឹងសេចក្តីសន្និដ្ឋាន គឺ សេចក្តីយោងនោះគឺត្រូវដាក់នៅក្នុងឧបសម្ព័ន្ធ គឺថាអាចជាការប្រសើរ បើយើងមានលេខយោងផ្ទាល់ ហើយនិងឯកសារឧបសម្ព័ន្ធនោះផ្ទាល់ទៅនឹងឯកសារ ប្រសិនជាប្រវែងទំព័រដែលអង្គជំនុំជម្រះបញ្ជាក់នោះ គឺថាអាចនឹងអនុញ្ញាតឲ្យភាគីពឹងផ្អែកលើភស្តុតាងនោះ មិនឲ្យភស្តុតាងណាមួយបាត់បង់ដោយសារតែការកំណត់ចំនួនទំព័រនោះទេ។ ខ្ញុំគិតថា យើងចំណាយលុយរាប់លានដុល្លារនៅក្នុងការដំណើរការនីតិវិធីនេះ។ គឺជាពិសេសគឺយើងការកំណត់ចំនួនទំព័រនៅដដែល ប៉ុន្តែលេខយោង ជាឯកសារយោងឧបសម្ព័ន្ធនោះ គឺថាអាចហ្នឹងដាក់បញ្ចូលបានដើម្បីខ្លួនលើកពីរឿងក្តីរបស់ខ្លួនឲ្យបានពិស្តារនោះ។

ខ្ញុំនឹងពិនិត្យឡើងវិញ ទាក់ទងទៅនឹងការធ្វើសក្ខីកម្មរបស់ជនជាប់ចោទ១សប្តាហ៍ ឬ២សប្តាហ៍ បន្ទាប់ពីភស្តុតាងដែលនៅសេសសល់នេះ ខ្ញុំសូមជម្រាបថា សំណើរបស់លោក ខៀវ សំផន ហើយយើងខ្ញុំសូមជម្រាបថានេះមិនសមស្របទេ។ ព្រោះគាត់មានពេល៥ឆ្នាំកន្លះហើយដើម្បីរៀបចំធ្វើសក្ខីកម្មរបស់ខ្លួន បាទ។ ហើយដោយសារតែការឈប់សម្រាកជាច្រើននោះ ទាក់ទងទៅនឹងការជំងឺរបស់លោក អៀង សារី និង នួន ជា ពេលនោះមេធាវីការពារក្តីលោក ខៀវ សំផន គឺថាអាចនឹងមានពេលច្រើនក្នុងការត្រៀមរៀបចំជារៀងរាល់ថ្ងៃ ព្រោះថាគាត់មានសុខភាពល្អ គាត់វ័យក្មេងជាងលោក នួន ជា ហើយ នួន ជា ក៏បានទទួលឱកាសក្នុងការរៀបចំនោះដែរ។ ដូច្នេះហើយ គាត់មិនមានមូលហេតុអីសមស្របសុំ២សប្តាហ៍ ឬលើសហ្នឹង ដើម្បីត្រៀមរៀបចំនោះទេ ព្រោះគាត់មានពេល៥ឆ្នាំជាងមកហើយ ដើម្បីដូច្នេះ។

[១០:១៩:១៨]

ខ្ញុំគិតថា លោកស្រីចៅក្រម និងភាគីថា ខ្ញុំអាចនឹងមានយោបល់មួយទាក់ទងនឹងសេចក្តីសម្រេច គឺថា E3 នឹងត្រូវចេញ ហើយនិងការនឹងទាក់ទងទៅនឹងការភាពអាចទទួលយកបាននៃឯកសារភស្តុតាងហ្នឹងក៏នឹងចេញនៅពេលក្រោយដែរ យើងនឹងស្វាគមន៍ ប៉ុន្តែមានមូលហេតុមួយដោយសារយើងពេលចេះតែទៅមុខ គឺថាភាគីត្រូវតែរៀបចំសេចក្តីសន្និដ្ឋានបញ្ចប់ អ្វីត្រូវទុក អ្វីត្រូវមិនយកនោះ។ ដូច្នេះហើយអាចហ្នឹង-- បាទ។ រីឯសេចក្តីសម្រេចទាក់ទងទៅនឹងការទទួលយកភស្តុតាងហ្នឹងសំខាន់ណាស់ ដើម្បីឲ្យយើងធ្វើការងារបាន បើមិនដូច្នោះទេ យើងមិនដឹងថាត្រូវទុកឯកសារណា ចោលឯកសារណាទេ។ ដូច្នេះ ខ្ញុំសូមអរគុណចំពោះមតិរបស់ខ្ញុំត្រឹមប៉ុណ្ណោះសិនបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។

បាទ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ចាស ខ្ញុំគ្រាន់មានការកត់សម្គាល់ខ្លីៗតែប៉ុណ្ណោះទាក់ទងចំណុចច្បាស់លាស់មួយចំនួននេះ។

ដំបូងទាក់ទងទៅនឹងបញ្ហាជនជាប់ចោទ យើងសុំ៣ថ្ងៃ ហើយយើងអាចកាត់មកត្រឹមតែ២ថ្ងៃទេចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ នេះជាការកត់សម្គាល់ទី១របស់ខ្ញុំ។ ទាក់ទងទៅនឹងការប្រាប់ជនជាប់ចោទឲ្យដឹងមុនអំពីសំណួរដែលយើងនឹងចោទសួរទៅគាត់នោះ យើងមិនជំទាស់ក្នុងការផ្តល់ប្រធាន

បទចម្បងឲ្យគាត់ទេ ក៏ប៉ុន្តែយើងនៅសុំរក្សាសិទ្ធិចោទសំណួរបន្ថែមដែលចេញពីចម្លើយរបស់ជនជាប់ចោទ នេះជាសិទ្ធជាមូលដ្ឋានរបស់ភាគីទាំងអស់គ្នាទេ។

[១០:២១:០៨]

ទាក់ទងទៅនឹងចំនួនទំព័រវិញ យើងអាស្រ័យតាមអង្គជំនុំជម្រះតែប៉ុណ្ណោះ។ យើងពុំមានការកត់សម្គាល់អ្វីធំដុំទេ។ យើងយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា ហើយជាមួយមេធាវីរបស់ ខៀវ សំផន ដែរគឺថាមិនត្រូវរាប់បញ្ចូលពីកំណត់ហេតុជើងទំព័រទេនៅក្នុងសារណាបញ្ចប់ការដេញដោលនេះ។

នៅចំណុចចុងក្រោយទាក់ទងនឹងរយៈពេលវេលាដែល ខៀវ សំផន សុំរយៈពេលត្រៀមសំណួរនោះ យើងក៏អាស្រ័យតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែរ ហើយយើងគាំទ្រការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ពីព្រោះថាខាង ខៀវ សំផន នេះមានពេលវេលាគ្រប់គ្រាន់ហើយក្នុងការត្រៀមខ្លួននោះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ សូមអញ្ជើញមេធាវីជាតិការពារក្តីលោកខៀវ សំផន!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន សូមគោរពអង្គប្រជុំ។ ខ្ញុំសូមលើកនូវចំណុចឆ្លើយតបខ្លីចំពោះការលើកអះអាងអំពីថាក្រុមលោក ខៀវ សំផន មានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំឯកសារទាំងអស់ ហើយដែលមិនចាំបាច់ត្រូវការពេលវេលាបន្ថែមដែលតាមការស្នើសុំ១សប្តាហ៍នោះ។ យើងឃើញថាការស្នើសុំរបស់យើង គឺជាការ--

សូមទោសលោកប្រធានដោយសារថាមានបញ្ហាបកប្រែជាភាសាបារាំងថា យើងអត់ត្រូវការពេលវេលា។ អម្បាញ់មិញ ខ្ញុំបានលើកសម្តីរបស់ខាងតំណាងអយ្យការ និងតំណាងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីថាយើងមិនត្រូវការពេលវេលា មិនចាំបាច់ត្រូវការពេលវេលាបន្ថែម១សប្តាហ៍ដើម្បីដកឃ្លាពិនិត្យទៅលើឯកសារ។ ដោយឡែក យើងខ្ញុំសូមបញ្ជាក់នូវជំហរដូច្នេះថា មូលហេតុដែលយើងស្នើសុំនេះ ដោយសារទី១ យើងឃើញថាក្រុមមេធាវីរបស់យើងបានចាប់ផ្តើមចូលនៅក្នុងនីតិវិធីនេះ គឺក្រោយគេបង្អស់ហើយ។ ហើយយើងចាប់ផ្តើមភ្លាមនៅពេលសវនាការ។ នេះជាបញ្ហាទី១។ ហើយមេធាវីដែលធ្លាប់ការពារលោក ខៀវ សំផន កន្លងមកគឺបានដូររហូតដល់ទៅពីរនាក់រួចទៅហើយ។

មួយទៀតទាក់ទងទៅនឹងបញ្ហារបស់លោក ខៀវ សំផន ផ្ទាល់។ រយៈពេល៥ឆ្នាំដែលតំណាង

សហព្រះរាជអាជ្ញាបានលើកថា យើងមានពេលវេលាដើម្បីត្រៀមនេះ។ មិនមែនប្រាកដដូច្នោះទេ ពីព្រោះរយៈពេល៥ឆ្នាំនេះ គឺរយៈពេលដែលលោក ខៀវ សំផន នៅក្នុងមន្ទីរឃុំឃាំង មិនមែនជាពេលវេលាដែលលោក ខៀវ សំផន ត្រៀមដើម្បីរៀបចំឯកសារនោះទេ។ វាជាការលំបាកណាស់ដែលឲ្យលោក ខៀវ សំផន មានរយៈពេល៥ឆ្នាំ ដែលថាត្រៀមដើម្បីតទល់ទៅនឹងឯកសាររាប់ពាន់ រាប់ម៉ឺនឯក-សារនេះ។

[១០:២៤:៣៧]

ដោយឡែកទាក់ទងទៅនឹងសុខភាពរបស់លោក ខៀវ សំផន យើងឃើញហើយថា ទោះបីលោក ខៀវ សំផន មានអាយុតិចជាងលោក នួន ជា ប៉ុន្តែមិនមែនមានន័យថាលោក ខៀវ សំផន ជាយុវជនដែលមានកម្លាំងពេញនោះទេ។ គាត់ក៏មានបញ្ហាសុខភាព ហើយគាត់ព្យាយាមតាមដាននីតិវិធីរហូតតាមលទ្ធភាពដែលគាត់អាចធ្វើទៅបានកន្លងមក។ ដូច្នេះការស្នើសុំពេលវេលានេះ វាសមស្របបំផុតហើយរយៈពេល១សប្តាហ៍ ដើម្បីឲ្យយើងអាចធ្វើការទៅលើឯកសារទាំងអស់នេះ។ វាមិនមែនជាការវែងធ្វើឲ្យអូសបន្លាយពេលវេលារបស់អង្គជំនុំជម្រះទេ តែដើម្បីផលប្រយោជន៍របស់យើងក្នុងការការពារក្តីនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ សូមអញ្ជើញលោក វែកគែន។

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោសចំពោះការលំបាកនៅក្នុងការនិយាយគ្នាហើយនិងការបកប្រែនោះដើម្បីឲ្យច្បាស់លាស់តែម្តងយើងសុំពេលវេលាជាសម្រាកមួយឲ្យលោក ខៀវ សំផន ធ្វើការជាមួយមេធាវីរបស់គាត់លើឯកសារ ហើយនិងប្រធានបទដែលខាងសហព្រះរាជអាជ្ញាហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ហើយចៅក្រមចង់សួរ។ អ៊ីចឹងសុំចាប់ពីពេលដែលយើងទទួលការផ្តល់ដំណឹងពីព័ត៌មាននេះយើងនឹងជម្រាបជូន ថាត្រូវការពេលវេលាប៉ុន្មាន។ នេះជាការកាត់ក្តីពិសេសមួយគឺថារឿងកន្លងផុត ៤០ឆ្នាំមកហើយ ហើយជនជាប់ចោទសុទ្ធតែមានអាយុជាង ៨០ឆ្នាំ គាត់សុទ្ធតែចាស់ៗហើយ លោក ខៀវ សំផន ក៏ចាស់, លោកនួន ជា ក៏ចាស់ដែរ។ ហើយគាត់មកព្យាយាមសវនាការរាល់ថ្ងៃនេះអស់កម្លាំងណាស់។ សហភាតារបស់ខ្ញុំនិយាយអំមិញហើយថាយើងគ្នាតិចណាស់ខាងសហព្រះរាអាជ្ញាគេគ្នាច្រើនគេផ្លាស់វេនគ្នាមកក្នុងសវនាការរហូតពេលមកសួរសាក្សីសួរអីនេះ

ហើយយើងនេះយើងមានមុខងដែលៗនៅពេលមកក្នុងសវនាការ។ ហើយពេលវេលាគឺថាមកចំណាយក្នុងសវនាការនេះយើងគ្មានពេលឯណាទៅត្រៀមលក្ខណៈអីក្រៅទៀតទេ។ អ៊ីចឹងយើងពុំមានលទ្ធភាពត្រៀមលក្ខណៈអីផ្សេងទៀតទេ ព្រោះយើងចំណាយពេលលើសវនាការអស់ហើយ។ យើងមធ្យោបាយយើងមានតិចជាងគេ។ ហើយការនិយាយអំមិញគឺថាពេលដែល អៀងសារី គាត់ស្លាប់ទៅនោះតើ -- ពេលគាត់ស្លាប់នោះធ្វើឲ្យខាងសហព្រះរាជអាជ្ញាវិញទេ ដែលគេមានឱកាសធ្វើការលើឯកសារច្រើនព្រោះថាគេកាត់បន្ថយការធ្វើការលើ អៀង សារី មកធ្វើការលើរឿង ខៀវ សំផន វិញ។ អ៊ីចឹងត្រង់ចំណុចនេះគឺថាពេវលា៣អាទិត្យនេះគឺថាមានបញ្ហា។ ដើម្បីឲ្យខាងមេធាវីការពារ -- ខ្ញុំគិតថាត្រូវការពេលវេលាហ្នឹង គិតចាប់ពីពេលដែលទទួលដំណឹងហើយ។ ឥឡូវនេះយើងបានពិភាក្សាជាមួយកូនក្តីយើង ពិគ្រោះជាមួយគាត់តែចុងសប្តាហ៍ទេ។ ហើយឥឡូវចុងសប្តាហ៍គេបិទទ្វារទៀត។ ពេលយើងធ្វើការជាមួយកូនក្តីយើង យើងត្រូវការឲ្យលោក ខៀវ សំផន គាត់អាចផ្តង់អារម្មណ៍បានផងដែរ។ គាត់អាយុជាង៨០ឆ្នាំហើយ ហើយសវនាការចប់ហើយ ធ្វើការក្រៅទៀត១ថ្ងៃពេញឲ្យប្រកបដោយប្រសិទ្ធភាពនោះមិនអាចទេ។

បាទទាក់ទងនឹងចម្លើយរបស់ជនជាប់ចោទ: ពេលវេលាដែលយើងចំណាយក្នុងសវនាការ ទាំងអស់នេះយើងបើកចំហតែម្តង។ លោកប្រធានបានលើកឡើងហើយថានៅពេលដែលសំណួរមានលក្ខណៈពាក់ព័ន្ធអាចបន្តធ្វើទៀតបាន។ អ៊ីចឹងខ្ញុំត្រូវតែពិភាក្សាជាមួយកូនក្តីរបស់ខ្ញុំត្រង់ចំណុចនេះ ពីព្រោះថាជាប្រធានបទមួយដ៏ធ្ងន់ធ្ងរណាស់។ ទាក់ទងទៅនឹងការបញ្ចប់ការពិភាក្សាដេញដោល ហើយនិងការធ្វើសារណា យើងត្រូវទទួល -- យើងចាំទទួលបញ្ជីឯកសារដែលមានលេខកូដ E3 (បើសិនជាខ្ញុំច្រឡំសូមតុលាការកែប្រែខ្ញុំ) ឯកសារទាំងឡាយដែលតុលាការយកទៅពិចារណាដើម្បីចេញសេចក្តីសម្រេចនិងដើម្បីជាមូលដ្ឋាននៃសេចក្តីសម្រេចនេះជាង -- ឯកសារជាង ៤.០០០ឯកសារ ហើយតុលាការនឹងត្រៀមចេញសេចក្តីសម្រេចលើចម្លើយជាលាយលក្ខណ៍អក្សរ ហើយនិងយើងនឹងឆ្លើយតបតាមរយៈសរសេរ តែឥឡូវនេះវាឡើងដល់ជាង ៥.០០០ឯកសារទៅហើយ ឯកសារ E3 នេះ។ អ៊ីចឹងយើងចង់បានបញ្ជីឯកសារទាំងអស់នេះ ហើយយើងបានដាក់សារណាជាច្រើនសុំឲ្យផ្តល់បញ្ជីឯកសារ E3 នេះមកឲ្យយើងៗសុំច្រើនដងណាស់មកហើយ។ ហើយរហូតមកដល់ថ្ងៃនេះៗ ការជូនដំណឹងអំពីក្រឡាបញ្ជីដែលយើងទទួលយកចុងក្រោយនោះ គឺថាខែកុម្ភៈនោះទេ។ គឺថាប៉ុន្មានខែក្រោយនោះបានៗទទួលបានប្រតិចារឹក បាទ សូមទោស។

[១០:៣១:០៨]

អ៊ីចឹងយើងដើម្បីធ្វើសារណាបញ្ចប់ការដេញដោលជាលាយលក្ខណ៍អក្សរនេះយើងត្រូវមានចំនួនបញ្ជីឯកសារហ្នឹង ឯកសារច្បាស់លាស់ដើម្បីយកមកពិចារណាសរសេរសារណារបស់យើង។ ត្រូវការពេលវេលាកែការបកប្រែផងដែរ មានបញ្ហាបកប្រែ។ យើងជាទូទៅនោះ យើងមានប្រតិចារឹកជាភាសាខ្មែរខុសពីប្រតិចារឹកភាសាបារាំង ឬអង់គ្លេស។ ខ្ញុំអាចឲ្យឧទាហរណ៍យ៉ាងស្រួល ពេលដែលខ្ញុំត្រៀមធ្វើក្នុងសវនាការ ខ្ញុំសុខចិត្តធ្វើការកត់សម្គាល់មួយ គឺថា E288។ ម្សិលមិញ ខ្ញុំនិយាយជាមួយសហភាតារបស់ខ្ញុំអំពីសំណៅជាភាសាខ្មែរ ដែលគាត់ទទួលបាន។ អ៊ីចឹងពេលហ្នឹងបានខ្ញុំដឹងថាពេលដែលខ្ញុំនិយាយថា មរណភាពរបស់ អៀង សារី នេះធ្វើឲ្យព្រះរាជអាជ្ញាគេមានកម្លាំងខ្លាំងជាងមុន ដើម្បីរៀបចំការងាររបស់គេ។ សរសេរជាភាសាខ្មែរនោះចេញទៅថា "ការមរណភាពរបស់លោក នួន ជា ធ្វើឲ្យខាងការពារក្ដីនេះមានកម្លាំងខ្លាំងជាងមុន"។ អ៊ីចឹងហើយនេះបញ្ហាបកប្រែធ្ងន់ធ្ងរណាស់ ហើយច្រើន។ ដូច្នេះយើងសូមមុននឹងសម្រេចលើពេលវេលា ទៅឲ្យយើងត្រៀមសរសេរសារណាបញ្ចប់ការដេញដោលនេះ គឺសុំរយៈពេល យើងសុំរយៈពេលបន្ថែម ពីព្រោះថាយើងត្រូវមានការងារច្រើនណាស់ ហើយវាមានសាក្សីប៉ុន្មាន ដូចអំមិញនេះដូច ៦០ប្លាយ ឥឡូវចូលដល់៨៧ អ៊ីចឹងការងារនេះសម្បើមណាស់។ អ៊ីចឹងបើយើងធ្វើការប្រៀបធៀបគ្នា ក្រុមការពារយើងនេះតូច ហើយធៀបនឹងព្រះរាអាជ្ញាគេធំណាស់។ អ៊ីចឹង យើងត្រូវការពេលវេលាបន្ថែមពីរសប្ដាហ៍ នៅពេលដែលយើងទទួលការសម្រាកពីរ ឬក៏បីខែ ដើម្បីសរសេរសារណាបញ្ចប់ការដេញដោលនេះ ខ្ញុំនិយាយថាត្រូវការ ៣០០ទំព័រ ហើយ៣០០ទំព័រនេះនោះចំពោះខ្ញុំនោះវាមិនច្រើនអីទេ។

[១០:៣៣:៤៥]

ខាងគេខាងណោះ គេធ្វើដូចគិតថាឲ្យបែង -- ដកៗហ្វណ្ឌូតចេញ។ ប៉ុន្តែចំពោះខ្ញុំ ១០០ទំព័រដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើនេះ ខ្ញុំមិនដឹងថា១០០ទំព័រនេះមិនដឹងជាយកសរសេរស្អីកើតទេ នៅក្នុងសំណុំរឿងដែលថាមានសាក្សីដល់ ៨៧នាក់នោះ ហើយមានសវនាការចំនួនជាង១០០ថ្ងៃ ហើយឯកសាររាប់ពាន់ទំព័រ រាប់ម៉ឺនទំព័រ។ អ៊ីចឹងដឹងថា -- ប៉ុន្តែចៅក្រមអ្នកសម្រេចអាហ្នឹង។ អ៊ីចឹងចំពោះសារណាចំពោះការពិភាក្សាចុងក្រោយធ្វើការសន្និដ្ឋានផ្ទាល់មាត់នោះ ត្រូវគិតពីពេល -- ពេលវេលាគិតចាប់ពីពេលដែលយើងទទួលបានអំណះអំណាងពីភាគីផ្សេងទៀតជាភាសាណាមួយ គឺថាភាសាខ្មែរជាភាសាបារាំង ព្រោះថាគាត់និយាយបារាំង ហើយនិងនិយាយខ្មែរ ហើយខាងគេនោះគេនិយាយអង់គ្លេស ភាគី

ផ្សេងទៀតនោះ។ អ៊ីចឹងការងាររបស់ក្រុមខ្ញុំនេះប្រើភាសាបារាំង។ អ៊ីចឹងជាពិសេសគឺថាភាសារបស់ជនជប់ចោទទេសំខាន់ជាងគេ។ អ៊ីចឹងគឺថាត្រូវការឲ្យយើង -- ឲ្យគិតពេលវេលាហ្នឹង គឺថាចាប់រាប់ពីពេលដែលទទួលបានការបកប្រែជាភាសាខ្មែរ ឬភាសាបារាំងសិន ហើយបន្ទាប់មកទៀត យើងត្រូវការពេល៤ថ្ងៃសម្រាប់និយាយដោយផ្ទាល់មាត់ដើម្បីបញ្ចប់ការពិភាក្សាដេញដោល។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១០:៣៥:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តី នួន ជា ក៏ចង់ឲ្យមានការកត់ត្រាជាប្រតិចារឹកថាយើងគាំទ្រទៅលើគោលគំនិតរបស់មេធាវីការពារក្តី ខៀវ សំផន ហើយនិងព្រះរាជអាជ្ញា ទាក់ទងទៅនឹងការទាមទារសុំចំនួនទំព័រ និងពេលវេលាសម្រាប់សារណារបញ្ចប់ការពិភាក្សាដេញដោលរបស់យើងខ្ញុំ។ ដូចដែលបានបញ្ជាក់រួចមកហើយអ៊ីចឹងខ្ញុំ មិនចង់និយាយឡើងវិញទៀតនោះទេ។ ត្រឹមតែ១០០ទំព័រក្របដណ្តប់ទៅលើឯកសារជាង ៦.០០០ និងរាប់ម៉ឺនសន្លឹក គឺវាហាក់ដូចជាមិនអាចធ្វើទៅបាននោះទេ។

ចំពោះករណីសំណុំរឿងកម្រិតជាតិ គឺវាអាចលើសពីនេះតទៀត គឺកម្រិតត្រឹមតែសំណុំរឿងណាំងៀន*(តាមសូរស័ព្ទ)* គឺវាអាចលើសកម្រិតហ្នឹងដែរ។ ប៉ុន្តែប្រសិនបើខ្ញុំចាំមិនខុសទេ គឺថាអង្គជំនុំជម្រះបានប្រកាសថា អាចផ្តល់មួយរយ-- ១៥០០ទំព័របន្ថែមទៀត ទាក់ទងទៅនឹងបញ្ហា លន់ នល់ ឬក៏ទាហាន លន់ នល់ ជាដើម។

[១០:៣៧:១៤]

ដើម្បី*(ឮមិនច្បាស់)* នូវទឡ្ហីករណ៍របស់មេធាវីការពារក្តីឲ្យបានត្រឹមត្រូវ ខ្ញុំគិតថា យើងត្រូវការបន្ថែមលើសពី ១០០ទំព័រនេះ។ ហើយខ្ញុំក៏មិនប្រាកដអំពីទឡ្ហីករណ៍ក្នុងការផ្តល់ ២៥០ទំព័រ ក៏ដូចជាការផ្តល់ពេលវេលាផងនោះទេ។ ខ្ញុំថា វាហាក់ដូចជាពិបាកយល់សម្រាប់សំណុំរឿងដ៏ស្មុគស្មាញបែបនេះ។ ខ្ញុំគិតថា នេះជារឿងក្តីដ៏ស្មុគស្មាញ និងខ្លាំងក្លាបំផុតបន្ទាប់ពីរឿងក្តីនៅ នូរ៉ឹមប៊ឺក និងរឿងក្តីទីក្រុងតូក្យូ។ ដូច្នេះ ខ្ញុំគិតថាការកម្រិតកំណត់យើងគួរតែធ្វើបាន ប៉ុន្តែការកម្រិតកំណត់ត្រឹម១០០ទំព័រ ជារឿងមួយដែលថាធ្ងន់ធ្ងរបំផុត។ ដូច្នេះហើយ ដើម្បីជាកំណត់ត្រាប្រតិចារឹក យើងស្នើសុំឲ្យមានការផ្តល់ឱកាសដល់យើង ដើម្បីបញ្ចេញនូវទឡ្ហីករណ៍ឲ្យបានគ្រប់គ្រាន់ ដែលមិនត្រូវមានការកម្រិតកំណត់បែបនេះទេ។

ខ្ញុំមិន -- គឺថាយើងចង់ឲ្យមានការផ្តល់ពេលវេលា ឬក៏ផ្តល់នូវទំព័រ មិនមែននិយាយអ្វីដែលមិនពាក់ព័ន្ធនោះទេ គឺយើងនឹងលើកឡើងនូវអ្វីដែលពាក់ព័ន្ធ។ ដូច្នេះជាសេចក្តីសន្និដ្ឋាន គឺថាខ្ញុំ គឺខាងមេធាវីការពារក្តី នួន ជា គាំទ្រទៅដល់គោលគំនិតរបស់ខាងមេធាវី ខៀវ សំផន មិនត្រឹមតែការស្នើសុំបន្ថែមពេលវេលាទេក្នុងការបញ្ចេញមតិយោបល់ទេ គឺសូមបន្ថែមទំព័រផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:៣៨:៥៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមត្រឡប់មកនិយាយអំពីសំណើរបស់សហព្រះរាជអាជ្ញាដែលសំណើនោះ គឺថាចង់ដាក់ដាច់ដោយឡែកពីគ្នានៃសារណារបញ្ចប់ការដេញដោល ហើយនិងហ្វូតណូត និងកំណត់ហេតុជើងទំព័រ។ ហើយអ៊ីចឹងខ្ញុំចង់ដឹង តើសហព្រះរាជអាជ្ញាដឹងថាចំនួនទំព័រប្រហាក់ប្រហែលប៉ុន្មានដែរឬទេ ដើម្បីបញ្ចូលកំណត់ហេតុជើងទំព័រនេះ? ខ្ញុំចង់និយាយលើករឿងនេះឡើងហ្នឹង ព្រោះថា ធម្មតាកំណត់ហេតុជើងទំព័រនេះសរសេរអក្សរតូចៗ អ៊ីចឹងត្រូវការពេលវេលាច្រើនណាស់ដើម្បីបកប្រែ។ ហើយខ្ញុំសូមបញ្ជាក់ផងដែរថា នៅពេលដែលយើងនិយាយឲ្យបានលម្អិតអំពីជើងទំព័រនេះ កំណត់ហេតុជើងទំព័រនេះ មិនមែនត្រឹមតែថាផ្តល់យោងជា -- ក្នុងភាសាដែលយើងប្រើនោះទេ តែយើងត្រូវធ្វើយ៉ាងណាឲ្យយោងនេះស៊ីសង្វាក់គ្នារវាងភាសាទាំងបីហ្នឹង។ បើមិនអ៊ីចឹងទេ យើងនឹងអាចមានការភ្ញាក់ផ្អើល។ ក៏ប៉ុន្តែការពីដំបូងនោះ យើងគិតថានឹងដាក់សារណាបញ្ចប់នោះ ទៅជាមួយភាសាទេ។ អ៊ីចឹងចំណុចនេះសំខាន់ណាស់។ តើលោកព្រះរាជអាជ្ញា លោកមានថាដឹងថាចំនួនទំព័រនៃកំណត់ហេតុជើងទំព័រនេះ ប្រហាក់ប្រហែលប៉ុន្មានទេ?

[១០:៤០:៤៣]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណចៅក្រម ឡាវែន៍។ ជាដំបូងខ្ញុំមិនប្រាកដថាតើជាបញ្ហាបកប្រែ ឬក៏អត់នោះទេ ប៉ុន្តែមេធាវី -- ប៉ុន្តែខាងព្រះរាជអាជ្ញាមិនមែនបញ្ជាក់ថាជើងទំព័រ និងជើងឯកសារ គួរដាក់ដាច់ពីគ្នានោះឡើយ។ គឺថាយើងគ្រាន់តែចង់បង្ហាញថា ឲ្យជើងទំព័រហ្នឹងវាទៅលេខយោងចុងឯកសារប៉ុនណោះ។ ទាក់ទងទៅនឹងលទ្ធភាពនៃការបញ្ជាក់អំពីប្រភពនៃភស្តុតាងជាបីភាសានោះ។

ពាក់ព័ន្ធទៅនឹងការបកប្រែភាសាបារាំង អង់គ្លេស និង ខ្មែរ នៅក្នុងសំណុំរឿង០០១ គឺថាខាងព្រះរាជអាជ្ញាមិនអាចធ្វើឲ្យបានទាន់ពេលវេលាទៅលើបញ្ហាទាំងអស់នេះ។ ដូច្នេះខ្ញុំសូមលើកឡើងថាវាមិនអាចធ្វើឡើងបានទេនៅក្នុងរយៈពេលខ្លី ព្រោះថាយើងត្រូវការរាប់ខែឯណោះ ដើម្បីធ្វើការងារទាំងអស់នេះ។ ហេតុដូច្នេះហើយទើបនៅក្នុងសំណុំរឿងទី១ ភាគីនីមួយៗដាក់តែមួយភាសា មិនមែនទាំងបីភាសានោះ ព្រោះថាដោយសារបញ្ហាបុគ្គលិក។ គឺថាបញ្ហាដែលយើងត្រូវដោះស្រាយ គឺវាច្រើនជាងចំនួនបុគ្គលិកដែលអាចដោះស្រាយបាន។ ដូច្នេះវាមិនអាចធ្វើទៅបាននោះទេ ប្រសិនបើយើងចង់ឲ្យមានការនិយាយយោងឲ្យត្រូវទាំងបីភាសា ដាក់លេខយោងឲ្យត្រូវទាំងបីភាសា។ ដូច្នេះ ខ្ញុំនិយាយនេះមិនមែនចង់មានន័យថា ជាការស្នើសុំឲ្យបង្កើនចំនួនបុគ្គលិកនោះទេ។

ពាក់ព័ន្ធទៅនឹងសារណា ខាងសហព្រះរាជអាជ្ញាមានការទទួលខុសត្រូវចំនួនពីរ។ ទី១គឺថាធានាថាអ្វីទាំងអស់ដែលបានដាក់ គឺថាគឺជាការបង្ហាញឲ្យលើសពីវិមតិសង្ស័យដូចដែលយើងបានបញ្ជាក់ថ្ងៃហ្នឹង ហើយចំណែកទី២ គឺថាៗធានាថា ឲ្យភាគីទាំងអស់មានសិទ្ធិគ្រប់គ្រាន់ក្នុងការនិយាយនូវអ្វីដែលខ្លួនចង់និយាយ។ ក្នុងនាមជាសហព្រះរាជអាជ្ញាយើងមិនជំទាស់ទៅលើសំណើ២៥០ទំព័រនោះទេ។ ប៉ុន្តែជំទាស់ទៅលើការស្នើសុំថែម៥០ទំព័របន្ថែមរបស់ព្រះរាជអាជ្ញា ដែលថាឲ្យត្រឹមតែ២០០ទំព័រនោះ។ ដូច្នេះ យើងជំទាស់ទៅលើបញ្ហានេះ។ ព្រោះថាទាំងអស់គ្នាគួរតែទទួលបានឱកាសក្នុងការស្តាប់នៅក្នុងសំណុំរឿងទាំងអស់នេះ។

[១០:៤៣:៣២]

ខ្ញុំគិតថា វាមានដំណោះស្រាយមួយ ប៉ុន្តែមិនប្រាកដថាអាចដោះស្រាយបញ្ហាបានទាំងអស់នោះទេ។ គឺការកែប្រែលេខយោងជើងទំព័រទៅជាលេខយោងចុងឯកសារទៅវិញ។ ចំណុចមួយទៀត ដែលខ្ញុំចង់និយាយយោងផងដែរ គឺថាយើងជិតដល់ពេលបញ្ចប់សវនាការរួចទៅហើយ ហើយយើងឮមេធាវីការពារក្តី ខៀវ សំផន មួយសាទៀត អំពីបញ្ហាមួយចំនួន ហើយក្នុងពេលនេះ គេតវ៉ាអំពីបញ្ហាដែលថាខ្លួនមិនមានធនធានគ្រប់គ្រាន់។ ក្នុងសំណុំរឿងនេះ ខ្ញុំមិនដែលមេធាវី ខៀវ សំផន និយាយ មិនដែលម្តងណាសោះ ដែលថាខ្លួនមានពេលវេលគ្រប់គ្រាន់ មានធនធានគ្រប់គ្រាន់ មិនដែលសោះ ហើយគេតែងតែនិយាយថា ខាងព្រះរាជអាជ្ញាមានចំនួនបុគ្គលិក ធនធានច្រើនលើសពីខាងការពារក្តី។ ប៉ុន្តែដើម្បីជាកំណត់ត្រាប្រតិចារឹក ក៏ដូចជាដើម្បីឲ្យសាធារណជនបានយល់ គឺថាសេចក្តីប្រកាសដែលថាព្រះរាជអាជ្ញាធ្វើការផ្លាស់ប្តូរគ្នា ប្តូរវេនគ្នាទៅវិញទៅមក គឺជាការពិត គឺវាជាការតម្រូវ។ ប៉ុន្តែចំពោះមេធាវី

ការពារក្តី ខៀវ សំផន ក៏ដូចគ្នាដែរ គាត់មានមេធាវីអន្តរជាតិ៣នាក់ គឺថាមេធាវីអន្តរជាតិមានដល់ទៅបីរូបឯណោះ លោក ហ្សាក់ វែកហ្សេស ក៏នៅក្នុងសំណុំរឿងក្តីនេះដែរ គឺចាប់តាំងពីដំបូងមក។ ហើយគាត់ប្រហែលជាកំពុងតែចាប់ផ្តើមសរសេរសារណាបញ្ចប់ការពិភាក្សាដេញដោលរួចទៅហើយ។ ហើយពួកគាត់មានមេធាវី សហមេធាវីបន្ថែមទៀតដែលសហមេធាវីទាំងអស់នេះកំពុងតែរៀបចំនូវពេលដែលលោក វែកគែន ចូលរួមសវនាការនេះ។ ដូច្នេះហើយ ខ្ញុំគិតថាមិនមែនបានន័យថា ព្រះរាជអាជ្ញាធ្វើអ្វីខុស ឬក៏ផ្សេងពីក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្វើនោះទេ។

ហើយចំណុចទៀតដែលខ្ញុំចង់បង្ហាញនៅក្នុងកំណត់ត្រាប្រតិចារឹក គឺថាខាងព្រះរាជអាជ្ញាមិនមែនត្រឹមតែចោទប្រកាន់ទៅលើជនជាប់ចោទតែមួយរូបនោះទេ គឺចោទប្រកាន់ទៅលើជនជាប់ចោទច្រើនរូប។ ហើយក្រុមការពារក្តីគឺមានក្រុមផ្សេងៗគ្នា។ ហើយយើងក៏ធ្វើការគ្រប់គ្រងទៅលើរឿងក្តីពីរបន្ថែមទៀត គឺរឿងក្តី០០៣ និង០០៤។ យើងបានធ្វើការគណនានៅពេលព្រឹកនេះ គឺថាធនធានរបស់ខាងព្រះរាជអាជ្ញា គឺមិនធំជាងខាងមេធាវីការពារក្តីឡើយ ប្រសិនបើមេធាវីការពារក្តីរួមបញ្ចូលគ្នាដោយយើងគិតផងដែរថា ព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវនៅក្នុងសំណុំរឿងផ្សេងៗទៀត។

[១០:៤៦:១២]

ហើយខាងព្រះរាជអាជ្ញាត្រូវធ្វើការដោះស្រាយទៅលើសំណុំរឿងផ្សេងៗទៀត ក្រៅពីសំណុំរឿង០០២។ ដូច្នេះហើយខ្ញុំសូមបញ្ជាក់ថា នេះមិនមែនបង្ហាញពីភាពមិនស្មើគ្នានៃការតទល់នោះឡើយ។ វិសមភាពនៃការតទល់រឿងក្តីនោះឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ និងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចប្រជុំរបស់យើង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៧ នាទី ដល់ម៉ោង ១១:០៦ នាទី)*

[១១:០៦:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចប្រជុំពិភាក្សារបស់យើងតទៅទៀត។ ជាតទៅនេះអំពីកាលបរិច្ឆេទកំណត់ពេលវេលាសម្រាប់ទាមទារសំណង។ ហើយជាចុងក្រោយនិងតារាងពេលវេលាសម្រាប់សវនាការនៅពេលខាងមុខ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមានការបញ្ជាក់អំពីកាលកំណត់កាលបរិច្ឆេទសម្រាប់ការទាមទារសំណងជាចុងក្រោយរបស់ខ្លួន និងកាលវិភាគពេលវេលាសម្រាប់សវនាការលើសំណុំរឿង០០២ នាពេលខាងមុខ។ ដូចដែលបានបញ្ជាក់រួចហើយនៅក្នុងសេចក្តីសម្រេចលើកទី២ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបើកសវនាការនាពេលអនាគតបន្តទៀត គឺអាស្រ័យទៅលើភវនីយហេតុនាពេលខាងមុខដូចជាបញ្ហាសម្បទាចូលរួមក្នុងសវនាការរបស់ជនជាប់ចោទដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២ ដែលបច្ចុប្បន្ននេះគឺមិនអាចដឹងបានថា -- ហើយដែលជាបញ្ហាដែលមិនអាចគ្រប់គ្រងបានដោយអង្គជំនុំជម្រះនោះឡើយ។ ហេតុដូច្នេះអង្គជំនុំជម្រះនឹងរៀបចំកិច្ចប្រជុំមួយនៅចុងឆ្នាំ២០១៣ ដើម្បីវាយតម្លៃលើស្ថានភាពនេះឡើងវិញ។ អំពីកាលបរិច្ឆេទ ផុតកំណត់សម្រាប់ដាក់សំណើទាមទារសំណងក៏នឹងត្រូវប្រាប់ឱ្យដឹងនាពេលក្រោយនៅក្នុងឆ្នាំនេះ ដែលវាទំនងជាថាការដាក់សំណើចុងក្រោយសូមទាមទារសំណងមិនត្រូវបានរំពឹងថានឹងធ្វើឡើងភ្លាមៗនោះទេ។ អង្គជំនុំជម្រះនឹងបញ្ជាក់ជូននៅក្នុងរយៈពេលដ៏ខ្លីខាងមុខនេះថាតើសំណើជាអាទិភាពរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏សុំឱ្យមានការអនុវត្តតាមរយៈការចាត់ចែងគម្រោងត្រូវបានយកមកពិចារណាដោយអង្គជំនុំជម្រះឬយ៉ាងណា ដើម្បីផ្តល់ប្រសិទ្ធភាពឱ្យបានសមស្របទៅនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលរងដោយសារតែឧក្រិដ្ឋកម្មដូចដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ស្របតាមវិធាន ២៣ស្ទួន (៤)(៣)ចំណុច ខ នៃវិធានផ្ទៃក្នុង។

ស្ថានភាពនៃការបកប្រែភាសាឯកសារ កាលពីថ្ងៃទី២៨ ខែកុម្ភៈ និងថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញានិងសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនអាចនឹងជួបប្រទះការលំបាកនៅក្នុងការឆ្លើយតបទៅនឹងកាលបរិច្ឆេទចុងក្រោយដែលអង្គជំនុំជម្រះកំណត់ត្រឹមថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ សម្រាប់ការបញ្ជូប់ សំណើសុំឱ្យបកប្រែទាំងអស់ដែលមិនទាន់បានបកប្រែរួចហើយ។

ចាប់តាំងពីពេលនោះមកភាគីទាំងពីរបានបញ្ជាក់ថាមានការជឿនលឿនទៅមុខគួរឲ្យកត់សម្គាល់ ពីព្រោះសំណើសុំឲ្យបកប្រែទាំងអស់ដែលពុំទាន់បានបកប្រែរួចរាល់នោះ។ អង្គជំនុំជម្រះក៏បានបញ្ជាក់ជូននៅមុនកិច្ចប្រជុំរៀបចំសវនាការថា អង្គជំនុំជម្រះបានយល់ស្របទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាថាប្រភេទជាក់លាក់នៃឯកសារមួយចំនួនមិនតម្រូវឲ្យធ្វើការបកប្រែនោះទេ ដូចជារូបថតដ្យាក្រាម គំនូសបង្ហាញ ឬក៏ទីតាំង និងសម្រង់ខ្សែវីដេអូដែលបានចាក់បង្ហាញនៅក្នុងតុលាការដែលបានបកប្រែនៅក្នុងប្រតិចារឹករួចហើយ។

អង្គជំនុំជម្រះយល់ស្របនិងបានបញ្ជាក់បន្ថែមទៀតថា អង្គជំនុំជម្រះនឹងពិចារណាទៅលើសំណើសុំទាំងឡាយណាដែលសមហេតុសមផល ដែលធ្វើឲ្យការកកស្ទះការបកប្រែភាសាអាចត្រូវដោះស្រាយបានរួចរាល់ ហើយយូរបំផុតនៅដំណាក់កាលនៃការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នូវការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២/០១។ តើភាគីអាចបញ្ជាក់ឲ្យបានច្បាស់ទេថា តើបញ្ហាបកប្រែភាសាដែលពុំទាន់បានធ្វើរួចរាល់អាចនឹងត្រូវបានដោះស្រាយ និងទោះជាក្នុងករណីណាក៏ដោយអាចនឹងត្រូវបានបញ្ចប់នូវត្រឹមកាលបរិច្ឆេទការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ មានន័យថាដើមខែតុលា ឆ្នាំ ២០១៣ បានដែរឬទេ?

សហព្រះរាជអាជ្ញា សូមអញ្ជើញលោក!

[១១:១១:១៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ចម្លើយដែលខ្លីនោះ គឺថាខ្ញុំជឿថាគេនឹង -- គេអាចបញ្ចប់ការបកប្រែនូវឯកសារសំខាន់ៗ ភស្តុតាងសំខាន់ៗទាំងអស់ដែលភាគីពឹងផ្អែក។ គឺមានការអភិវឌ្ឍតាំងពីការដាក់ឯកសារមក យើងបានចង្អុលបង្ហាញនៅក្នុងការដាក់សុំរបស់យើងថា “ការប៉ាន់ប្រមាណឯកសារនោះគឺត្រូវតែមានការបកប្រែជាដើមនោះ”។ ខ្ញុំគិតថា យើងសង្ឃឹមថាឯកសារភាគច្រើនទាំងអស់នោះគឺថាអាចបញ្ចប់នៅពេលនេះហើយ។ ប្រហែលថាមានការលំបាករបស់តុលាការនោះដែរ នៅក្នុងសម័យអន្តរកាលមួយនៅក្នុងសម័យកាលដែលថាៗ ការបកប្រែវាមិនបានគ្រប់គ្រាន់។ ដោយហេតុថាគេមិនអាចបញ្ចប់ទាំងស្រុងទេ ប៉ុន្តែខ្ញុំយល់ឃើញថាឯកសារមួយចំនួនត្រូវបានបកប្រែនៅក្នុងកម្រិតមួយដែលសមស្រប ដោយមានការលើកលែងខ្លះដែលថាតុលាការបានកំណត់ហួសហេតុបញ្ជាក់ថានៅក្នុងការដាក់ឯកសាររបស់យើងនោះ។

អ៊ីចឹងខ្ញុំសូមជូនព័ត៌មានជាក់លាក់មួយចំនួនអំពីចម្លើយរបស់សាក្សី ហើយនិងការស្នើ ការតវ៉ា របស់សហព្រះរាជអាជ្ញាហ្នឹង យើងបានស្នើ ហើយត្រូវបានដាក់ជូនចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវបានទទួលស្គាល់។ ហើយចំនួនរបស់ខ្ញុំប្រហែលជា ១០៥០បាទ --១.៥០០ ហើយជាអាចនឹងមានជាភាសាអង់គ្លេស ហើយប្រហែលជា ១០៥០គឺថាមានជាភាសាខ្មែរ។ អាចនឹងគិតថាឯកសារដែលជាសរសេរផ្ទាល់ដៃមិនទាន់បានបកប្រែ ប៉ុន្តែ១០៥០នោះគឺមានតែ១៩ មិនទាន់បកប្រែទៅជាភាសាបារាំង។

[១១:១២:៤៩]

ដូចគ្នានេះដែរ នៅពេលខ្ញុំមើលឯកសារ E3 ដែលត្រូវបានទទួលស្គាល់រួចហើយនោះ ដោយអង្គជំនុំជម្រះនោះ គឺដោយដកចេញនូវឯកសារ ដូចជាឯកសារវីដេអូ រូបថត ផែនទី ដែលតុលាការបានទទួលស្គាល់ហើយនោះ ជាឯកសារចំនួនតូចទេដែលត្រូវបកប្រែនោះ។ ដូចដែលខ្ញុំជម្រាបជូនហ្នឹងគឺថាមានបញ្ហាមួយចំនួនទៀតដែលយើងសូមការណែនាំពីតុលាការនោះ បញ្ហាមួយដែលមាននៅក្នុងឯកសារដែលត្រូវបកប្រែនោះគឺថាបញ្ជីអ្នកទោសនៅ ស-២១។ ឥឡូវនេះប្រហែលជា ១៥០ នៃឯកសារដែលមិនទាន់បានបកប្រែទៅជាភាសាទាំងបីនោះ គឺថាជំហររបស់យើងខ្ញុំគឺឯកសារទាំងអស់នេះគឺថាគឺមានច្បាប់ដើមជាភាសាខ្មែរ គឺថាបញ្ជីឈ្មោះមនុស្ស។ ប្រសិនបើយើងពិនិត្យមើលឯកសារមួយចំនួនដែលមានជាភាសាបារាំង ហើយនិងអង់គ្លេសជាបកប្រែនោះ គឺថាកាត់បានពាក់កណ្ដាលនោះ។ ដូច្នេះហើយមានតែពាក់កណ្ដាលទេដែលត្រូវការបកប្រែ។ អ៊ីចឹងសំណើនៅក្នុងការដាក់ឯកសាររបស់ខ្ញុំហ្នឹងគឺថា ចំពោះឯកសារដូចដែលខ្ញុំបាននិយាយដូចជាបញ្ជីឈ្មោះមនុស្សនេះ គឺអាចនឹង ភាគីគឺអាចនឹងទទួលស្គាល់ ហើយអាចនឹងយល់ថាជាភស្តុតាងប្រសិនបើវាមានជាភាសាខ្មែរច្បាប់ដើម ឬក៏មានអាចជាបកប្រែទៅបារាំង ឬអង់គ្លេសជាដើមនោះ គឺជាការគ្រប់គ្រាន់ទៅហើយ គឺថាអាចធ្វើឲ្យមានភាពងាយស្រួលនៅក្នុងឲ្យ ស៊ី.អឹម.អេស ហ្នឹងអាចធ្វើការបកប្រែក្នុងរយៈពេល១ខែ ឬក៏២ខែនោះ។ ប្រហែលជាគេអាចមានធនធានច្រើនក្នុងការបកប្រែទៅជាភាសាអង់គ្លេស ឬក៏ទៅជាភាសាបារាំងនោះ គឺថាគេអាចនឹងប្រាប់មកយើងថា ធនធាននោះមាន ឬមិនមាន។ ប៉ុន្តែយើងត្រូវតែមានលទ្ធភាពប្រាប់ពួកគាត់ថា ទាក់ទងទៅនឹងឯកសារប្រភេទនេះគឺថាអាចជាភាសាខ្មែរ ឬក៏អាចបកទៅជាបារាំង ឬក៏ជាភាសាអង់គ្លេស អាហ្នឹងក៏ជាអាចជាការល្អដែរ។ ក្រៅពីនេះ ខ្ញុំជឿថាយើងមានស្ថានភាពល្អក្នុងការបកប្រែនេះ។ គឺមានបញ្ហាមួយទៀត គឺថាអង្គជំនុំជម្រះគប្បីតែជ្រាបពីរឿងនេះនោះគឺថា គឺយើងមានឯកសារវែងៗមួយចំនួនដូចជា សៀវភៅដែលសរសេរដោយ ហ្វីលីព ស្សូត, ឯកសារវែងដូចជា របាយការណ៍ ហ្វីប៊ីស ប្រចាំខែ

ដែលថាមានបកប្រែទៅជាមួយផ្នែកដែលគេចាត់ទុកថាពាក់ព័ន្ធតែប៉ុណ្ណោះទេ។ ប៉ុន្តែសេចក្តីដកស្រង់មួយចំនួនត្រូវបានប្រើនៅតុលាការ ត្រូវបានអាន ហើយនិងបានបកប្រែរួចហើយដែរ។

[១១:១៥:៤៣]

សេចក្តីរំពឹងរបស់ខ្ញុំ គឺថាមិនមែនជាតំណាងព្រះរាជអាជ្ញាទេ ប៉ុន្តែពីមេធាវីការពារផងដែរ គឺថាមានផ្នែកខ្លះគឺមានការទទួលស្គាល់ មានសេចក្តីដកស្រង់ដែលខ្ញុំចង់ពឹងផ្អែកពីឯកសារដ៏វែង ហើយមិនទាន់បានបកប្រែទេ។ នេះជាផ្នែកមួយដែលភាគីធ្វើនូវសេចក្តីសារណាររបស់ខ្លួននោះ។ ពួកគាត់ចង់សម្រេចចិត្តថា ត្រូវតែទទួលស្គាល់ថាយកតែទំព័រផ្នែកនេះទេដែលមិនទាន់បានបកប្រែ។ នេះហើយគឺថាអាចនឹងមានប្រយោជន៍។ យើងត្រូវមានភាពបត់បែនដែលត្រូវតែយើងសម្រេចយកដើម្បីកែតម្រូវបញ្ហាឱ្យវាមានស្រួល។ ដូច្នេះ ខ្ញុំជម្រាបតុលាការ គឺថាមានផ្នែកមួយគឺថាអាចនឹងកើតឡើងនៅពេលដែលភាគីរៀបចំសារណា ប៉ុន្តែខុសពីចំណុចទាំងអស់នោះ គឺការបកប្រែមានស្ថានភាពល្អទេ។ សូមជម្រាបបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយទៅសំណួររបស់លោកប្រធាន និងខ្ញុំសូមអនុញ្ញាតនិយាយដោយសង្ខេបអំពីចំណុចមួយចំនួនដែលលោកប្រធានបានលើកឡើងទាក់ទងទៅនឹងសំណង។

ទាក់ទងនឹងបញ្ហាបកប្រែ ខ្ញុំគិតថា ចំពោះយើង យើងថាអាចមានឯកសាររបស់យើងទាំងអស់ដែលត្រូវ -- នឹងត្រូវបានបកប្រែក្នុងរយៈពេល២ខែទៀត ពី១ខែទៅ១ខែទៀត។ អានេះបើតាមអង្គភាពបកប្រែប្រាប់មកយើង។ ហើយយើងនៅមានឯកសារ ៦០ -៧០ ទៀតដែលត្រូវបកប្រែ ហើយចំនួនទំព័រប្រហែលជា៣៧០ទំព័រ។ ដូច្នេះយើងនឹងទទួលបានការបកប្រែទាំងអស់នេះនៅក្នុងពេលឆាប់ៗខាងមុខ។ ខ្ញុំគាំទ្រការកត់សម្គាល់របស់សហព្រះរាជអាជ្ញាថា ត្រូវមានភាពបត់បែន ហើយនិងលទ្ធភាពទទួលបានការបកប្រែជាភាសាបារាំង ឬក៏អង់គ្លេស ដើម្បីកុំឱ្យពន្យារពេលសវនាការ។ នេះខ្ញុំសូមបញ្ចប់និយាយពីការបកប្រែ។

[១១:១៧:៥៣]

ហើយខ្ញុំ -- បន្ទាប់ទៀតខ្ញុំត្រូវកត់សម្គាល់មួយទៀត។ ខ្ញុំយល់ពីការចង្អុលបង្ហាញរបស់តុលាការក៏ប៉ុន្តែការព្រួយបារម្ភរបស់យើង គឺថាគឺសិទ្ធិដែលថានឹងមានបញ្ហាចោទឡើងនៅពេលដែលមានសំណុំ

រឿង០៣, ០៤ ទៀត អឺ ០២/០១, ០២/០២។ អ្វីដែលយើងចង់ដឹង គឺថាតើអង្គជំនុំជម្រះមានគោលជំហរទាក់ទងទៅនឹងអាជ្ញាអស់ជំនុំនៅពេលដែលមានដំណាក់កាលកាត់សេចក្ដីលើកទី២ហ្នឹង។ តើទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍អីជាដើមនេះ សិទ្ធិបណ្ដឹងឧទ្ធរណ៍។ អ៊ីចឹងយើងចង់ដឹងថា តើអង្គជំនុំជម្រះមានចម្លើយតាមផ្លូវច្បាប់ទាក់ទងទៅនឹងសមត្ថកិច្ចរបស់ខ្លួនដែរឬក៏អត់? នេះគឺជាជួយសម្រួលឲ្យយើងធ្វើការត្រៀមសំណុំរឿងបន្ទាប់ទៀត។ នេះបើតាមកថាខណ្ឌ៥៤, ៥៥ -- ១៥៤, ១៥៥។ តើអង្គជំនុំជម្រះអាចជម្រាបថា តើអាចផ្ដល់បញ្ជាក់មកឲ្យយើងមុន ឬក្រោយសារណាបញ្ចប់ការដេញដោល។

[១១:១៩:២២]

ទាក់ទងទៅនឹងសំណាង បាទ ខ្ញុំសូមទោស ខ្ញុំអង្គាល់មុននឹងហ្នឹងលោកប្រធាន ការកត់សម្គាល់របស់លោកអំមិញនេះ ខ្ញុំមិនយល់ពីសំណួររបស់លោកប្រធានទេ ទាក់ទងទៅនឹងមាត្រា២៣(៣) ខ្ញុំយល់មិនច្បាស់។ អ៊ីចឹងខ្ញុំសូមឲ្យតុលាការជួយបំភ្លឺកន្លែងថា មាត្រា ២៣ -- វិធាន ២៣(៣)(ខ) ទាក់ទងទៅនឹងបទចោទប្រកាន់ទាំងអស់នេះ។ សូមលោកប្រធានជួយបំភ្លឺ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

ខ្ញុំគិតថា អ្វីដែលចែងនៅក្នុងវិធាននេះគឺ បើសិនជាគម្រោងដែលស្នើមកហ្នឹង គឺគម្រោងអត្ថិភាពនិងគម្រោងនេះនឹងត្រូវ -- អង្គជំនុំជម្រះនឹងគិតថា ជាគម្រោងដែលផ្ដល់ការ -- ផ្ដល់សំណងមានប្រសិទ្ធ-ភាពទៅជនរងគ្រោះនៃបទឧក្រិដ្ឋដែលមានចែងនៅក្នុងសំណុំរឿង០០២/១ ស្របតាមវិធាន២៣(ខ)។ បាទ នេះជាអ្វីដែលលោកប្រធានបានលើកឡើងអម្បាញ់មិញ ដែលការបកប្រែចេញពីភាសាមិនសូវច្បាស់លាស់។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៣:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយន៍ ដើម្បីឆ្លើយបំភ្លឺតបទៅនឹងការសំណើសុំបំភ្លឺបញ្ជាក់របស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើងអម្បាញ់មិញនេះ ពាក់ព័ន្ធ

ជាមួយនឹងបញ្ហានៃអាជ្ញាអស់ជំនុំ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

នៅក្នុងការយោងទៅរកបញ្ហាទី២ដែលសហមេធាវីនាំមុខបានលើកឡើង ទាក់ទងទៅនឹងថាតើអង្គជំនុំជម្រះមានជំហរដូចម្តេចទៅបញ្ហាច្បាប់ ទាក់ទងទៅនឹងអាជ្ញាអស់ជំនុំនេះ ទៅលើរឿងក្តី០០២/០២ ហើយនិងបន្តទៅទៀតនោះ នៅក្នុងសវនាការបន្តបន្ទាប់នោះ។ អង្គជំនុំជម្រះបានចាត់ទុកថា បញ្ហានេះដូចជាឆាប់ពេកនឹងពិភាក្សានៅពេលនេះ។

ចំណុចទី១នោះ ដោយហេតុថាយើងត្រូវរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះសាលាកំពូលសិន ដើម្បីបំភ្លឺនូវបញ្ហាមួយចំនួនបែបនេះ។ ប៉ុន្តែចំណុចទី២ យើងបានចង្អុលបង្ហាញជូនភាគីរួចហើយថា បន្ទាប់ពីការដេញដោលបញ្ចប់នូវរឿងក្តី០០២/០១នោះ យើងនឹងធ្វើការប្រជុំរៀបចំសវនាការលើបញ្ហាមួយចំនួនទាក់ទងទៅនឹងថាតើបញ្ហាអាជ្ញាអស់ជំនុំនេះត្រូវលើកឡើងដែរឬទេ? តើភាគីអាចលើកឡើងបានទេនូវចំណុចពេលនោះ?

[១១:២៤:៥៨]

ខ្ញុំសង្ឃឹមថា អាចជាចម្លើយគ្រប់គ្រាន់ទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។

បាទជាបញ្ហាជាបន្តទៅនេះ គឺបញ្ហាបុគ្គលផ្សេងទៀតដែលត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្មនៅក្នុងសវនាការ។ មុននឹងពិភាក្សាលើបញ្ហានេះ អង្គជំនុំជម្រះសូមរំឭកថា ភាគីត្រូវប្រើរហស្សនាមក្នុងការពិភាក្សាលើសាក្សីនីមួយៗ និងមិនត្រូវបញ្ចេញនូវព័ត៌មានដែលអាចនាំឲ្យមានការសន្និដ្ឋានទៅលើអត្ត-សញ្ញាណពិតប្រាកដរបស់សាក្សីឡើយ លើកលែងតែសាក្សីដែលបានធ្វើសក្ខីកម្មរួច។

សំណើសុំពាក់ព័ន្ធទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើសុំរួចហើយនៅមុនកិច្ចប្រជុំរៀបចំសវនាការ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឲ្យមានការបញ្ជាក់អំពីស្ថានភាពរបស់អ្នកជំនាញ ស្ទីវិន ហេដឌ័រ ដែលបានស្នើសុំរួចមកហើយនោះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា កិច្ចខិតខំប្រឹងប្រែងរបស់អង្គភាពគាំពារសាក្សីអ្នកជំនាញ ដើម្បីធានាឲ្យមានការផ្តល់សក្ខីកម្មរបស់គាត់ទោះជាក្នុងឋានៈជា

អ្នកជំនាញក្តីឬជាសាក្សីក្តី ឬកំពុងតែបន្តនៅឡើយ។ ភាគីទាំងអស់នឹងទទួលបានការជូនដំណឹង និងការផ្តល់មតិយោបល់នៅក្នុងពេលវេលាដ៏សមស្របមួយ ស្តីពីកាលបរិច្ឆេទនៃសក្ខីកម្មរបស់គាត់ ប្រសិនបើការផ្តល់សក្ខីកម្មរបស់គាត់អាចត្រូវធ្វើបានមែននោះ។

[១១:២៦:២៩]

ទាក់ទងទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា សុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-186 អង្គជំនុំជម្រះសូមជម្រាបថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ នឹងធ្វើការវាយតម្លៃឡើងវិញអំពីហានិភ័យក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីមានសំណើសុំវិធានការការពាររបស់គាត់នៅក្នុងសវនាការភ្លាមៗដែលមិនបានរំពឹងទុកជាមុននោះ។

ពេលនេះនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ថាតើដើមបណ្តឹងរដ្ឋប្បវេណីTCCP-186 នឹងយល់ព្រមមកផ្តល់សក្ខីកម្មឡើងវិញនៅចំពោះមុខអង្គជំនុំជម្រះដែរឬអត់នោះទេ។ ហេតុដូច្នេះអង្គជំនុំជម្រះមិនទាន់ធ្វើសេចក្តីសម្រេចឱ្យបានច្បាស់លាស់ទៅលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យកោះហៅបុគ្គលរូបនេះឡើងវិញនៅឡើយទេ។ ហើយផ្ទុយទៅវិញ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ចំពោះសំណើនេះ។ ហើយប្រសិនបើក្រុមមេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសូមឱ្យកោះហៅបុគ្គលរូបនេះឡើងវិញនោះ ខ្លួនអាចលើកឡើងនៅក្នុងការជំទាស់នេះដោយផ្ទាល់មាត់នាពេលនេះបាន។

[១១:២៨:០០]

**លោក អាកទួរ វែកកែន៖**

បាទសូមអភ័យទោសលោកប្រធាន។ ខ្ញុំស្តាប់ឃ្លាលោកប្រធានលើកចុងក្រោយអម្បាញ់មិញនេះអត់បាន។ ហើយខ្ញុំបានជម្រាបហើយថា យើងនឹងដាក់សារណាជាលាយលក្ខណ៍អក្សរ គឺឯកសារ E286.1/1។ ដើម្បីបញ្ជាក់នឹងយើងជំទាស់បដិសេធមិនឱ្យហៅបុគ្គលហ្នឹងមកទៀតទេ។ ខ្ញុំមិនមានអ្វីនិយាយអីវែងឆ្ងាយទៀតទេនៅកន្លែងនេះលោកប្រធាន។ ព្រោះនៅក្នុងឯកសាររបស់ខ្ញុំនេះមានអំណះអំណាងអស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវសេចក្តីនេះ។ សំណើរសុំទាក់ទងទៅនឹងសាក្សី ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែម។ ចាប់តាំងពីពេលបើកសវនាការមកទល់ពេលនេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្ម ឬបានបញ្ជាក់

ថា អង្គជំនុំជម្រះស្តាប់សក្ខីកម្មពីបុគ្គលប្រហែលជា៨៩រូប។ នៅមុនកិច្ចប្រជុំរៀបចំសវនាការភាគីទាំងអស់បានជូនដំណឹងដល់អង្គជំនុំជម្រះអំពីសំណើសុំឲ្យស្តាប់សក្ខីកម្មបុគ្គលចំនួន ១៧រូប បន្ថែមទៀតមុននឹងកិច្ចដំណើរការនីតិវិធីទៅលើភស្តុតាងក្នុងសំណុំរឿង០០២/០១ ត្រូវបិទបញ្ចប់នោះ។ អង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនភាគីទាំងអស់ដើម្បីបញ្ជាក់ថា តើហេតុអ្វីបានជាភាគីទាំងអស់ពិចារណាថាវាចាំបាច់ត្រូវកោះហៅបុគ្គលថ្មីទាំងនេះបន្ថែមទៀត និងបន្ទាប់មកអង្គជំនុំជម្រះនឹងសម្រេចក្នុងពេលឆាប់ៗថាតើសវនាការសម្តាប់សក្ខីកម្មបុគ្គលទាំងនេះបន្ថែមទៀត វាជាការចាំបាច់ផលប្រយោជន៍យុត្តិធម៌ដែរឬយ៉ាងណា?

[១១:៣០:០៣]

សហព្រះរាជអាជ្ញាបានស្នើសុំឲ្យកោះហៅបុគ្គលចំនួន ១០រូបបន្ថែមទៀត ឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ប្រាំរូបទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ, បីរូបទាក់ទងទៅនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិជ្រៃ ហើយនិងពីររូបទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ។ ដំបូងសហព្រះរាជអាជ្ញាស្នើសុំឲ្យស្តាប់សក្ខីកម្មសាក្សី TCW-505, TCW-386 និងសាក្សី TCW-651 ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំនៅដំណាក់កាលទី១។

ពាក់ព័ន្ធនឹងគោលនយោបាយដែលមានគោលដៅខ្ពស់របប លន់ នល់, ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំនៅដំណាក់កាលទី២ និងទាក់ទងទៅនឹងជនជាតិចាម សហព្រះរាជអាជ្ញាស្នើសុំបន្ថែមទៀតឲ្យស្តាប់សក្ខីកម្មសាក្សី TCW-674 និងសាក្សី TCW-269។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថាសាក្សី TCW-505, TCW-386 និង TCW-651 ត្រូវបានសហព្រះរាជអាជ្ញាត្រូវបានសហព្រះរាជអាជ្ញាកំណត់ថា ជាបុគ្គលដែលមានអាទិភាពសម្រាប់កោះហៅក្នុងសំណុំរឿង០០២/០១ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទី២ នាពេលក្រោយបន្តិចគឺ ឯកសារ E ឬនាពេលក្រោយបន្តិចឯកសារ E236។ តាមពិតទៅសាក្សី TCW-674 ជាសាក្សីដែលមានឈ្មោះនៅក្នុងបញ្ជីបម្រុងរបស់អង្គជំនុំជម្រះសម្រាប់ការកោះហៅទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ។ ប៉ុន្តែទីបំផុតមិនត្រូវបានស្តាប់សក្ខីកម្មដោយសារមូលហេតុសក្ខីកម្មមានលក្ខណៈច្រំដែល។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថាសាក្សី TCW-269 មិនត្រូវបានសហព្រះរាជអាជ្ញា ឬភាគីណាមួយកំណត់កាលពីមុនមកថាមានការពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១នោះឡើយ។ តើពេលនេះសហព្រះរាជអាជ្ញាអាចរៀបរាប់សង្ខេបទៅលើសំណើសុំទាំងប្រាំនេះ ជាពិសេសពាក់ព័ន្ធជាមួយនឹង --

ទាក់ទងនឹងសាក្សីដែលមានរហស្សនាម TCW-269 នេះបានដែរឬទេ?

[១១:៣២:៣៧]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយដោយសង្ខេបដោយហេតុថាលោកប្រធានមានឯកសាររួចហើយគឺ E288/3 ដែលយើងបានដាក់ជូននៅថ្ងៃអង្គារ លើកឡើងអំពីសំណើទាំង១០នេះ ហើយនិងបញ្ជាក់ពីសារៈសំខាន់នៅក្នុងចំណុចសំណើនោះរួចហើយ។ ប្រហែលជាខ្ញុំត្រូវកំណត់សម្គាល់មួយថាយើងជ្រុលហើយថា នេះជាឱកាសចុងក្រោយដើម្បីលើកឡើងនូវបញ្ហាមួយចំនួនទាក់ទងទៅនឹងសាក្សីនោះ។ តាមពិតទៅសាក្សីទាំងប្រាំនេះ ហើយនិងប្រាំទៀតនោះ យើងបានដាក់រួចហើយផ្អែកលើមូលដ្ឋាននៃសហព្រះរាជអាជ្ញាដែលបានធ្វើធានាថាមានឱកាសដ៏សមស្របក្នុងការបង្ហាញសំណុំរឿងរបស់ខ្លួនឲ្យហួសពីវិមតិសង្ស័យ។ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយថា លើកលែងតែការចោទប្រកាន់សំខាន់ណាមួយបង្ហាញភស្តុតាងហួសពីមតិសង្ស័យទាក់ទងទៅនឹងការចោទប្រកាន់នោះ គឺថាបើសិនជាមានវិមិតសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះហើយយើងខ្ញុំមានចំណុចអប្ប-បរិមាប្រាំបន្ថែមដើម្បីបញ្ជាក់ថា សំណើទាំងនេះគឺវាមានសារៈសំខាន់ត្រឹមត្រូវ ជាផ្នែកមួយដែលបានលើកឡើងពីខាងមុនមកហើយ។ នៅ TCW-2069 ដែលសហព្រះរាជអាជ្ញាមិនទាន់មានឱកាសក្នុងការពិនិត្យនូវភស្តុតាងដែលក្នុងដំណាក់កាលសវនាការ។ យើងបានពិនិត្យមើលប្រតិចារឹក យើងបានពិនិត្យមើលឯកសារ។ ហើយសំណើទាំងអស់នេះត្រូវបានដាក់ជូនដោយផ្អែកលើ -- យើងខ្ញុំគិតថាជាការទទួលខុសត្រូវរបស់យើងខ្ញុំក្នុងការដាក់បន្ថែមដោយយើងមានឱកាសដ៏ល្អបំផុត ដ៏សមស្រប ដើម្បីបង្ហាញរឿងក្តីឲ្យហួសពីវិមតិសង្ស័យខាងអយ្យការ របស់អយ្យការ។

នៅពេលដែលយើងដាក់ស្នើសំណើនេះកាលពីមុននោះ នោះគឺដំណាក់កាលដែលសាក្សីមួយចំនួនត្រូវបានកោះហៅឲ្យធ្វើសក្ខីកម្ម។ នេះហើយជាដំណាក់កាលដែលមានការជំទាស់តវ៉ាទាក់ទងទៅនឹងទិដ្ឋភាពមួយចំនួននៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះ នោះវាមិនទាន់ច្បាស់លាស់ ប៉ុន្តែឥឡូវនេះយើងវាយតម្លៃឡើង យើងពិនិត្យឃើញថាមានការជំទាស់តវ៉ាជាបន្តបន្ទាប់ពីមេធាវីការពារក្តីនៅក្នុងរឿងក្តីនេះ។ ដោយបានស្តាប់ភស្តុតាងមួយចំនួន សហព្រះរាជអាជ្ញាជឿថាជាការទទួលខុសត្រូវរបស់ខ្លួនក្នុងការធានាថា យើងមានឱកាសដ៏សមស្របក្នុងការបង្ហាញទិដ្ឋភាពទាំងនេះ។ នេះហើយជាមូលហេតុដែលយើងខ្ញុំស្នើសាក្សីបីទាក់ទងទៅនឹងការជម្លៀសទី១។ ដូចដែលលោក លោកស្រីចៅក្រមបញ្ជាក់ហើយ គឺថា

សាក្សីម្នាក់ៗទាំងបីនេះគឺថាក្នុងបង្ហាញភស្តុតាងអំពីគោលនយោបាយ ការកំណត់ទិសដៅ យកមន្ត្រីអតីត លន់ នល់ ជាទិសដៅក្នុងការជម្លៀសដោយបង្ខំរបស់គេនោះ។

[១១:៣៦:១៧]

ហើយជាការចោទប្រកាន់ដ៏សំខាន់ ហើយផ្នែកដ៏សំខាន់ក្នុងរឿងក្តីនេះនោះគឺថា ការចោទប្រកាន់ពីមនុស្សឃាត ដែលកើតចេញពីអំពើនោះ ដែលជនជាប់ចោទអាចនឹងប្រឈមមុខនឹងការចោទប្រកាន់នោះ។ ជាពិសេសច្បាស់ពីលោក នួន ជា ហើយនិងសំណើថ្មីៗនេះ មេធាវីការពារក្តីទាំងពីរគឺថា ប៉ុន្មានសប្តាហ៍ចុងក្រោយនេះគឺបង្ហាញច្បាស់ថា គោលនយោបាយតម្រង់ទៅរកអតីតមន្ត្រី លន់ នល់ នោះគឺថាជាចំណុចដ៏សំខាន់ដែលជាការដោះបន្ទុករបស់ភាគីមេធាវីទាំងពីរក្រុម ជា -- យើងមានភារកិច្ចក្នុងការបង្ហាញភស្តុតាងអំពីនយោបាយនេះ ដោយសារថាបុគ្គលទាំងបីនេះគឺមកពីតំបន់ខុសៗគ្នានៃប្រទេស។ ហើយជាលទ្ធផលនោះគឺភស្តុតាងរបស់ពួកគេនោះគឺដូចដែលបញ្ជាក់នៅក្នុងសំណើនោះបង្ហាញថា មាននយោបាយត្រូវបានកើតឡើងនៅក្នុងតំបន់ផ្សេងៗគ្នាដូចជា នៅក្នុងស្រុកត្រាំកក់ ស្រុក១២ ហើយដែលមានទិសដៅប្រឆាំងនឹងបុគ្គលិក ឬក៏រាជការសម័យ លន់ នល់។ ហើយគំរូនៃអាកប្បកិរិយានោះគឺកើតឡើងនៅក្នុងទូទាំងប្រទេស នៅក្នុងពេលជម្លៀសដោយបង្ខំលើកទី១ ហើយនិងជាពិសេសមានសេចក្តីថ្លែងការណ៍អំពីការកំណត់យកជនមហាក្បត់ទាំងប្រាំពីរជាដើមពីដំបូងរបស់របបនោះ។ ហើយគឺមាន -- យើងនិយាយថាមាននយោបាយក្នុងការកំណត់យកអតីតមន្ត្រីរបប លន់ នល់។

[១១:៣៨:០៥]

ឃើញថាយើងអាចបង្ហាញពីភស្តុតាងថាមានគោលនយោបាយ មានសេចក្តីប្រកាស ហើយអាចមានភស្តុតាងតាមកាលៈទេសៈថា មានគោលនយោបាយបែបនោះ។ ហើយយើងនឹងជម្រាបច្បាស់ថា យើងមិនព្យាយាមកោះសាក្សីទាំងអស់នេះដើម្បីបង្ហាញនូវភស្តុតាងទៅលើព្រឹត្តិការណ៍ផ្សេងទៀតទេ ដែលអង្គជំនុំជម្រះបានដកចេញតាមរយៈដីកាបំបែកសំណុំរឿងទេ គឺថាឯកសារ TCW-389 គឺថាមកពីស្រុក១២ បាទ។ គឺ 386 ដែលទាក់ទងទៅនឹងបញ្ហាថា ត្រូវដាក់បញ្ចូល។ យើងមិនព្យាយាមស្នើសុំឲ្យមានការកំណត់ទោសទេនៅលើរឿងដែលថាមានឧក្រិដ្ឋនៅក្នុងស្រុក១២ គឺថាយើងមានឱកាសសមស្របដើម្បីបង្ហាញថាមានគោលនយោបាយដ៏ក្តៅគគុកដើម្បីសំដៅទៅរកអតីតមន្ត្រី លន់ នល់ ដូចជានៅស្រុក១២ និងស្រុកត្រាំកក់នេះ ដើម្បីឲ្យគាត់ផ្តល់ភស្តុតាងដែលចង្អុលបង្ហាញថា គឺវាមានភស្តុតាងបែបនោះ។ នេះជាគំរូនេះឯងត្រូវបានប្រើទូទាំងប្រទេសដែលអាចនឹងមានការអះអាងថា នៅចុងសវនាការគឺថាវាមាន

គោលនយោបាយមួយដើម្បីកំណត់យកនូវអតីតមន្ត្រីទាហាន -- មន្ត្រីរបស់លន់ នល់ នោះ។

ចំណុចទី២ ទាក់ទងទៅនឹងការកំណត់ពេលវេលានោះគឺថាយើងមិន យើងនឹងមិនស្នើត្រឹមតែប្រាំនោះទេ គឺថាយើងកំណត់យក១០ គឺថាមិនឲ្យប្រើពេលវេលាច្រើនទេ គឺថាសាក្សីម្នាក់តែកន្លះថ្ងៃប៉ុណ្ណោះទាក់ទងទៅនឹង១០ ប៉ុន្តែយើង បើសិនជាយើងកំណត់យកត្រឹមតែប្រាំ គឺថា ១ថ្ងៃកន្លះ គឺម្នាក់ពេលព្រឹកម្នាក់ពេលល្ងាច។ ហើយយើងមិនស្នើ -- មិនសួរសំណួរអំពីហេតុការណ៍ផ្សេងទៀតដែលមិនមែនជាមូលហេតុនៃការកោះហៅដូចជា កំណត់ទិសដៅមន្ត្រី លន់ នល់ នោះទេ។ ដូច្នេះ ដើម្បីឲ្យយើងខ្ញុំមានឱកាសដើម្បីបង្ហាញភស្តុតាង អំពីបញ្ហានៅក្នុងរឿងក្តីនេះដែលអង្គជំនុំជម្រះនឹងត្រូវធ្វើការវិនិច្ឆ័យសម្រេចភ្លាមៗនេះ។ នៅក្នុងសេចក្តីរៀបរាប់នេះ គឺថាពន្យល់ដោយខ្លួនឯងហើយ គឺជាការគាំទ្រទៅនឹងអ្វីដែលខ្ញុំនិយាយថ្ងៃនេះ។

ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំទី២នោះ សាក្សីពីររូបនេះ គឺថា 251 ហើយនិង 269 យើងបានស្នើដើម្បីគាំទ្រ កថាខណ្ឌនៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះ ដែលជាប្រធានបទនៃការជំនុំជម្រះនេះ។ កថាខណ្ឌ២៦៦, ២៦៨ ហើយនិង ២៨១។

[១១:៤១:២០]

នៅក្នុងកថាខណ្ឌទាំងបីនេះ គឺទាក់ទងទៅនឹងការជម្លៀសដោយបង្ខំទី២ ដែលលោក លោកស្រីចៅក្រមអាចនឹងឃើញ គឺថាមានការធ្វើផែនការសម្រាប់ជម្លៀសទី១ ដែលគេដាក់មូលហេតុពីរយ៉ាងនៅក្នុងការចោទប្រកាន់។ ទី១នោះគឺមូលហេតុដើម្បីបញ្ជូនកម្លាំងពលកម្មអំពីភូមិភាគថ្នាក់តំបន់ខាងត្បូងទៅខាងជើងបាទ ពីទក្សិណទៅឧត្តរជាដើម។ ជាពិសេសការជម្លៀសប្រជាជនចាមជាដើមនោះ។

យើងយល់ថា ហើយយើងក៏ទទួលស្គាល់តាមជំហររបស់អង្គជំនុំជម្រះដែរនៅក្នុងដីកាសម្រេចបំបែកសំណុំរឿងហ្នឹង ដែលថាសំណើរបស់យើងខ្ញុំដើម្បីដាក់បញ្ចូលនៅសាក្សីមួយចំនួនដើម្បីគាំទ្រកថាខណ្ឌមួយចំនួននៅដីកាដំណោះស្រាយនេះ គឺសំណើនោះ គឺចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ គឺឯកសារ E279 ទាក់ទងទៅនឹងការប្តូរទីតាំងប្រជាជនដែលអាចនឹងថា ជាធ្វើទុកបុកម្នេញ។

ហើយនិងពាក់ព័ន្ធនឹងបញ្ហាប្រល័យពូជសាសន៍ អង្គជំនុំជម្រះបានសម្រេចពីខាងដើមហើយថាការចោទប្រកាន់ទាំងអស់នេះ គឺត្រូវបានដកចេញពីការជំនុំជម្រះលើកទី១។ ហើយយើងទទួលស្គាល់ការប្រកាន់ជំហរនេះ អ៊ីចឹងយើងគឺមានចំណុចពីរ។ ទី១ គឺដើម្បីកោះហៅសាក្សីទាំងអស់នេះ ដោយថាអាចនឹងកំណត់នូវអង្គហេតុឡើងវិញ គឺមិនអាចនឹងកំណត់បទចោទ ក្រៅពីអ្វីដែលយើងមាននៅក្នុងសេចក្តី

សម្រេចបំបែកសំណុំរឿងទី១ នោះ -- ទី២ នោះបាទ។ អ៊ីចឹងហើយយើងខ្ញុំចង់បានចម្លើយនៅក្នុងកិច្ចប្រជុំនេះថាការជម្លៀសទី២ ដោយបង្ខំនេះក៏ដាក់បញ្ចូលនៅក្នុងរឿងក្ដីនេះដែរ។

មូលហេតុដែលបានបញ្ជាក់សម្រាបការជម្លៀសនោះ គឺថាដើម្បីប្ដូរទីតាំង ហើយដើម្បីបំបែកជនជាតិចាមនោះដែរ។ នេះជាចំណុចសំខាន់មួយដែលសហព្រះរាជអាជ្ញាទទួលនូវឱកាសដើម្បីបង្ហាញភស្ដុតាងអំពីកថាខណ្ឌទាំងអស់ហ្នឹង គឺមិនមែនបង្ហាញភស្ដុតាងពីប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាម ហើយការចោទប្រកាន់ផ្សេងទៀតខុសពីអ្វីដែលការជំនុំជម្រះដែលបំបែកនេះទេ គឺបង្ហាញភស្ដុតាងថា ការជម្លៀសដោយបង្ខំលើកទី២ នេះគឺត្រូវបានធ្វើឡើងដោយមិនមានមូលដ្ឋានយុត្តិកម្មច្បាប់នោះទេ។

[១១:៤៤:២៩]

ហើយកថាខណ្ឌនោះ គឺថាមិនមានមូលហេតុតាមច្បាប់ក្នុងការបំបែកជនជាតិ ប្រជាជនចាមឲ្យដាច់ៗពីគ្នានោះទេ។ ដូច្នេះសូមជម្រាបថា យើងមិនមានសាក្សីជាចាមណាមួយទេ នៅក្នុងចំណុចជាក់លាក់នេះ ដើម្បីបញ្ជាក់ពីគោលបំណងដោយខុសច្បាប់ក្នុងការបំបែកប្រជាជននេះ។ ពេលនោះយើងនឹងមិនមានឱកាសក្នុងការបង្ហាញភស្ដុតាង ថាមានហេតុការណ៍បែបនោះទេ គឺថាដូចជាមូលហេតុមួយនៃការជម្លៀសបង្ខំទី២នេះ គឺជាការបំបែកជនជាតិចាមឲ្យនៅដាច់ពីគ្នា។ ធ្វើបែបនោះ គឺនឹងធ្វើឲ្យកាត់បន្ថយកាតព្វកិច្ចរបស់យើងខ្ញុំក្នុងការ ការជម្លៀសលើកទី២នោះ គឺវាមិនត្រឹមតែអាក្រក់ទេ ប៉ុន្តែវាជាការបំបែកប្រជាជនចាមផងដែរ។ នេះហើយដែលជាទឡ្ហីករណ៍របស់យើងខ្ញុំដែលអាចនឹងច្បាស់នៅក្នុងសំណើរបស់យើងខ្ញុំ សេចក្ដីរៀបរាប់អំពីសាក្សីដែលថាអាចផ្ដល់ភស្ដុតាងអ្វីខ្លះ។ នេះហើយជាមូលហេតុដែលយើងខ្ញុំដាក់សំណើសុំឲ្យមានសាក្សីពីរបន្ថែមនោះទេ។

[១១:៤៥:៤៩]

រីឯ TCW-269 នោះគឺថា តាមពិតទៅគឺជាសំណើដ៏សំខាន់។ គឺTCCP-215 គឺស្ថិតនៅក្នុងបញ្ជីរបស់សាក្សី។ យើងសន្និដ្ឋានថាអាចនឹងត្រូវបានកោះហៅ សាក្សីហ្នឹងមិនទាន់ត្រូវបានកោះហៅទេ។ យើងខ្ញុំគិតថាដើម្បីឲ្យយើងបំពេញទៅតាមស្តង់ដារនៃភស្ដុតាងគ្រប់គ្រាន់អំពីការជម្លៀសលើកទី២នេះ យើងខ្ញុំយល់ថាជាការសមស្របដើម្បីកោះហៅសាក្សីពីរ មិនត្រឹមតែមួយទេ។ ដូច្នេះ យើងខ្ញុំនឹងស្នើកន្លះថ្ងៃសម្រាប់សាក្សីម្នាក់ៗ អាចនឹង២ថ្ងៃកន្លះសម្រាប់សាក្សីទាំងពីរនេះ ដើម្បីធ្វើឲ្យយើងមានឱកាសគ្រប់គ្រាន់ដើម្បីអះអាងអំពីរឿងក្ដី ជាពិសេសគឺនយោបាយប្រឆាំងអតីតមន្ត្រី លន់ នល់ ជាដើមនោះ។ ហើយជាពិសេស ហើយនិងមូលហេតុមួយទៀតនៃការជម្លៀសដោយបង្ខំលើកទី២នេះ។ ហើយយើងខ្ញុំយល់

ហើយអំពីការកំណត់បទចោទនៅក្នុងករណីការជំនុំជម្រះនេះ។ ហើយយើងខ្ញុំថាមិននឹងប្រើពេលច្រើនរបស់អង្គជំនុំជម្រះនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយទៅលើចំណុចនេះ។ ខ្ញុំគិតថាអង្គជំនុំជម្រះយល់យ៉ាងអំពីសំអាងហេតុដែលលោកបានលើកឡើងក្នុងការស្នើសុំឱ្យទទួលយកសាក្សីទាំងប្រាំរូបនេះ។ ប៉ុន្តែខ្ញុំមានការព្រួយបារម្ភបន្តិចអំពីការប៉ាន់ស្មានពេលវេលារបស់លោកចំពោះសាក្សីមួយរូបៗ។ ខ្ញុំយល់ថាដូចជាមិនមានសាក្សីម្នាក់ដែលកន្លងមកហ្នឹង ចំណាយពេលត្រឹមតែកន្លះថ្ងៃនោះទេ។ ហើយខ្ញុំក៏ចង់ដឹងថាតើការគណនារបស់លោកក្នុងការកំណត់ហ្នឹង តើលោកមានគិតទៅដល់ភាគីដទៃទៀតដែរឬទេ? តើការដែលលោកគណនាថា២ថ្ងៃកន្លះសម្រាប់ប្រាំនាក់ហ្នឹង មានគិតដល់ភាគីដទៃដែរឬទេ?

[១១:៤៨:១៧]

**លោក វីណ្ឌ្លៀម ស្មីត៖**

លោកប្រធាន លោកស្រីចៅក្រម ខ្ញុំយល់ថាតាមខាងព្រះរាជអាជ្ញាគឺជាការគណនាដ៏សមស្រប ហើយវាជាការគណនាដែលថាអាចមានលក្ខណៈធ្វើឱ្យទាក់ទាញក៏ពិតមែន ប៉ុន្តែយើងខ្ញុំសូមនិយាយថា នេះគឺជាសំណើដ៏សុទ្ធចិត្ត ដ៏ត្រឹមត្រូវមួយ ហើយអ្វីដែលព្រះរាជអាជ្ញាចង់បាន អ្វីដែលព្រះរាជអាជ្ញាចង់ធ្វើ គឺដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ គឺយើងផ្តោតជាពិសេសតែទៅលើបញ្ហាជាក់ស្តែងតែមួយប៉ុណ្ណោះ យើងមិនផ្តោតទៅលើបញ្ហាដទៃទៀតក្រៅពីមូលហេតុដែលយើងស្នើសុំឱ្យកោះហៅសាក្សីនោះឡើយ។ ប្រសិនបើយើងធ្វើការកំណត់គោលដៅឱ្យច្បាស់នៅក្នុងការចោទសួរសំណួររបស់យើងនោះ គឺផ្អែកទៅលើការដឹងរបស់យើងដែលថាអង្គជំនុំជម្រះនេះត្រូវបញ្ចប់ក្នុងពេលឆាប់ៗនេះ។ យើងនឹងធ្វើដូច្នេះបាន។ ហើយប្រហែលជា ប្រសិនបើមានការចោទប្រកាន់ថា យើងមិនមានការសន្សំសំចៃពេលវេលា យើងនឹងធ្វើឱ្យបានជោគជ័យនូវការសន្សំសំចៃពេលវេលានេះ នៅក្នុងការសួរដេញដោលរបស់យើងនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការបំភ្លឺរបស់តំណាងសហព្រះរាជអាជ្ញា។ ហើយតើភាគីណាមួយជំទាស់ទៅនឹង

សំណើសុំស្តាប់សក្ខីកម្មបុគ្គលបន្ថែមដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញានេះដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ វាមិនមែនជាការភ្ញាក់ផ្អើលសម្រាប់យើងខ្ញុំដែលថាយើងខ្ញុំជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលថា និយាយអំពីគោលនយោបាយនៃការជម្លៀសលើកទី១ ប្រឆាំងនឹងខាង លន់ នល់។ គឺសាក្សី 505, 651 និងសាក្សីមួយមួយរូបទៀត ក៏ដូចជាសាក្សីនៅក្នុងទួលពោធិ៍ជ្រៃ។ ការពិតទៅ យើងខ្ញុំមិនជំទាស់នោះទេ គឺថាព្រះរាជអាជ្ញានិយាយត្រូវ ហើយអ្វីដែលលើកឡើងក៏វាបញ្ជាក់ផងដែរថា ខាងមេធាវី នួន ជា បានជំទាស់ទៅនឹងហេតុការណ៍ដែលនិយាយអំពីទួលពោធិ៍ជ្រៃ អំពីការសម្លាប់មន្ត្រី លន់ នល់ នោះ ហើយយើងបានបញ្ជាក់រួចទៅហើយកាលពីម្សិលមិញ យើងស្នើសុំឲ្យមានសាក្សីបន្ថែមប្រាំរូបទៀតទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ។ ខ្ញុំនឹងនិយាយអំពីសំណើរបស់ខ្ញុំនៅពេលក្រោយ ប្រសិនបើមានសំណើ។

[១១:៥១:១៦]

ប៉ុន្តែយើងមានបញ្ហាមួយទាក់ទងទៅនឹងសាក្សីពីររូបនៅក្នុងការជម្លៀសលើកទី២។ ខ្ញុំហាក់ដូចជាមិនឃើញមានហេតុផលថាហេតុអ្វីបានជាវាជាបញ្ហាថ្មីមួយ។ ខ្ញុំគិតថាសាក្សីនេះ សាក្សីទាំង២នេះគួរតែត្រូវបានគេកោះហៅតាំងពីដំបូង ស្នើសុំតាំងពីដំបូង។ ដូច្នេះ ខ្ញុំគិតថាហាក់ដូចជាមិនមានភាពពាក់ព័ន្ធ ឬក៏មានភាពចាំបាច់តម្រូវឲ្យមានសាក្សីទាំងពីររូប គឺTCCP-215 និងសាក្សីTCW--

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឲ្យមេធាវីការពារក្តីនិយាយឈ្មោះសាក្សីមួយរូបទៀត។

**ប្រធានអង្គជំនុំ៖**

មានបញ្ហាបកប្រែ លោកបញ្ជាក់អំពីរហស្សនាមសាក្សីចំនួនពីររូប ដែលបកប្រែ។ អ្នកបកប្រែបកប្រែមិនទាន់ទេ។ សូមលោកបញ្ជាក់សាឡើងវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទសូមអភ័យទោសលោកប្រធាន ខ្ញុំនិយាយយោងទៅលើ TCCP-215 និង TCW-674 និង TCW-269។ គឺថាយើងជំទាស់ទៅលើសាក្សីទាំងពីររូបនេះ។ ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយ គឺថាយើងនឹងធ្វើសារណានិយាយអំពីតួនាទី និងមួយទៀតគឺទាក់ទងទៅនឹងតួនាទីរបស់ខៀវ សំផន គឺសាក្សី TCW-164 និង271។

[១១:៥៣:០២]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់កត់សម្គាល់ថា យើងដាក់បន្ទុកទៅលើទូកមានភស្តុតាងបន្ថែមទៀតច្រើន។ សាក្សីកោះហៅមកទៀត ហើយនិងមានសាក្សី TCW-186 ជាគោលការណ៍ សហព្រះរាជអាជ្ញា គេត្រូវធ្វើការងាររបស់គេហ្នឹង ខ្ញុំមិនមានជំទាស់ទេ។ ក៏ប៉ុន្តែជាទូទៅ ខ្ញុំគិតថាការងារគួរតែធ្វើតាំងពីយូរយារណាស់មកហើយ។ ហើយពេលវេលាយើងនេះ គួរតែរក្សាទុកដើម្បីរក្សាសារណាបញ្ចប់ការដេញដោលឲ្យបានល្អ ល្អជាង។

អ៊ីចឹងសំណើនេះវាយឺតយ៉ាវពេកហើយ។ ថ្ងៃ១០ មិថុនា កាលហ្នឹងយើងមានសវនាការ អ៊ីចឹងខ្ញុំអត់មានមើលចម្លើយរបស់សាក្សីទាំងអស់នោះឲ្យបានលម្អិតនោះទេ។ អ៊ីចឹងខ្ញុំមិនអាចជំទាស់អំពីការប៉ាន់ប្រមាណពេលវេលារបស់គាត់ដែលបានស្នើនោះទេ។ ហើយពេលវេលាដែលខាងមេធាវីការពារក្ដីនេះត្រូវការប្រើ ថាចំណាយពេលអីប៉ុន្មាន អីប៉ុន្មាននោះ។ អ៊ីចឹងខ្ញុំក៏មិនអាចប្រមាណដឹងដែរខាងខ្ញុំព្រោះអ៊ីចឹងថាតែឥឡូវនេះមិនអាចធ្វើការប៉ាន់ប្រមាណបានទេ។ ព្រោះយើងកាលដែលគាត់ដាក់សំណើហ្នឹងមក យើងធ្វើសវនាការពេលនុ៎ង។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១១:៥៤:៤៥]

**លោក វីញ្ញៀម ស្មីត៖**

លោកប្រធាន នេះជាការឆ្លើយតបដោយសង្ខេបពាក់ព័ន្ធទៅនឹងអ្វីដែលសហភាតាររបស់ខ្ញុំ គឺមេធាវីការពារក្ដី ខៀវ សំផន បាននិយាយសំណើដែលទាក់ទងទៅនឹងការជម្រើសទី១ គឺមិនយឺតឡើយ ហើយសំណើហ្នឹងបានធ្វើកាលពីប៉ុន្មានឆ្នាំកន្លងមកហើយ។ ចំពោះការជម្រើសទី២ ដូចដែលបានលើកឡើងដោយមេធាវីការពារក្ដី នួន ជា ដែលថាសាក្សី 215 -- TCCP-215 ឬក៏ 674 ត្រូវបានដាក់-- សាក្សីនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ។ ហើយសាក្សីដែលបានដាក់នៅចំពោះមុខដោយតំណាងសហព្រះរាជអាជ្ញាគឺ នៅថ្ងៃទី០៨ មេសា, គឺឯកសារ E379។ សាក្សីទាំងអស់នេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាល ពីពេលមុនរួចទៅហើយ។ ហើយនេះគឺជាអ្វីដែលកើតឡើងនៅពេលដែលមកដល់ចុងបញ្ចប់នៃសវនាការនៅក្នុងប្រព័ន្ធស៊ីវិលឡូ គឺថាចៅក្រមអង្គជំនុំជម្រះជាអ្នកសម្រេច

ថាតើសាក្សីណាមួយត្រូវកោះហៅមក រហូតមកដល់ពេលដែលអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចចុងក្រោយ។ យើងសូមអរគុណដែលមានការចេញសេចក្ដីសម្រេច។ រហូតដល់ពេលមានការចេញសេចក្ដីសម្រេចហ្នឹងទើបយើងដឹងទើបភាគីទាំងអស់គ្នាដឹង ថាតើសាក្សីណាមួយត្រូវបានដកចេញ សាក្សីណាមួយត្រូវបានដាក់បញ្ចូល។ ដូច្នេះហើយវាមិនមែនជាបញ្ហាយឺតនោះឡើយ។ ការដែលនិយាយថាយឺតគឺវាមិនត្រឹមត្រូវនោះទេ។ ទាក់ទងទៅនឹងពេលវេលាប្រសិបបើយើងធ្វើការពិនិត្យទៅលើដើមបណ្ដឹងរដ្ឋប្បវេណីប្អូនរូបដែលយើងបានស្ដាប់ក្នុងមួយថ្ងៃនោះ ខ្ញុំគិតថានេះគឺជាបញ្ហាដែលយើងនិយាយអំពីការសន្សំសំចៃពេលវេលា ហើយព្រះរាជអាជ្ញាក៏នឹងធ្វើការសន្សំសំចៃពេលវេលាតាមបែបនោះដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយទី២ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យស្ដាប់សក្ខីកម្មសាក្សីរបស់បុគ្គលចំនួនបីរូបក្នុងចំណោម បុគ្គលប្រាំរូប ដែលមាននៅក្នុងសម្រង់វីដេអូទាក់ទងទៅនឹងទីកន្លែងសម្លាប់នៅទួលពោធិជ្រៃ។ ហើយខ្សែវីដេអូនេះត្រូវបានទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ ពីមុនមកបុគ្គលទាំងនេះមិនត្រូវបានកំណត់ថាការពាក់ព័ន្ធទៅនឹងសំណុំរឿង០០២នោះទេ។ ហេតុដូច្នេះសំណើសុំនេះ គឺជាសំណើសុំដើម្បីស្ដាប់ភស្តុតាងថ្មីដែលអនុលោមតាមវិធាន៨៨(៤)នៃវិធានផ្ទៃក្នុង។ តើពេលនេះសហព្រះរាជអាជ្ញាអាចលើកឡើងអំពីសំណើនេះឲ្យបានលម្អិតជាពិសេសសូមបញ្ជាក់ថាហេតុអ្វីបានជាការស្នើសុំឲ្យស្ដាប់សក្ខីកម្មបុគ្គលបីរូបក្នុងចំណោមបុគ្គលទាំងនេះ គឺជាការចាំបាច់នោះ?

[១១:៥៨:០០]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ លោកប្រធានយើងស្នើសុំបុគ្គលបីរូបក្នុងចំណោមបុគ្គលប្រាំរូបដែលមាននៅក្នុងសម្រង់វីដេអូដែលមានចំណងជើងថា “១ថ្ងៃនៅទួលពោធិ៍ជ្រៃ”។ គឺឯកសារ E186.1R គឺខ្សែវីដេអូដែលអង្គជំនុំជម្រះបានទទួលយក ហើយវាជាឯកសារវីដេអូនៅក្នុងបញ្ជីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងខែមេសា ឆ្នាំ២០១១។ ហើយបន្ទាប់មកទៀត ព្រះរាជអាជ្ញាបានទទួលនូវ ខ្សែវីដេអូហ្នឹងហើយយើងបានធ្វើសំណើផ្សេងមួយទៀតបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ព្រោះថាមុនពេលដែលយើងធ្វើសំណើនេះយើងអត់មានខ្សែវីដេអូនេះឡើយ។ ហើយអង្គជំនុំជម្រះបានទទួលយកខ្សែវីដេអូនេះ។ ហើយនៅក្នុងខែមេសា ឆ្នាំ២០១១ ក៏មានការបញ្ជាក់ទៅលើបញ្ហានេះដែរ។

លោក លោកស្រីចៅក្រម ចំពោះមូលហេតុដែលយើងស្នើសុំឲ្យមានសាក្សីបីរូបនៅក្នុងខ្សែវីដេអូ

នេះគឺថាមូលហេតុដែលយើងស្នើសុំនោះទាក់ទងទៅនឹងទួលពោធិជ្រៃដូចដែលលោក លោកស្រីចៅក្រមដឹងហើយគឺថាសាក្សីពីររូបបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការសម្លាប់ដូចដែលមានចោទនៅក្នុងដីកាដំណោះស្រាយរួចទៅហើយ។ នៅពេលដែលយើងស្តាប់សក្ខីកម្មរបស់សាក្សីទាំងពីររូបនោះហើយពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួនដែលមាននៅក្នុងសេចក្តីថ្លែងការណ៍នោះ វាហាក់ដូចជាមានបញ្ហាមួយទៀតដែលតម្រូវឲ្យមានការបង្ហាញសក្ខីកម្មដោយសាក្សីដទៃទៀត។ ដូច្នេះ យើងខ្ញុំយល់ឃើញថាវាអាចនឹងមានតម្លៃនៃភស្តុតាង ដើម្បីជួយដល់ព្រះរាជអាជ្ញាក្នុងការបង្ហាញថាមានការសម្លាប់នៅទួលពោធិ៍ជ្រៃ។ ដូច្នេះ ភស្តុតាងដែលគេផ្តល់ឲ្យនោះគឺវានៅមានលក្ខណៈកម្រិត។ ដូច្នេះ នៅក្នុងសក្ខីកម្មដែលសាក្សីបានផ្តល់ឲ្យគេនិយាយថា គេបានឃើញ ប៉ុន្តែមិនមែននិយាយថា "ឃើញ" ទេ គេបែរជាប្រើពាក្យថា "គេបានឮ" ទៅវិញ។ ដូច្នេះហើយសាក្សីដែលយើងជ្រើសរើសឡើងគឺថា គួរតែជាសាក្សីដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។ ដូច្នេះ អ្វីដែលយើងបានស្តាប់ឮនៅក្នុងសក្ខីកម្មហ្នឹង គួរតែមានការគាំទ្រដោយសក្ខីកម្មរបស់អ្នកដទៃ។ ដោយសារតែវាមិនមានបញ្ហានេះកើតឡើង ហើយដោយសារតែមេធាវីការពារក្តី នួន ជា បានជំទាស់ទៅលើការសម្លាប់នៅទួលពោធិ៍ជ្រៃ ដូចដែលមានបង្ហាញនៅក្នុងដីកាដំណោះស្រាយ ហើយដោយសារតែសហព្រះរាជអាជ្ញាមានឱកាសគ្រប់គ្រាន់សមស្របក្នុងការបង្ហាញទៅលើហេតុការណ៍ទាំងអស់នេះ។

[១២:០១:១១]

យើងសូមស្នើសុំកោះហៅសាក្សីបីរូបបន្ថែមទៀត។ ហើយយើងអាចដាក់សាក្សីប្រាំរូបដូចដែលមេធាវីការពារក្តី នួន ជា បានស្នើពាក់ព័ន្ធទៅនឹងទីតាំងសម្លាប់មនុស្ស គឺសាក្សីទាំងប្រាំរូបដែលបានផ្តល់ចម្លើយទៅដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ។ តាមពិតទៅ ប្រសិនបើយើងទទួលបាននូវការសំណើនេះ ហើយសាក្សីបីរូបដែលយើងស្នើសុំឲ្យមកផ្តល់សក្ខីកម្ម គឺសាក្សីដែលមាននៅក្នុងខ្សែវីដេអូនោះ យើងជឿជាក់ថាយើងអាចរកបាន ហើយយើងអាចកោះហៅសាក្សីនោះ គឺកោះហៅសាក្សីបីក្នុងចំណោមសាក្សីប្រាំ ដូចដែលមេធាវីការពារក្តី នួន ជា គាត់ចង់ឲ្យកោះហៅអ៊ីចឹង។

មូលហេតុដែលយើងស្នើសុំឲ្យមានសាក្សីក្នុងពេលនេះ គឺសាក្សីចេញពីក្នុងខ្សែវីដេអូនៅពេលនេះ គឺថានៅពេលដែលយើងរៀបចំបញ្ជីសាក្សីរបស់យើងនៅក្នុងឆ្នាំ២០១១ ខ្សែវីដេអូហ្នឹងមិនទាន់បានចេញផ្សាយនៅឡើយ។ ទោះបីថា សាក្សីហ្នឹងវាមាននៅក្នុងបញ្ជីឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងឆ្នាំ២០១១ក៏ដោយ ប៉ុន្តែនៅពេលនុំងរហូតមកដល់ពេលក្រោយទៀត ទើបខ្សែវីដេអូហ្នឹង គឺនៅឆ្នាំ២០១២

ហ្នឹងទើបខ្សែវីដេអូហ្នឹងអាចត្រូវបានផ្សព្វផ្សាយ ហើយយើងស្នើសុំដាក់ខ្សែវីដេអូហ្នឹងចូលទៅក្នុងសំណុំរឿង។ ហេតុដូច្នេះហើយទើបថា មុនឆ្នាំ២០១២ យើងមិនមានឱកាសដើម្បីបង្ហាញ ឬក៏ដើម្បីកំណត់អត្តសញ្ញាណនៃសាក្សីទាំងអស់នេះ។

[១២:០៣:០៨]

ហេតុដូច្នេះហើយមូលហេតុដែលថា ហេតុអ្វីបានជាយើងស្នើសុំសាក្សីទាំងពីររូបនេះ? ខ្ញុំសូមចំណាយពេលបន្តិចដើម្បីលើកឡើង។ ខ្ញុំគិតថាលោក លោកស្រីចៅក្រមបានឃើញវីដេអូនេះរួចទៅហើយ គឺថាមានទាហានខ្មែរក្រហមបីរូប ដែលមានវត្តមាននៅក្នុងទីតាំងសម្លាប់មនុស្សនោះៗ។ ខ្ញុំធ្វើការដកស្រង់ គាត់បញ្ជាក់ថា៖ គាត់ជាអ្នកដឹកមន្ត្រីជាន់ខ្ពស់ លន់ នល់ យកមកទួលពោធិ៍ជ្រៃនៅថ្ងៃទី៣ បន្ទាប់ពីការរំដោះ។ គាត់និយាយជាមួយមន្ត្រីទាំងអស់នោះ ដើម្បីធ្វើឲ្យមន្ត្រីទាំងអស់នោះ គាត់សប្បាយចិត្ត ប៉ុន្តែមន្ត្រីនោះគាត់អត់ដឹងថាគេត្រូវបាន -- ត្រូវយកមកសម្លាប់នោះទេ។ គាត់មិនដឹងអំពីផែនការដែលថាត្រូវសម្លាប់មន្ត្រីទាំងអស់នោះទេ។

លោក លោកស្រីចៅក្រម ប្រហែលជាយើងត្រូវធ្វើការសិក្សាបន្ថែមទៀតទៅលើការពណ៌នាទាំងអស់នេះ។ ប៉ុន្តែការរៀបរាប់របស់បុគ្គលទាំងបីនៅក្នុងខ្សែវីដេអូនោះគឺវាហាក់ដូចជាភស្តុតាងមួយដ៏ល្អ ដែលវាប្រសើរ អាចថាល្អជាងការសម្ភាសរបស់សហចៅក្រមស៊ើបអង្កេត គឺសាក្សី TCW-644, 699, 803, 689។ ខ្ញុំមិនមាននូវបញ្ជី -- មិនមាននូវឯកសារយោងឲ្យត្រឹមត្រូវទៅលើសាក្សីចុងក្រោយដែលបានស្នើសុំដោយមេធាវីការពារក្តី នួន ជា នោះទេ។ ដូច្នេះទាំងព្រះរាជអាជ្ញា ទាំងមេធាវីការពារក្តីគឺយល់ស្របគ្នា។ ដោយសារហេតុផលដូចគ្នា ដែលថាព្រះរាជអាជ្ញាគួរមានឱកាសបន្ថែមទៀតក្នុងការបង្ហាញទៅលើសំណុំរឿងនេះឲ្យហួសពីវិមតិសង្ស័យ ហើយមេធាវីការពារក្តីក៏ចង់មានឱកាសដើម្បីបង្ហាញថា មិនមានហេតុការណ៍នេះ មិនមានព្រឹត្តិការណ៍នេះកើតឡើង គឺថាខុសពីអ្វីដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ទោះបីថា យើងដោយសារតែមានសាក្សីដែលអាចផ្តល់អំពីតម្លៃនៃភស្តុតាងដែលអាចក្របដណ្តប់ទៅលើបញ្ហាមួយចំនួន។ ដូច្នេះហើយយើងស្នើសុំនៅក្នុងពេលឥឡូវនេះ។

សំណើនេះយើងនឹងមិនធ្វើសំណើនេះទេ ប្រសិនបើមិនមានបញ្ហាទាំងអស់នេះកើតឡើង។ ដូច្នេះខ្ញុំប្រាកដថា មេធាវីការពារក្តី នួន ជា បានពិនិត្យមើលទៅលើខ្សែវីដេអូ ហើយយើងមានការរៀបរាប់ក្នុងវីដេអូនោះផងដែរ ដែលបញ្ជាក់ថាសាក្សីទាំងបីរូបហ្នឹងបាននិយាយអ្វីខ្លះនៅក្នុងខ្សែវីដេអូនោះ។

[១២:០៦:២១]

ក្នុងករណីដែលយើងអាចស្វែងរកភស្តុតាងល្អបំផុតនោះ គឺថា នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ទោះបីថាភស្តុតាងនឹងមកពីខាងព្រះរាជអាជ្ញា ឬក៏ខាងមេធាវីការពារក្តីក៏ដោយក៏យើងត្រូវតែទទួល។ ហេតុដូច្នេះ ខ្ញុំសូមស្នើសាក្សីទាំងបីរូបដែលមាននៅក្នុងខ្សែវីដេអូនោះ គឺគាត់បានចូលរួមដោយផ្ទាល់ និងបានសង្កេតឃើញដោយផ្ទាល់នៅក្នុងការកាប់សម្លាប់ទៅលើមនុស្ស។ ដូច្នេះហើយសាក្សីទាំងអស់នេះ គួរតែជាសាក្សីអាទិភាពដើម្បីធ្វើការកោះហៅ។

ប្រសិនបើមានសាក្សីណាដែលមិនអាចមកចូលរួមបានយើងចង់ឲ្យសាក្សីដែលមេធាវី នួន ជា បានលើកឡើង គឺសាក្សី 664, 699, 803 និងសាក្សីចុងក្រោយនោះ។ យើងស្នើសុំឲ្យសាក្សីទាំងបីរូបដែលមាននៅក្នុងខ្សែវីដេអូហ្នឹងជំនួសដោយសាក្សីដែលបានកំណត់ដោយក្រុមមេធាវីការពារក្តី នួន ជា។

ដូច្នេះយើងមានឱកាសគ្រប់គ្រាន់ដើម្បីបង្ហាញ មិនមែនត្រឹមតែបង្ហាញសំណុំរឿងនោះទេ ប៉ុន្តែបង្ហាញអំពីទម្រង់នៃ -- ដែលបានចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ព្រោះថា នេះជាសាក្សីផ្សេងក្រៅពីសាក្សីរបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ ខ្ញុំគិតថាអង្គជំនុំជម្រះនឹងអាចស្តាប់នូវភស្តុតាងដ៏ល្អបំផុតដែលមានជាជាងស្តាប់ភស្តុតាងដែលមិនសូវជាសំខាន់ណាស់ណានោះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី!

[១២:០៨:២២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ដោយសារសង្ខេបទេ គ្រាន់តែ ខ្ញុំគ្រាន់តែចង់ជម្រាបជូនថា សហមេធាវីនាំមុខគាំទ្រសំណើរបស់សហព្រះរាជអាជ្ញា ហើយនិងខាង -- ហើយនិងសំណើគាត់ពីមុននោះក៏អ៊ីចឹងដែរ។ ទាក់ទងសាក្សីហ្នឹង ខ្ញុំគិតថាសហព្រះរាជអាជ្ញាហ្នឹង គាត់មានសមត្ថភាពក្នុងការវាយតម្លៃតម្រូវការសាក្សីនេះ ព្រោះថាបន្ទុកខាងភស្តុតាង គាត់ចង់កោះហៅអ្នកណាអ្នកណីមក។ អ៊ីចឹងយើងមានទំនុកទុកចិត្តលើកគាត់ទាំងស្រុងតែម្តង។

**ប្រធានអង្គជំនុំ៖**

ចុះភាគីមេធាវីការពារក្តី តើមានជំទាស់ទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា ក្នុងការស្តាប់សក្ខីកម្មបុគ្គលដែលសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះដែរឬទេ?

សូមអញ្ជើញលោក រ៉ិចទ័រ កូប៉េ!

[១២:០៩:១០]

**លោក វិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំដឹងអំពីពេលវេលាដែលយើងដល់ម៉ោងហើយ ប៉ុន្តែខ្ញុំនិយាយដោយសង្ខេបទេ។ យើងបានដាក់សំណើនាប់របស់ សំណើបន្ទាន់មួយទាក់ទងទៅនឹងបញ្ហាទួលពោធិ៍ជ្រៃ។ ហេតុដូច្នេះហើយយើងបានលើកយកទឡ្ហីករណ៍ដែលថា ហេតុអ្វីបានជាសាក្សីទាំងអស់នោះ គឺសាក្សីទាំងប្រាំដែលយើងកំណត់រួចមកហើយហ្នឹងថា ជាសាក្សីដ៏សំខាន់ដែលអាចជួយដល់ស្វែងរកការពិត គឺថាយើងកំពុងធ្វើការជំទាស់ទៅលើហេតុការណ៍កើតឡើងនៅទួលពោធិ៍ជ្រៃ ដូចដែលមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ដូចជាយើងជំទាស់ទៅលើការដែលថា មានគោលនយោបាយសម្លាប់មន្ត្រី លន់ នល់។ យើងបានបញ្ជាក់រួចទៅហើយនៅក្នុងសំណើរបស់យើង ហើយយើងបានស្នើសុំសាក្សីពីររូបដូចដែលមេធាវីការពារក្តី -- ដូចដែលសហព្រះរាជអាជ្ញាស្នើសុំដូច្នេះដែរ។ ដោយសារតែយើងមានគោលដៅដូចគ្នាហ្នឹងគឺថាដូចដែលព្រះរាជអាជ្ញាបានលើកឡើងអ៊ីចឹង គឺស្នើសុំឲ្យមានសាក្សីនៅក្នុងខ្សែវីដេអូនោះ។ អ្វីដែលយើងមិនយល់ គឺថាហេតុអ្វីបានជាខ្សែវីដេអូដែលធ្វើឡើងដោយ ថេត សម្បត្តិ គឺថាគាត់ គឺថាខ្សែវីដេអូហ្នឹងអាចបង្ហាញជាពន្លឺអំពីអ្វីដែលបាននិយាយ អ្វីដែលបានបញ្ជាក់នោះ។

ប៉ុន្តែបញ្ហាសំខាន់មួយទៀតគឺថា យើងយល់ស្របទៅនឹងការជំទាស់ យល់ស្របទៅលើការខ្វែងយោបល់គ្នាទាក់ទងនឹងទួលពោធិ៍ជ្រៃ ជាពិសេសគឺគោលនយោបាយសម្លាប់ទាហាន លន់ នល់។ ដោយសារតែហេតុផលទាំងអស់នេះហើយ ទើបយើងស្នើសុំឲ្យមានការកោះហៅសាក្សីទាំងអស់នេះ។ គឺថាប្រសិនបើនិយាយឲ្យខ្លីទៅ គឺថាព្រះរាជអាជ្ញាគាត់មើលពីមួយជ្រុង ហើយខ្ញុំមកពីមួយជ្រុងទៀត។ ដូច្នេះហើយទើបមិនជំទាស់ទៅលើសាក្សីប៉ុន្មានរូបដែលបានស្នើឡើងដោយព្រះរាជអាជ្ញានោះ។ ខ្ញុំមិនដឹងថាតើខ្ញុំមានឱកាសអាចនិយាយបន្ថែមអំពីសំណើរបស់ខ្ញុំ ឬក៏អត់នោះឡើយ? ព្រោះជាបញ្ហាដូចគ្នាដោយសារខ្ញុំមើលទៅឃើញថាយើងដល់ម៉ោងហើយ ដូច្នេះទុកឲ្យអង្គជំនុំជម្រះជាអ្នកសម្រេចទៅចុះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:១៣:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមជម្រាបភាគី និងសាធារណជនថា ឥឡូវនេះ កិច្ចប្រជុំរៀបចំសវនាការចុងក្រោយលើសំណុំរឿង០០២/០១នេះ គឺនៅមានបញ្ហាបន្តិចបន្តួចទៀតទេ មិនច្រើនទេ ហើយបញ្ហានេះ

គឺពាក់ព័ន្ធទៅនឹងសំណើសុំរបស់មេធាវីការពារក្តីចំពោះសាក្សីមួយចំនួន ដែលលោកមេធាវី នួន ជា មានបំណងថានឹងលើកឡើងអំមិញ ប៉ុន្តែវាអត់មានពេលវេលា។ ឥឡូវហ្នឹង ហើយអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទរួចហើយថា ស្តាប់សក្ខីកម្ម ស៊ឹម ហោ បន្តបញ្ចប់ ដែលនឹងសួរឡើងដោយក្រុមមេធាវីការពារក្តី។ ហើយដោយសារតែហេតុផលនេះ ហើយអង្គជំនុំជម្រះក៏មិនអាចប៉ាន់ប្រមាណនូវពេលវេលាច្បាស់លាស់ក្នុងការក្នុងកិច្ចដំណើរការស្តាប់សក្ខីកម្ម ស៊ឹម ហោ នៅរសៀលនេះ ដែលនឹងអាចបញ្ចប់នោះ អង្គជំនុំជម្រះសម្រេចថានៅរសៀលនេះ គឺនៅពេលដែលចូលវិញ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្ម ស៊ឹម ហោ តាមកាលវិភាគដែលអង្គជំនុំជម្រះគ្រោងទុកបានជម្រាបជូនសាក្សីកាលពីម្សិលមិញរួចហើយ គឺចាប់ផ្តើមពីម៉ោងមួយ សាបសិបនាទីទៅ។ ហើយប្រសិនបើកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះបានចប់មុនពេលកំណត់នោះ ហើយនៅពេលវេលាសេសសល់ អង្គជំនុំជម្រះនឹងធ្វើការប្រជុំបន្តកិច្ចប្រជុំពិភាក្សា លើកិច្ចរៀបចំសវនាការនៅក្នុងសំណុំរឿង០០២/០១ បញ្ចប់ ដោយសារមានបញ្ហាបន្តិចបន្តួចតូចទេ ទំនងជាអាចប្រើប្រាស់ពេលវេលាយ៉ាងយូរមួយម៉ោងប៉ុណ្ណោះ។ សូមភាគី និងសាធារណជនជ្រាប។

ឥឡូវនេះដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលតទៅ រហូតដល់ម៉ោងមួយសាមសិបនាទី សូមចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការស្តាប់ការពិភាក្សាដេញដោលលើសក្ខីកម្មសាក្សី ស៊ឹម ហោ តាមកាលវិភាគដែលបានកំណត់ទុក។

សម្រាកចុះ!

*(កិច្ចប្រជុំរៀបចំសវនាការសម្រាកនៅម៉ោង ១២:១៦ នាទី និងបន្តនៅម៉ោង ១៥:១២ នាទី)*

[១៥:១១:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តនៅកិច្ចប្រជុំរៀបចំសវនាការរបស់យើងដែលបានធ្វើកាលពីព្រឹកមិញ ហើយនៅមិនទាន់ចប់នៅមួយផ្នែកតូចទៀត។ ដោយពេលវេលានេះអំណោយផលយើងអាចធ្វើកិច្ចការនេះចប់នៅរសៀលនេះ។ ហើយកាលពីព្រឹកមិញយើងដល់ចំណុចមួយពាក់ព័ន្ធទៅនឹងសំណើសុំរបស់

សហព្រះរាជអាជ្ញាសុំដាក់បន្ថែមនូវសាក្សីមួយចំនួនដើម្បីឲ្យ នៅចំពោះមុខអង្គជំនុំជម្រះដើម្បីផ្តល់សក្ខីកម្ម។ ហើយជាបន្តទៅនេះគឺដូចគ្នាអ៊ីចឹងដែរគឺទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យស្តាប់ភស្តុតាងពីបុគ្គលចំនួនប្រាំរូបបន្ថែមទៀត ហើយបុគ្គលបីរូបមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ៣ បុគ្គលដែលត្រូវបានកំណត់ថាពាក់ព័ន្ធទៅនឹងសំណុំរឿង០០២ ក៏ប៉ុន្តែមិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ គឺសាក្សី TCW-644, TCW-689, TCW-699។ សាក្សីពីររូបក្នុងចំណោមនេះមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងសវនាការកាលពីមុនមក ហើយថ្ងៃនេះត្រូវបានកំណត់អត្តសញ្ញាណរហស្សនាម TCW-802 និង TCW-803។ ហើយតើពេលនេះក្រុមមេធាវីការពារក្តី នួន ជា អាចរៀបរាប់លម្អិតអំពីខ្លឹមសារនៃសំណើសុំទាំងនេះបានដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការពិតយើងខ្ញុំអាចរៀបរាប់បានលោកប្រធាន។ អនុញ្ញាតឲ្យខ្ញុំចាប់ផ្តើមដោយសុំអធ្យាស្រ័យដែលកាលពីព្រឹកមិញខ្ញុំបានប្រាប់ឈ្មោះនូវខ្សែភាពយន្តឯកសារគឺពាក់ព័ន្ធនឹងសាក្សី TCW-720។ ខ្ញុំក៏បានលើកឡើងសាក្សី TCW-720 កាលពីព្រឹកមិញ ដោយសារតែនៅក្នុងខ្សែភាពយន្តនិយាយអំពីទួលពោធិ៍ជ្រៃគាត់នោះមិនមែនបានរៀបរាប់អំពីទាហានប៉ុណ្ណោះនោះទេ គឺដូចដែលបាននិយាយដោយសហព្រះរាជអាជ្ញានៅក្នុងរូបខ្សែភាពយន្តនោះក៏យើងមើលឃើញអ្នកផលិតខ្សែភាពយន្តនោះសួរកូនក្តីរបស់ខ្ញុំ នួន ជា ថាតើមានគោលនយោបាយដែរឬទេ? នៅក្នុងរបបឬមុនរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគោលនយោបាយក្នុងការកំណត់អត្តសញ្ញាណ និងការកាប់សម្លាប់មន្ត្រី លន់ នល់ ទាហាន នល់ នល់។ នៅក្នុងខ្សែភាពយន្តនោះកូនក្តីរបស់ខ្ញុំនោះ គឺគាត់ គឺគាត់បានលើកឡើងថាមិនមានទេគោលនយោបាយបែបនុ៎ង។ ឈរលើមូលដ្ឋាននេះហើយ ដែលវាជាមូលដ្ឋានសំណើរបស់ខ្ញុំជាសំណើដែលខ្ញុំបានជូនជាការគោរពកាលពីម្សិលមិញផងដែរ ខ្ញុំស្នើសុំសាក្សីសំខាន់ៗទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ។ ខ្ញុំមិនបានស្នើសុំសាក្សីប្រាំនាក់នោះទេនៅក្នុងសំណើរបស់យើងខ្ញុំ គឺប្រាំមួយនាក់ឯណោះ។

ខ្ញុំសូមចាប់ផ្តើមប្រសិនបើអនុញ្ញាត។ ខ្ញុំលើកឡើងសាក្សីទាំងប្រាំមួយ ដែលមាននៅក្នុងសំណើនោះ គឺ TCW-223, TCW-223 គឺមេធាវីការពារក្តី នួន ជា នោះគឺថាយើងដឹងច្បាស់ណាស់ថាជាសាក្សីមួយសំខាន់ខាងយើងខ្ញុំយល់ដូច្នេះ។ TCW-223 មិនត្រឹមតែដឹងស្គាល់ នួន ជា ច្បាស់នោះទេ ហេតុផលនេះហើយទើបយើងស្នើសុំឲ្យកោះគាត់មក គឺដោយសារតែគាត់គឺជាសាក្សីអត្តចរិត គាត់ស្គាល់ច្បាស់ទៅលើ នួន ជា។ សាក្សី TCW នេះផងដែរ TCW-223 នេះក៏ជាមេបញ្ជាការខ្មែរក្រហម

ដែលគាត់បានដឹងអំពីអត្ថិភាពនៃគោលនយោបាយក្នុងការកំណត់គោលដៅសម្លាប់ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់។

[១៥:១៧:០៦]

សាក្សី TCW-223 គឺតាមការសន្និតគាត់មានវត្តមានក្នុងពេលដែលគេពិភាក្សាទៅលើគោលនយោបាយនោះ ហើយសាក្សីរូបនេះទំនងជា -- គឺជាភស្តុតាងដែលរឹងមាំ ហើយគឺគាត់ក៏អាចបង្ហាញថា គ្មានគោលនយោបាយបានបង្កើតឡើងក្នុងការកំណត់គោលដៅមន្ត្រីរដ្ឋការ លន់ នល់ និងទាហាន លន់ នល់ នោះទេ។ បានន័យថាមិនមានការកាប់សម្លាប់ទាហាន និងមន្ត្រី លន់ នល់ នោះទេ។ ដូច្នេះហើយវាជាបញ្ហាមួយដែលមានសារៈសំខាន់ណាស់ដែលសាក្សី TCW-223 គឺជាសាក្សីមួយជាមូលដ្ឋានសំខាន់នៅក្នុងសំណើរបស់យើងខ្ញុំ។

នៅពេលនេះ ខ្ញុំសូមអនុញ្ញាតលើកឡើងថា ខ្ញុំសង្ឃឹមថានៅក្នុងថ្ងៃនេះ ឬក៏ដំណាក់កាលក្រោយ យើងខ្ញុំនឹងទទួលបានការជូនដំណឹងថា ហេតុអ្វីបានជាអង្គជំនុំជម្រះមិនបានឯកភាពគ្នា ជាពិសេសលើការកោះហៅសាក្សី TCW-223 ដែលជាសាក្សីអត្តចរិតតែមួយប៉ុណ្ណោះដែលអាចបញ្ជាក់អំពីលោក នួន ជា បាន។

[១៥:១៨:២២]

នេះជាបញ្ហាមួយដោយឡែក ក៏ប៉ុន្តែយើងខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះធ្វើការបំភ្លឺលើបញ្ហាហ្នឹងជូនយើងខ្ញុំ។ ខ្ញុំលើកឡើងបញ្ហានេះគឺ ហេតុផលដែលខ្ញុំស្នើសុំសាក្សីប្រាំបន្ថែមពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃនោះគឺដោយសារមូលហេតុថា នៅចុងខែមេសា ដើមខែឧសភា យើងឃើញថាមានសាក្សីចំនួនតែពីររូបតែប៉ុណ្ណោះដែលបានផ្តល់សក្ខីកម្មអំពីព្រឹត្តិហេតុ ឬក៏ហេតុការណ៍ដែលកើតឡើងនៅទួលពោធិ៍ជ្រៃ។ វាបង្ហាញយ៉ាងច្បាស់ថា សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីឯកភាពលើអង្គហេតុថា សាក្សីទាំងពីរនេះគឺមិនបានបញ្ជាក់ទាល់តែសោះថា ពួកគាត់មិនធ្លាប់បានមកផ្តល់សក្ខីកម្មនៅមុខចៅក្រមស៊ើបអង្កេតនោះទេ។ វាមានចន្លោះប្រហោងធំធេងណាស់ ដែលយើងបានរៀបរាប់នៅក្នុងសំណើរបស់យើងខ្ញុំ។ ជាពិសេសពាក់ព័ន្ធទៅនឹងកំណត់ហេតុរបស់គាត់ និងសក្ខីកម្មដែលគាត់នឹងមកផ្តល់ជូន។

ចំណុចសំខាន់មួយទៀតសាក្សីទាំងប្រាំរូប ដែលចៅក្រមស៊ើបអង្កេតផ្អែកនៅក្នុងដីកាដំណោះស្រាយនោះគួរតែកោះហៅមកឲ្យមកចូលខ្លួនក្នុងនាមជាសាក្សីចំពោះមុខអង្គជំនុំជម្រះរបស់យើង។ ខ្ញុំបានស្តាប់ឮសហព្រះរាជអាជ្ញាលើកឡើងក្នុងថ្ងៃនេះ ដែលថាមិនអាចនោះទេ ដែលថាយើងមិនអាចកោះ

ហៅគាត់នោះជាសាក្សីនោះឡើយ ក៏ប៉ុន្តែបើសិនជាពីរមិនអាចកោះបាន គួរតែកោះហៅបីនាក់មក។ ដូច្នេះហើយចំពោះមេធាវីការពារក្តីយើងគិតថា វាមានសារសំខាន់ណាស់ សាក្សី TCW-223 ហ្នឹងមិនត្រឹមតែត្រូវចូលខ្លួនមកទេ គឺសាក្សីប្រាំនាក់បន្ថែមទៀតពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃក៏ត្រូវកោះហៅមកផងដែរ។

យើងបានរៀបរាប់ហើយថា អ្វីដែលសាក្សីទាំងនោះអាចផ្តល់សក្ខីកម្ម និងអ្វីដែលពួកគេបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំសូមលើកឡើងថា ខ្ញុំរីករាយប្រសិនបើអង្គជំនុំជម្រះថា ចង់ជ្រាបទៅលើបញ្ហានេះ ហើយថាតើមានអ្វីខ្លះដែលយើងខ្ញុំបានសរសេរនៅក្នុងសំណើស្នើសុំសាក្សីទាំងនេះនោះ។ សរុបមកវិញ ចំពោះមេធាវីការពារក្តីយើងគិតថា មានសារៈសំខាន់ណាស់ដែលសាក្សីទាំងប្រាំមួយនាក់ត្រូវតែចូលខ្លួនមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ ជាពិសេសនៅក្នុងវគ្គសវនាការក្នុងវគ្គនេះតែម្តង។ សូមអរគុណ។

[១៥:២១:០៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណនៅការលើកឡើងបញ្ជាក់នូវបញ្ហានេះ ហើយតើមានភាគីណាមានមតិជំទាស់ទៅនឹងសំណើសុំឲ្យ -- ដោយក្រុមមេធាវីការពារក្តីលោក នួន ជា ក្នុងការសុំកោះហៅបុគ្គលទាំងនេះទាំងប្រាំមួយនេះមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ?

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក វីណ្ឌៀម ស្មីត៖**

សូមថ្លែងអំណរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងជំហររបស់យើងខ្ញុំនៅក្នុងថ្ងៃនេះ យើងមិនជំទាស់ជាក្នុងការកោះហៅសាក្សីទួលពោធិ៍ជ្រៃនោះទេ។ តំណាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីឯកភាពគ្នាថា ភស្តុតាងបន្ថែមទៀតជាប្រយោជន៍សម្រាប់ភាគីទាំងពីរតែម្តង។ ជាពិសេសក្នុងការដោះស្រាយទៅលើកាតព្វកិច្ច បំពេញកាតព្វកិច្ចរបស់ខ្លួន។

[១៥:២២:០៥]

អង្គជំនុំជម្រះត្រូវតែកំណត់ថា តើភស្តុតាងនោះគ្រប់គ្រាន់ដែរឬទេ? អ្វីដែលយើងខ្ញុំស្នើឡើងនោះគឺថាប្រសិនបើយើងកោះហៅសាក្សីទាំងបីនាក់ដែលមានឃើញនៅក្នុងខ្សែរូបភាពវីដេអូនោះ ភស្តុតាងហ្នឹងវាគ្រប់គ្រាន់ អ៊ីចឹងបានន័យថា បើកោះហៅបីនាក់ហ្នឹងហើយ មិនចាំបាច់កោះហៅសាក្សីទាំងអស់

ដែលមេធាវីការពារក្តី នួន ជា បានស្នើសុំនោះ បន្ថែមនោះទៀតទេ។ ផ្អែកតាមគោលការណ៍នោះ តុលាការនេះត្រូវតែដោះស្រាយ និងពិនិត្យទៅលើភស្តុតាងដែលល្អៗបំផុតតាមរយៈខ្សែវីដេអូ ដូចដែលបានលើកឡើងនៅក្នុងនោះ ទាហានទាំងបីនាក់ គឺបានទំនងជាបង្ហាញនូវ -- ផ្តល់នូវភស្តុតាងដែលពួកគាត់ឃើញដោយផ្ទាល់ភ្នែកជាជាងប្រាំនាក់ដែលមេធាវីការពារក្តីស្នើសុំ។ ដូច្នេះហើយយើងខ្ញុំសូមឱ្យកោះហៅសាក្សីបីនាក់ក្នុងខ្សែវីដេអូនុ៎ងជាមុនសិនមក ហើយយើងនឹងពិចារណាពេលវេលារបស់តុលាការថា តើត្រូវកោះហៅសាក្សីបន្ថែមទៀតដែរឬទេ ពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ។ នេះគឺជាការគ្រប់គ្រងទៅលើពេលវេលារបស់យើង ហើយខ្ញុំគិតថាការធ្វើដូច្នេះ គឺថាភស្តុតាងហ្នឹងគឺត្រូវបានស្នើសុំពីភាគីគ្រប់គ្នារួចមកហើយ។ ហើយវាជួយទៅដល់ការបំពេញកាតព្វកិច្ចរបស់យើងបានទាំងអស់គ្នា។ ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់សម្រាប់កំណត់ហេតុប្រតិចារឹកពាក់ព័ន្ធទៅនឹង TCW-233 សហព្រះរាជអាជ្ញាបានបញ្ជាក់ជំហររបស់យើងខ្ញុំលើសាក្សីមួយនេះ គឺ 233 -- TCW-233។ ជំហររបស់ខ្ញុំបានលើកឡើងនៅក្នុងញត្តិរបស់ខ្ញុំកាលពីមុនដាក់ជូនអង្គជំនុំជម្រះ ឃើញមាននៅក្នុងឯកសារ E93/2 ចុះថ្ងៃ១១ ខែកក្កដា ឆ្នាំ២០១២ ហើយនិង E9/14/1/1 ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១។ យើងខ្ញុំក៏សូមបញ្ជាក់ក្នុងប្រតិចារឹកផងដែរថា ខាងតំណាងសហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះ និងលើកឡើងថា ប្រសិនបើសាក្សីយើងមិនកោះហៅសាក្សីមកចំពោះមុខអង្គជំនុំជម្រះនោះទេ យើងគួរតែទទួលយកកំណត់ហេតុសាក្សីរបស់គេ គឺប្រតិចារឹករបស់ TCW-233 គួរតែទទួលយក ពិសេសកំណត់ហេតុរបស់សាក្សីរូបនេះ។

[១៥:២៤:៣៦]

ហើយយើងក៏បានលើកឡើងផងដែរ ថាប្រតិចារឹកដែលពាក់ព័ន្ធទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ប៉ែន -- ជាមួយនិង ប៉ែន យៀវនិន គឺ TCW-92 ក៏គួរទទួលយកផងដែរ កំណត់ហេតុរបស់គាត់នោះ។ ហើយដោយសារតែ TCW-233 គាត់មិនអាចមកតុលាការនេះផងទេ។ ឯកសារ D313/1.2.406.1។ ឯកសារមួយនេះគឺមានកំណត់ខ្សែអាត់ TCW-223 ជាពិសេសបង្ហាញអំពីការដែលគាត់លើកឡើងអំពីកិច្ចប្រជុំដែលគាត់ថាគាត់បានចូលរួមផងដែរនាសម័យនោះ ជាពិសេសកិច្ចប្រជុំដែលគាត់ដែលគាត់បានចូលរួមប្រជុំជាមួយនឹង នួន ជា ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ដែលក្នុងពេលប្រជុំនោះ គឺគេបានលើកឡើងពិភាក្សាអំពីគោលនយោបាយពាក់ព័ន្ធទៅនឹងមន្ត្រីរបប លន់ នល់។

ចំពោះ TCW-92 កំណត់ហេតុរបស់សាក្សី TCW-92 និងឯកសារពាក់ព័ន្ធនឹងបុគ្គលរូបនេះគួរតែទទួលយកមកផងដែរ។ TCW-223 ជាពិសេសនោះ គឺថាយើងគួរតែយកកំណត់ហេតុរបស់គាត់

ដែលគាត់ឆ្លើយអំពីកិច្ចប្រជុំដែលគាត់បានចូលរួមនៅក្នុងថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥។ ហើយដែលកំណត់ទាំងនេះវាខុសពីកំណត់ហេតុរបស់សាក្សី TCW-233។ ដូច្នេះខ្ញុំស្នើសុំដូច្នេះ ប្រសិនបើមេធាវីការពារក្តីឯកភាពនោះ គឺថាកំណត់ហេតុរបស់បុគ្គលដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ គឺពាក់ព័ន្ធនឹងអត្តចរិត និងទាក់ទងនឹងអំពើរបស់ជនជាប់ចោទ។

[១៥:២៦:៣៧]

ហើយប្រសិនបើសាក្សី TCW-223 មិនមកចូលខ្លួនក្នុងតុលាការនោះទេ គឺតំណាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីត្រូវតែមានជំហរ និងលើកឡើងឲ្យបានច្បាស់លាស់ ហើយបើសិនគាត់មិនមកនោះទេ គឺថាយើងគួរតែទទួលយកកំណត់ហេតុរបស់សាក្សីរូបនេះ ហើយយើងត្រូវពិចារណាទៅលើកំណត់ហេតុទាំងអស់នោះផងដែរ។ នេះគឺជាជំហររបស់មេធាវីការពារក្តី។ សូមអរគុណ។ អ៎! ជាជំហររបស់តំណាងសហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

បញ្ជាក់អំមិញ បញ្ជាក់បន្តិចថា ដោយសារការអាចមកពីការបកប្រែ ឬក៏មានការនិយាយម្តងខុសគ្នា។ ដែលលោក ស្មីត ដែលលោកមានលើកឡើងដល់សាក្សី TCW-223 ឬក៏ 233? ព្រោះសាក្សីដែលមានលេខរបៀបនេះ គឺមានតែមួយគឺ តាមសំណើសុំរបស់លោកមេធាវីការពារក្តីលោក នួន ជា ក្នុងចំណោមប្រាំមួយ គឺមានសាក្សីដែលមានរហស្សនាម TCW-223, មិនមែន 233 ទេ។

បាទ សូមបញ្ជាក់ដើម្បីជាប្រតិចារឹកកុំឲ្យមានការភ័ន្តច្រឡំលើការកំណត់អត្តសញ្ញាណនៃសាក្សីនេះ។

[១៥:២៨:០៦]

**លោក វីល្លៀម ស្មីត៖**

សូមអធ្យាស្រ័យលោកប្រធាន។ កំហុសរបស់ខ្ញុំ។ ខ្ញុំតាមពិតទៅនិយាយសំដៅលើ TCW-223 ទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកៗមេធាវីឲ្យភាគីខាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងមុនបាទ។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំនិយាយដោយខ្លីទេលោកប្រធាន។ សហមេធាវីនាំមុខពុំមានការជំទាស់អ្វីទេទៅនឹងសំណើរបស់លោកមេធាវីរបស់លោក នួន ជា ទេ។ អ៊ីចឹងត្រូវមានជម្រើសក្នុងជ្រើសរើសសាក្សីដែលត្រូវមកផ្តល់

សក្ខីកម្មនៅទីនេះ។ អ៊ីចឹងអត់មានជំទាស់អីទេលោកប្រធាន។

[១៥:២៨:៥៤]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ បញ្ហាដែលខ្ញុំចង់គូសបញ្ជាក់នោះគឺមានដូចតទៅ។ ដូចដែលអង្គជំនុំជម្រះស្នើសុំពាក់ព័ន្ធនឹងសាក្សី TCW-223 គឺថាភាគី និងអង្គជំនុំជម្រះបានជ្រាបហើយ វាជាសំណើថ្មីមួយដែលវាពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ ជាពិសេសនៅក្នុងវគ្គសវនាការលើកនេះ។ យើងខ្ញុំស្នើសុំ TCW-223 តាំងខាងពីដំបូងមក គាត់បាន -- ខ្ញុំរៀបរាប់មូលហេតុរបស់ខ្ញុំនៅក្នុងសំណើរបស់ខ្ញុំ ហើយវាជាស្ថានភាពថ្មី ដោយសារតែយើងបន្ថែមអង្គហេតុទួលពោធិ៍ជ្រៃ។ ដូច្នេះហើយទើបយើងខ្ញុំយល់ឃើញថាសក្ខីកម្មនិងភស្តុតាងរបស់សាក្សីដែលយើងខ្ញុំស្នើសុំនេះ វាកាន់តែសំខាន់ឡើង ហើយដែលវាបានបង្ហាញអំពីគោលនយោបាយ តើមានឬមិនមានពាក់ព័ន្ធទៅនឹងការសម្លាប់មន្ត្រីរដ្ឋការនិងទាហាន លន់ នល់។ សាក្សីរូបនេះ គឺអាចបញ្ជាក់ និងសម្រេចថាតើហេតុការណ៍ដែលនៅទួលពោធិ៍ជ្រៃនោះ គឺសកម្មភាពរបស់កម្មាភិបាលមូលដ្ឋាន ដោយសារខឹងសម្បាទៅនឹងមន្ត្រីទាហានរបប លន់ នល់ ឬក៏ជាគោលនយោបាយបង្កើតតាំងពីដើមដំបូងមក។ ដូច្នេះហើយនេះជាសំណើរបស់យើងខ្ញុំថ្មី ទឡ្ហីករណ៍ថ្មីនៅពេលដែលយើងនិយាយអំពីសំណើសុំសាក្សី TCW-223។ ដូចខ្ញុំបានបញ្ជាក់ពីខាងដើមអ៊ីចឹង គឺថាខ្ញុំមិន -- សូមបញ្ជាក់គឺចំពោះមេធាវីការពារក្ដី គឺថាយើងខ្ញុំត្រូវការឲ្យសាក្សីនេះ មកផ្ដល់សក្ខីកម្មជាខ្លាំង។

[១៥:៣០:៥១]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោក វែកគែន!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ បាទ ទាក់ទងទៅនឹងការដាក់សក្ខីកម្មសាក្សីជាលាយលក្ខណ៍អក្សរដែលមិនអាចមកផ្ដល់សក្ខីកម្មនៅទីនេះ ទាក់ទងទៅនឹងឥរិយាបថរបស់ជនជាប់ចោទ ហើយនិងទង្វើគាត់ហ្នឹង យើងខ្ញុំសូមជំទាស់ ព្រោះយើងមានសរសេរនៅក្នុងឯកសារ E277 ដែលមានសេចក្ដីសន្និដ្ឋាន

របស់យើងពាក់ព័ន្ធនឹងបញ្ហានេះ ដែលយើងដាក់នៅថ្ងៃទី០៩ មេសា ឆ្នាំ២០១៣ រួចហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ បន្តទៀត ចុងក្រោយទាក់ទងទៅនឹងតួនាទីរបស់ ខៀវ សំផន ជាពិសេសទាក់ទងទៅនឹងការរៀនសូត្រនយោបាយ។ សហព្រះរាជាអាជ្ញាបានស្នើសុំឲ្យកោះហៅសាក្សីដែលមានរហស្សនាម TCW-164 និង TCW-781។ សាក្សីទាំងពីរ ត្រូវបានសហព្រះរាជអាជ្ញាកំណត់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីលើកមុន ថាជាបុគ្គលសំខាន់ដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែថ្មីៗនេះ ត្រូវបានអង្គជំនុំជម្រះស្នើសុំឲ្យលើកទៅស្តាប់សក្ខីកម្មនៅក្នុងសវនាការពេលក្រោយវិញ។ តើពេលនេះ សហព្រះរាជអាជ្ញាអាចរៀបរាប់លម្អិតទៅលើមូលដ្ឋាននៃសំណើសុំនេះដែរឬទេ?

**លោក វីណ្ស៊ៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

ជាថ្មីម្តងទៀត មូលដ្ឋាននៃសំណើនេះ គឺរកឃើញនៅក្នុងអង្គហេតុដែលថាមានភស្តុតាងជាច្រើនត្រូវបានស្តាប់នៅក្នុងរឿងក្តីនេះហើយ ចំពោះអ្វីដែលលោកប្រធានបានប្រកាសនៅថ្ងៃទី៣១ ខែឧសភាដែលថាសាក្សីបន្ទាប់មកទៅទៀតដែលត្រូវកោះហៅមកក្នុងសវនាការនេះ។ ផ្អែកលើការវាយតម្លៃយើងខ្ញុំភស្តុតាងហ្នឹង ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះតាមការកោះហៅសាក្សីតាមរយៈឯកសារដែលត្រូវបានទទួលស្គាល់។

[១៥:៣៣:០៩]

តាមទស្សនៈរបស់យើងខ្ញុំ ដោយចាំថាជំហររបស់មេធាវីការពារក្តីលោក ខៀវ សំផន ថាកាន់តែច្បាស់ហើយ ជាក់លាក់ក្នុងអំឡុងពេលដែលសវនាការបន្តទៅមុខ គឺថាលោក ខៀវ សំផន មិនមានតួនាទីជាក់ស្តែងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយគាត់មិនមានការចូលរួមដោយសំខាន់អ្វីទេ នៅក្នុងសហឧក្រិដ្ឋកម្មរួមក្នុងគោលនយោបាយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ។ នៅក្នុងមួយផ្នែកដ៏ធំហ្នឹង គាត់មិនបានដឹងអំពីថាសហឧក្រិដ្ឋកម្មរួមនោះទេ ហើយនិងបទឧក្រិដ្ឋដែលកើតនៅក្នុងសម័យកាលនោះទេ។ ប៉ុន្តែត្រូវចាំថា ជំហរនោះ ហើយនិងជំហរមួយទៀតទាក់ទងទៅនឹងសេចក្តីប្រកាសដែលសហព្រះរាជអាជ្ញាដែលស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះនោះ ទាក់ទងទៅនឹងបញ្ហាអ្វីផ្សេងទៀតអំពីអំពើនិងអាកប្បកិរិយារបស់ជនជាប់ចោទនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយដោយយល់

អំពីជំហររបស់អង្គជំនុំជម្រះ ហើយនិងការអនុវត្តជាអន្តរជាតិនោះ សេចក្តីប្រកាសនោះមិនគប្បីទទួលស្គាល់នៅក្នុងតុលាការនេះថាជាភស្តុតាងទេ យ៉ាងហោចណាស់ក្នុងករណីដែលសេចក្តីប្រកាសនោះមានព័ត៌មានមួយចំនួនអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលថាត្រូវមានការផ្ទៀងផ្ទាត់ដោយមេធាវីការពារក្តី ហើយក្នុងករណីនោះ មិនត្រូវបានដាក់បញ្ចូលទេ។ នេះជាទម្លាប់អនុវត្តអន្តរជាតិ ហើយក៏ជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែរ ដែលត្រូវធ្វើ ហើយចំពោះសេចក្តីយោងផ្សេងៗទៀតទាក់ទងទៅនឹងការអប់រំនយោបាយ ហើយនិងការចូលរួមក្នុងការលើកកម្ពស់គោលនយោបាយផ្សេងៗរបស់លោក ខៀវ សំផន នៅក្នុងសហឧក្រិដ្ឋកម្មរួម ហើយអំពីការអនុវត្តគោលនយោបាយឆ្ពោះទៅរកអតីតរដ្ឋការទាហាន លន់ នល់ នោះគឺថាភាគច្រើនគឺស្ថិតនៅទៅនឹង-- សម័យនោះគឺថានឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ឥឡូវនេះយើងមើលសំណើពីដើមរបស់សហព្រះរាជអាជ្ញា ដើម្បីឲ្យអង្គជំនុំជម្រះស្តាប់សវនាការអំពីអំណាចរបស់លោក ខៀវ សំផន ការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម សមាជិកភាពរបស់គាត់ជាមួយ នួន ជា នៅក្នុងសហឧក្រិដ្ឋកម្មរួមនោះ ហើយនិងការយល់ដឹងអំពីបទឧក្រិដ្ឋដែលកើតឡើងនៅក្នុងសម័យនោះផងដែរ។

យើងបានស្នើសាក្សីប្រាំពីររូបទៀត។ ឥឡូវនេះយើងបានឃើញថាទាំងប្រាំពីរនោះ ហើយនិងពីរនោះត្រូវបានស្តាប់សវនាការដោយអង្គជំនុំជម្រះហើយ។ ហើយអ្នកទាំងពីរនាក់នោះឥឡូវនេះគឺ ហែម អួន នោះគឺបានដឹងជាសាធារណៈហើយ។ យើងមានសាក្សីមួយទៀត ព្រឹកមិញនេះគឺ TCCP-186 ភស្តុតាងរបស់គាត់មិនទាន់ពេញលេញទេ។ ហើយទាក់ទងទៅនឹងចំណុចដ៏សំខាន់នេះឯងដែលយើងខ្ញុំលើកអម្បាញ់មិញនេះ។ ការចោទប្រកាន់ទាក់ទងទៅនឹងការបណ្តុះបណ្តាលបំពាក់បំប៉នគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដោយខៀវ សំផន នោះ យើងបានស្តាប់សាក្សីពីរផ្សេងទៀត គឺ ពិន ខេង ហើយនិង រស់ ស៊ុយ ជាសាក្សីរបស់មេធាវីការពារក្តីដែលយោងទៅរកសកម្មភាពរបស់លោក ខៀវ សំផន។ ប៉ុន្តែនៅក្នុងចំណោមសាក្សីរបស់សហព្រះរាជអាជ្ញានោះគឺថាយើងចង់កោះអញ្ជើញនោះដើម្បីបង្ហាញពីទិដ្ឋភាពនេះ ដើម្បីបញ្ជាក់ថាការចូលរួមដ៏សំខាន់ ហើយនិងសមាជិកភាពនៅក្នុងសហឧក្រិដ្ឋកម្មរួមជាមួយលោក នួន ជា។ ដើម្បីបង្ហាញអំពីអំណាច ហើយនិងឥទ្ធិពលរបស់គាត់ និងការដឹងអ្វីដែលគាត់ចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មនោះ។ ដូច្នេះយើងខ្ញុំសូមអនុញ្ញាតកោះសាក្សីពីរទៀតដើម្បីមានឱកាសដ៏សំខាន់ក្នុងការបង្ហាញភស្តុតាងថាទិដ្ឋភាពនិយាយពីតួនាទីរបស់លោក ខៀវ សំផន ជាពិសេសនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺរយៈពេល ៣ឆ្នាំ ៨ខែ ហើយសាក្សីដែលត្រូវប្រើសម្រាប់សាក្សីនេះ

ពេលវេលាគឺថា១ថ្ងៃសម្រាប់សាក្សីទាំងពីរ។ យើងខ្ញុំស្នើថា នឹងសួរផ្តោតតែទៅលើទិដ្ឋភាពនេះមួយតែប៉ុណ្ណោះ។ យើងពិនិត្យមើលសាក្សីបីទាក់ទងអំពីតម្លៃជាភស្តុតាង ដើម្បីបង្ហាញអំពីតួនាទីរបស់លោក ខៀវ សំផន នៅក្នុងសហខក្រិដ្ឋកម្មរួម ហើយនិងការដឹងរបស់គាត់នូវគោលនយោបាយ។ យើងមើល TCW-164 នៅក្នុងសំណើរបស់ខ្ញុំទៅអង្គជំនុំជម្រះហ្នឹងគឺមុនពេលកិច្ចប្រជុំរៀបចំសវនាការនេះ ថា ខៀវ សំផន គាត់បានបញ្ជាក់ថា ខៀវ សំផន និង នួន ជាបានចូលរួមនៅក្នុងវគ្គសិក្សាពីរនៅក្នុងពហុកីឡដ្ឋានបុរីកីឡានៅឆ្នាំ១៩៧៦ និង៧៨។ ហើយ ខៀវ សំផន បានពិភាក្សាអំពីការចាប់ខ្លួន ប៉ង់ នៅមន្ទីរ៨៧០ ហើយនិងជាសមគំនិតជាមួយយួន។ ហើយ នួន ជា នៅក្នុងឆ្នាំ១៩៧៨ ដែលថាលោក ខៀវ សំផន បាន និយាយពីអំពើក្បត់ជាតិរបស់ កុយ ធួន។ TCW-781 ដែលបាននិយាយអំពីការបាត់ខ្លួនពាក់កណ្តាលនៃសមាជិកក្នុងកងរបស់គាត់។ នៅក្នុងសម័យកាលនោះក្នុងគោលបំណងនៃការសិក្សាវគ្គសិក្សានោះ ហើយគាត់ពន្យល់ថា វគ្គនោះគឺគេដឹងហើយថា គេដឹងអំពីការបាត់ខ្លួន ហើយការចាប់ខ្លួនមនុស្ស។ គាត់និយាយអំពីការប្រជុំដែល ខៀវ សំផន, វ៉ាន់ រិទ្ធ និង នួន ជា នៅដើមខែមករា ឆ្នាំ១៩៧៩ ដែលថាទាំងបីនាក់គាត់នោះគាត់បានប្រកាសនៅចុងបញ្ចប់វគ្គសិក្សានោះ ដោយហេតុថាមានភាពចាំបាច់ដើម្បីរួមគ្នាដើម្បីវាយប្រយុទ្ធប្រឆាំងនឹងខ្មាំង។ ហើយគាត់បានបញ្ជាក់ថា គឺបន្ទាប់មកគឺមិនមានការចាប់ខ្លួនទេ ពីព្រោះថាគេចង់រួបរួមគ្នាដើម្បីវាយប្រឆាំងតបទៅនឹងវៀតណាមវិញ។ ដូច្នេះលោក លោកស្រីចៅក្រម--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក វែកគែន!

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមផ្តាច់សហភាតារបស់ខ្ញុំហ្នឹង ព្រោះខ្ញុំមិនដឹងថាគាត់និយាយពីអីទេ។ យើងនិយាយអំពីបញ្ហាបច្ចេកទេស ហើយសហព្រះរាជអាជ្ញាកំពុងតែធ្វើសេចក្តីសន្និដ្ឋានចុងក្រោយហើយគាត់និយាយលម្អិតទៅលើសក្ខីកម្ម លើអ្វីដែលគេបាននិយាយពីមុនមក។ ខ្ញុំមើលទៅដូចជាអត់មានប្រយោជន៍អីសោះ ខ្ញុំមិនដឹងថាម៉េចក៏មកនិយាយរឿងហ្នឹង យើងកំពុងតែប្រជុំរៀបចំសវនាការ ម៉េចក៏និយាយពីសំណុំរឿងវែងឆ្ងាយ។

[១៥:៤១:០២]

**លោក វីល្លៀម ស្មីត៖**

លោកចៅក្រមប្រធាន ខ្ញុំយល់អំពីចំណុចរបស់លោក វែកគែន ប៉ុន្តែខ្ញុំលើកពី -- បញ្ជាក់ពីមូលហេតុដែលយើងខ្ញុំដាក់សំណើសាក្សីទាំងអស់នេះ។ តាមពិតនោះ យើងនឹងស្នើសុំឲ្យអង្គជំនុំជម្រះកោះអញ្ជើញសាក្សីទាំងអស់នេះ ពីព្រោះថាយើងមានបញ្ហាចម្រូងចម្រាសខ្លាំងណាស់ អំពីមេធាវីការពារក្តីលោក ខៀវ សំផន ថាគាត់មិនបានពាក់ព័ន្ធនៅក្នុងវគ្គបំពាក់បំប៉ននយោបាយនិងវគ្គអ្វីផ្សេង។ ថាគាត់មិនបានដឹងអំពីគោលនយោបាយ អំពីសហឧក្រិដ្ឋកម្មរួម ដោយសារយើងមានសាក្សីពីរហើយដែលសហព្រះរាជអាជ្ញាបានកោះអញ្ជើញនោះ។ ដើម្បីយើងអនុវត្តកាតព្វកិច្ចរបស់យើង ហើយមានឱកាសដ៏សមស្រប យើងខ្ញុំសូមស្នើដាក់សាក្សីពីរទៀតដែលនឹងត្រូវប្រើពេលតែ១ថ្ងៃតែប៉ុណ្ណោះ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ភាគីពាក់ព័ន្ធផ្សេងទៀតមានមតិយោបល់អ្វីទេលើសំណើសុំរបស់សហព្រះរាជអាជ្ញាសូមស្តាប់សក្ខីកម្មបុគ្គលទាំងនេះ។

[១៥:៤២:១៨]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន យើងគាំទ្រសំណើរបស់សហព្រះរាជអាជ្ញា។ ហើយនៅក្នុងសំណើនោះគឺថាយើងសូមស្នើមួយដែរ សុំឲ្យស្តាប់សាក្សី 94។ តើខ្ញុំអាចពន្យល់ពីមូលហេតុ ហើយចាំ-- ឬក៏ឲ្យខ្ញុំពន្យល់ពេលក្រោយ?

យើងបានធ្វើសំណើនេះទៅតុលាការប៉ុន្មានថ្ងៃមុនដោយទាក់ទងទៅនឹងសាក្សីលេខ94នេះ ហើយខ្ញុំមិននិយាយផ្ទាល់មាត់ពីអ្វីដែលខ្ញុំសរសេរហើយៗនោះទេពីមូលហេតុនោះ។ ក៏ប៉ុន្តែអំណះអំណាងហ្នឹងដូចៗគ្នា ដូចនឹងអំណះអំណាងសហព្រះរាជអាជ្ញាដែរ គឺថាបើបុគ្គលទាំងអស់នេះមាននៅក្នុងបញ្ជីរបស់យើងតាំងពីដើមមកហើយៗ ពេលណាមួយនោះមាននៅក្នុងបញ្ជីរបស់តុលាការផងដែរ។ បុគ្គលនេះត្រូវបានស្នើមកដើម្បីស្តាប់ពីរចនាសម្ព័ន្ធ ហើយនិងការិយាល័យ-- មន្ទីររបស់ជនជាប់ចោទ ហើយគាត់ក៏អាចនិយាយអំពីសុន្ទរកថារបស់លោក ខៀវ សំផន ដែលបាននិយាយទៅកាន់ខ្មែរដែលត្រឡប់មកពីបរទេសនៅខែឧសភា ឆ្នាំ១៩៧៦។ អ៊ីចឹងជាទូទៅបុគ្គលនេះអាចនិយាយអំពីសុន្ទរកថាផ្សេងៗទៀតរបស់លោក ខៀវ សំផន ផងដែរ ហើយនិងស្គាល់ពីការដឹងឮរបស់លោក ខៀវ សំផន អំពីគោលនយោបាយ។ អ៊ីចឹងសំណើរបស់ខ្ញុំនេះ គឺថាអាចស្នើឲ្យទទួលយកបុគ្គលនេះដោយសារគាត់អាចមាន --

អាចផ្តល់ព័ត៌មានគួរឲ្យចាប់អារម្មណ៍ច្រើនលោកប្រធាន។

[១៥:៤៤:១៦]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោក វែកគែន!

**លោក អាកទួរ វែកគែន៖**

បាទ ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ខ្ញុំគួរឲ្យអស់សំណើចដែរ ដែលបានឮលោកសហព្រះរាជអាជ្ញាធ្វើពើ ដូចជាថាធ្វើឲ្យដឹងអំពីអត្ថិភាពនៃវិធានច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលតម្រូវឲ្យសាក្សីអំពើ ហើយនិងឥរិយាបថហ្នឹងត្រូវប្រឈមមុខនឹងការសួរផ្ទាល់។ អ៊ីចឹងនេះមិនគួរឲ្យឆ្ងល់ អស់សំណើចណាស់។ ហើយពេលឮគាត់និយាយថា គាត់ទើបតែរកឃើញ -- អស់រយៈពេលជាយូរមកហើយហ្នឹងទើបតែរកឃើញថា លោក ខៀវ សំផន បដិសេធបទចោទទៅលើគាត់នេះ។ អ៊ីចឹងលោកសហព្រះរាជអាជ្ញា តាំងពីដើមទីមក តាំងពីដំបូងសវនាការបឋមនោះ គាត់ នេះហើយគាត់ប្រាប់គោលជំហររបស់គាត់តាំងពីដើមមកហើយតើ មិនមែនទើបតែនិយាយតែឥឡូវនេះទេ។ អ៊ីចឹង គាត់ប្រាប់ពីគោលជំហរគាត់តាំងពីដើមហើយ។ អ៊ីចឹងថា អំណះអំណាងរបស់ព្រះរាជអាជ្ញានេះ គឺថាមិនមានភាពសុចរិតទេ។ សហព្រះរាជអាជ្ញាហ្នឹងថែមទាំងបានកោះហៅសាក្សីមួយចំនួនដែលធ្លាប់បាននិយាយពីរឿងរ៉ាវទាំងអស់នេះអស់ហើយ។ អ៊ីចឹងយើងសូមជំទាស់ទៅនឹងក្នុងការសុំឲ្យកោះហៅសាក្សីបន្ថែមមកទៀត។

ខ្ញុំមិននិយាយវែងឆ្ងាយទេលោកប្រធាន ដើម្បីផ្តល់មូលហេតុនេះ។ អ៊ីចឹងគឺថាដើម្បីឲ្យចំណេញពេលវេលាសន្សំសំចៃពេលវេលានេះ បើសិនជាមិនកោះបុគ្គលទាំងអស់នេះមកនោះ យើងអាចចំណេញពេលវេលា។ យើងចំណេញពេលវេលា ចង់និយាយថាពេលដែលយើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលហ្នឹង យើងអាចយកពេលហ្នឹងទៅប្រើវិញ។

[១៥:៤៦:១៦]

បាទ ឆ្លើយតបទៅនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីលើកឡើងអម្បាញ់មិញថាយើងបានសុំដាក់សំណើយើងពីរបីថ្ងៃមុននេះ ហើយសំណើនេះត្រូវបានពិភាក្សានៅក្នុងសវនាការថ្ងៃទី១១ មករា ឆ្នាំ២០១៣។ ឯកសារ E1/159.1 គឺជាសំណើសុំស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី 94 ។ បាទ ខ្ញុំគិតថាតារាងដែលតុលាការបានផ្តល់ជូន ផ្ញើជូន បន្ទាប់ពីមានការចេញសារណាថ្ងៃទី៣០ ឧសភា អ៊ីចឹងខ្ញុំសូមជំទាស់ផងដែរនូវការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីលេខ 94 នេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះមេធាវីការពារក្តីលោក នួន ជា យ៉ាងម៉េចដែរ លើសំណើសុំស្តាប់សក្ខីកម្មបន្ថែមរបស់សហព្រះរាជអាជ្ញាលើសាក្សីពីររូប និងសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានស្នើសុំស្តាប់នូវសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីមួយរូប គឺ TCCP-94។

**លោក វ៉ិចទ័រ កូប៉េ៖**

អត់មានការសំណើអ្វីទេ លោកប្រធានពីយើងខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ ជាទីបញ្ចប់នេះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទំនងជាមិនស្នើសុំឲ្យកោះហៅសាក្សីបន្ថែមទៀតទេ សម្រាប់កិច្ចការជំនុំជម្រះក្តីនេះ។ តើក្រុមការពារក្តីអាចបញ្ជាក់បានដែរទេថាជាការពិតដូច្នេះមែនដែរឬទេ?

**លោក អាកទូរ វែកគែន៖**

បាទ បើតាមមើលទៅក្នុងដំណាក់កាលយើងនេះអត់មានចង់កោះហៅអីទេ ប៉ុន្តែបើសិនមានការប្រែប្រួលចំពោះសាក្សីដែលនឹងកោះហៅក្រោយពីមានសំណើរបស់ភាគីច្រើននេះនេះ ខ្ញុំសូមរក្សាសិទ្ធិៗកែប្រែ។ ចង់និយាយថាអាចថាថ្ងៃក្រោយអាចសុំធ្វើសំណើដែរ។ បាទ ប៉ុន្តែឥឡូវខុស ខ្ញុំចូលប្រធានបទផ្សេងទៀត។ ខ្ញុំសូមជម្រាបជូនតុលាការថា នៅក្នុងតារាងរបស់អង្គជំនុំជម្រះដែលរៀបរាប់អំពីសំណើទាំងអស់ដែលបានដាក់នៅក្នុងដំណើរការនីតិវិធីនេះ គឺថា ខ្វះសំណើរបស់លោក ខៀវ សំផន មួយ គឺជាសំណើដែលមានលេខ E220 គឺជាសំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៤ ខែសីហា ២០១២ គាត់សុំឲ្យដាក់ចំពោះមុខតុលាការនៅឯកសារមួយឯកសារថ្មីមួយបាទ។ ហើយសំណើហ្នឹងដូចអត់មាន -- អត់ទាន់បានទទួលចម្លើយពីអង្គជំនុំជម្រះទេ លោកប្រធានសំណើនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក វែកគែន ដែលបានផ្តល់ព័ត៌មានដ៏សំខាន់។ អង្គជំនុំជម្រះនឹងពិនិត្យលើបញ្ហានេះឡើងវិញ។ ពីព្រោះឯកសារជាច្រើនដែលភាគីបានស្នើសុំដូចអង្គជំនុំបានជម្រាបជូនកាលពីព្រឹកមិញអីចឹងថាការកត់សម្គាល់របស់អង្គជំនុំជម្រះឃើញថាសំណើសុំនៅក្នុងអំឡុងពេលធ្វើដំណើរការសវនាការសំណុំរឿង០០២/០១ នេះមានរហូតដល់២៨៥សំណើសុំឯណោះ។ ហើយបញ្ហានេះ បើសិនជាសំណើបានដាក់ហើយនោះ គឺប្រហែលជាមានការធ្វេសប្រហែសក្នុងការរៀបចំពិនិត្យនូវសំណើនេះហើយ ហើយ

អង្គជំនុំជម្រះនឹងពិនិត្យលើបញ្ហា និងដោះស្រាយបញ្ហានេះឲ្យបានល្អ បន្ទាប់ពីបានទទួលការបញ្ជាក់ប្រាប់ពីសំណាក់លោក វែកគែន ជាមេធាវីការពារក្តីលោក ខៀវ សំផន។

[១៥:៥១:០៦]

បាទ អង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណដល់គ្រប់ភាគីដែលបានដាក់សារណារបស់ខ្លួន។ អង្គជំនុំជម្រះនឹងពិចារណាលើសារណាទាំងអស់នេះនឹងក្នុងពេលឆាប់ៗខាងមុខនេះ អង្គជំនុំជម្រះនឹងបញ្ជាក់ជូនថាតើមានបុគ្គលណាខ្លះដែលភាគីបានស្នើសុំនាពេលនេះ និងត្រូវបានកោះហៅមកឲ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

សេចក្តីពន្យល់អំពីហេតុផលពាក់ព័ន្ធនឹងការមិនកោះហៅបុគ្គលណាមួយនឹងមានផ្តល់ជូននៅក្នុងសេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី ដែលអង្គជំនុំកំពុងតែពិចារណាសម្រេច។ សេចក្តីសម្រេចនឹង -- អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចនេះនៅប៉ុន្មានសប្តាហ៍ខាងមុខនេះ។

ហើយមុននឹងបញ្ចប់នូវកិច្ចរៀបចំសវនាការនេះ តើភាគីណាចង់លើកឡើងនូវបញ្ហាសេសសល់ផ្សេងទៀតដែរឬទេ? អម្បាញ់មិញនេះ គឺលោក វែកគែន បានលើកឡើងនូវការបញ្ជាក់របស់ខ្លួនមួយលើសំណើលេខ E220 ដែលជាសំណើរបស់ ខៀវ សំផន ដែលអង្គជំនុំជម្រះមានការហាក់ដូចជាភ្លេចមិនទាន់បានដាក់បញ្ជាក់នៅក្នុងបញ្ជីតារាងស្តីពីឧបសម្ព័ន្ធស្តីពីសំណើសុំរបស់មេធាវីពាក់ព័ន្ធនឹងរឿងក្តីក្នុងអំឡុងពេលកន្លងមក ហើយក៏មិនទាន់ឃើញអង្គជំនុំជម្រះសម្រេចលើបញ្ហានេះ។ នេះជាការព័ត៌មានមួយដ៏សំខាន់ដែលអង្គជំនុំជម្រះនឹងជម្រាបជូនហើយថានឹងពិនិត្យពិចារណាសម្រេចលើបញ្ហានេះ។

[១៥:៥២:៣៨]

បាទ បើមិនមានទេ គឺឥឡូវនេះកិច្ចប្រជុំរៀបចំសវនាការនៅលើកនេះដល់ទីបញ្ចប់ហើយ។ អ៊ីចឹងអង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់គ្រប់ភាគីទាំងអស់ចំពោះការបញ្ចេញនូវរាល់មតិយោបល់ចូលរួមនៅក្នុងកិច្ចប្រជុំដ៏សំខាន់នេះរបស់ខ្លួន។ ហើយក្នុងពេលដ៏ខ្លីខាងមុខនេះ អង្គជំនុំជម្រះនឹងចេញដីកាកំណត់កាលបរិច្ឆេទសវនាការទៅលើឯកសារដែលនឹងធ្វើនៅសប្តាហ៍ក្រោយ ព្រមទាំងចេញដីកាកំណត់កាលបរិច្ឆេទសវនាការលើសំណុំរឿង០០២/០១ ដែលនៅសេសសល់ក្នុងអំឡុងពេលឆាប់ៗខាងមុខនេះ។

ហើយជំនួសឲ្យអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមថ្លែងអំណរគុណដល់សហព្រះរាជអាជ្ញា ដល់សហមេធាវីការពារក្តីជនជាប់ចោទ ដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមន្ត្រីបុគ្គលិកដែលបានចូលរួមគាំទ្រនូវកិច្ចប្រជុំរៀបចំរបស់

យើងនេះ ដែលបានជួយខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត សម្រួលដល់កិច្ចប្រជុំរៀបចំសវនាការរបស់យើងនៅលើកនេះបានជោគជ័យ។

ហើយសូមជូនពរអស់លោក លោកស្រី នាងកញ្ញាជួបតែនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ហើយនិងសូមអស់លោក លោកស្រី នាងកញ្ញាទាំងអស់ទទួលបានជោគជ័យក្នុងការបំពេញភារកិច្ចគ្រប់ៗគ្នា។

បាទ សូមបិទកិច្ចប្រជុំពិភាក្សាលើការរៀបចំសវនាការលើកនេះត្រឹមនេះ។

សម្រាកចុះ៕

*(កិច្ចប្រជុំរៀបចំសវនាការផ្អាកនៅម៉ោង ១៥:៥៤នាទី)*